ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- [illegible]
- [illegible]

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៩ ខែកញ្ញា ឆ្នាំ២០០០

## មាតិកា

◆ សំបុត្រៈ ក្អែកខ្មៅ........................ ១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាពរបស់ ជិន អ៊ា ហៅ ស៊ូ........................ ២

◆ រណ្តៅប្រល័យពូជសាសន៍នៅខេត្តបន្ទាយមានជ័យ........................ ៧

◆ ខួបឆ្នាំទី២៥ នៃកំណើតបក្សកុម្មុយនិស្តកម្ពុជា........................ ១០

◆ សមមិត្ត គង់ ឬ សួង ស៊ីគឿន........................ ១៥

◆ មន្ទីរពេទ្យវិកលចរិតក្លាយជាមន្ទីរឃុំឃាំង........................ ២០

**ផ្នែកប្រវត្តិសាស្ត្រ**

◆ សំឡេងពីមន្ទីរស-២១........................ ២៤

◆ ឈ្លើយសឹកវៀតណាម........................ ២៨

**ផ្នែកច្បាប់**

◆ គំរូមួយនៃភ័ស្តុតាងឯកសារភ្ជាប់មេដឹកនាំជាន់ខ្ពស់........................ ៣១

◆ ការរំលោភលើផ្លូវភេទ........................ ៣៥

◆ វិធីបួនយ៉ាងក្នុងការវិនិច្ឆ័យអំពើទារុណកម្ម........................ ៣៨

**វេទិកាពិភាក្សាជាសាធារណៈ**

◆ សៀវភៅខ្មោះ យុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិន........................ ៤១

◆ តើការលើកលែងទោសជាតម្លៃនៃសន្តិភាព........................ ៤៨

◆ គេរងំណែល........................ ៤៩

◆ ស្នាដៃតាម៉ុក........................ ៥២

◆ ការទាមទារប្រវត្តិសាស្ត្រកម្ពុជាមកវិញ........................ ៥៤

**ធំព័រស្រាវជ្រាវរកគ្រួសារ**

◆ ការសម្លាប់រង្គាលនៅបឹងទន្លេសាប........................ ៥៨

**សិល្បៈខ្មែរក្រហម**

◆ យើងខ្ញុំនារីបដិវត្តកម្ពុជាថ្មី........................ក្របក្រោយ



វន វេត



ខៀវ បុណ្ណារី



គន ហាក់ អាយុ១៧ឆ្នាំ
ថ្ងៃចូលបដិវត្តៈ ៧-៩-១៩៧៤

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**វាគ្មិនលេខនេះ** ដេវីត ឆេនដល័រ, ភីតធឺរ ម៉ាឃ្យៀ, ស៊ីវ ហេឌ័រ, យ៉ន វ៉ាន់ គ្រីនធីន, ហិនរី ឃីសស៊ីងជឺរ, ក្រេក អេចឆេសាន់, ចាយ៉ា វ៉ាមជី, យឹមស៊ុត វ៉ាណាជិត **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុផល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** អែម សុខឃឹម **និពន្ធនាយករងទី១ៈ** ដាត កុសល **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** សួ ប៊ុនស៊ូ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយៈ** ទ្រី សុភក្តិ

**សំបុត្រៈ**

# ក្អែកខ្មៅ

នៅខែកញ្ញា ឆ្នាំ១៩៧៨ ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យដែលមាន អៀង សារី ជានាយករដ្ឋមន្ត្រី បានបោះពុម្ពផ្សាយនូវឯកសារជាផ្លូវការមួយក្រោមចំណងជើងថា «សៀវភៅខ្មៅ» ។ សៀវភៅខ្មៅមានអត្ថន័យប្រហាក់ប្រហែលទៅនឹងបញ្ជីខ្មៅ និងជាទូទៅត្រូវបានស្គាល់ថាជាសៀវភៅខ្មោច ។ សៀវភៅខ្មៅនៃរបបកម្ពុជាប្រជាធិបតេយ្យគឺជាឯកសារឃោសនានិងទាញហេតុផលជាលក្ខណៈអន្តរជាតិដើម្បីការពារគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យ និងជាយុទ្ធសាស្ត្រយក «ស» ធ្វើជា «ខ្មៅ» ហើយយក «ខ្មៅ» ធ្វើជា «ស» ដើម្បីបំបិទភ័ស្តុតាងការបង្អត់អាហារនិងការសម្លាប់រង្គាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សៀវភៅខ្មៅជាតំណាងយ៉ាងពិតប្រាកដឲ្យភាពខ្មៅងងឹតអន្ធការនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏ជាពណ៌សម្បុរនៃសម្លៀកបំពាក់របស់កម្មាភិបាល និងខួរក្បាលរបស់អ្នកដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ។

អៀង សារី បានផ្តល់សម្ភាសន៍នៅប្រទេសស៊ុយអែដនៅក្នុងឆ្នាំ១៩៨០ ថា «យើង(របបកម្ពុជាប្រជាធិបតេយ្យ) ត្រូវបានធ្វើឲ្យជឿជាក់ថា រដ្ឋាភិបាលចិនតែងតែជួយជ្រោមជ្រែងយើងក្នុងការតស៊ូដើម្បីទាមទារឯករាជ្យនិងការពារជាតិលុះដល់ថ្ងៃជ័យជម្នះ ។ យើងមិនបានដឹងអំពីជីវិតប្រជាជនតូចតាចឡើយ ប៉ុន្តែមនុស្សឃាតវាអាចកើតឡើង ។ រីឯឃាតករគឺជាពួកយួន ។ វាច្បាស់ដូចថ្ងៃអ៊ីចឹង» ។ ការប៉ះទង្គិចរវាងរបបកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមបានកើតឡើងជាច្រើនលើកច្រើនសា ។ យោធានៃភាគីទាំងសងខាងត្រូវបានចាប់ខ្លួននិងយកទៅសម្លាប់ចោលទៅវិញទៅមក ។ មានទាហានវៀតណាមចំនួន៤៨៨នាក់ត្រូវបានចាប់ខ្លួននៅក្នុងសមរភូមិប្រយុទ្ធ ហើយបានបញ្ជូនមកដល់មន្ទីរស-២១ដែលជាទីកន្លែងឃុំឃាំងសម្ងាត់របស់អង្គការ រួមមានជនជាតិបរទេស ជនជាតិភាគតិច និងដែលភាគច្រើនជាប្រជាពលរដ្ឋខ្មែរចំនួនជាង១ម៉ឺននាក់ទៀត ដើម្បីធ្វើទារុណកម្ម សួរចម្លើយ ហើយក្រោយមកត្រូវសម្លាប់ចោល ។

សៀវភៅខ្មៅមានកម្រាស់ចំនួន៨៩ទំព័រ ចែកចេញជា៧វគ្គ ។ វគ្គទី១ស្តីអំពីសារជាតិកាន់កាប់ទឹកដីរបស់វៀតណាមនៅក្នុងអតីតកាលដែលចែកចេញជា៣ចំណុចធំៗគឺ ក) សកម្មភាពវាតទីនិយមរបស់វៀតណាមនៅក្នុងអតីតកាល ខ) មធ្យោបាយវៀតណាមលេបទឹកដីកម្ពុជា និង គ) សកម្មភាពដែលវៀតណាមបានអនុវត្ត ។ វគ្គទី២ ស្តីអំពីយុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិនរបស់បក្សកុម្មុយនិស្តឥណ្ឌូចិនរបស់ហូជីមិញ (ចុះផ្សាយក្នុងលេខនេះ) ។ វគ្គទី២នេះចែកចេញជា២ចំណុចដែលផ្តោតទៅលើកម្មវិធីនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជានិងយុទ្ធសាស្ត្ររបស់សហព័ន្ធឥណ្ឌូចិន ។ វគ្គទី៣ស្តីអំពីការតស៊ូរបស់វៀតណាម-កម្ពុជានៅលើគោលនយោបាយពីឆ្នាំ១៩៥៤ ដល់ឆ្នាំ១៩៧០ ។ វគ្គទី៤ ស្តីអំពីការប៉ុនប៉ងរបស់វៀតណាមក្នុងការបំផ្លាញឯករាជ្យរបស់កម្ពុជាពីឆ្នាំ១៩៧០-៧៥ ។ វគ្គទី៥ស្តីអំពីកិច្ចចរចានៅទីក្រុងប៉ារីស និងការប៉ុនប៉ងរបស់វៀតណាមក្នុងការកម្ទេចបដិវត្តន៍កម្ពុជា ។ វគ្គទី៦ស្តីអំពីសកម្មភាពរបស់វៀតណាមដើម្បីសម្រេចគោលដៅកាន់កាប់និងលេបទឹកដីកម្ពុជាពីឆ្នាំ១៩៧៥ ដល់បច្ចុប្បន្ន(ឆ្នាំ១៩៧៨) ។ វគ្គទី៧អំពីការបូកសរុប ។

សៀវភៅខ្មៅមានជីវិតដូចជាសត្វក្អែកខ្មៅដែលតែងតែជាប្រផ្នូលនៃភាពចង្រៃខុបទ្រព្យនៅក្នុងសង្គមខ្មែរ ។ ប្រជាជនខ្មែររាប់លាននាក់ដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរវាងឆ្នាំ១៩៧៥-៧៩ គឺមិនខុសពីគំនរខ្មោចដែលបានរៀបចំឡើងឲ្យសត្វក្អែកខ្មៅស៊ីជាអាហារក្រោមដែនការរបស់មេដឹកនាំនៃរបបនេះឡើយ ។

**ឆាំង យុ**



# ចម្លើយសារភាពរបស់ ជិន អ៊ា ហៅ ស៊ូ

ជិន អ៊ា ហៅ ស៊ូ គឺជាអ្នកទោសគុកទួលស្លែងម្នាក់ ដែលត្រូវអង្គការខ្មែរក្រហមចាប់ខ្លួននៅខែ៣ ឆ្នាំ១៩៧៧ ។ ចម្លើយសារភាពរបស់ ជិន អ៊ា បានឲ្យដឹងថា ជិន អ៊ា ឈ្មោះបដិវត្តន៍ ស៊ូ មានអាយុ៣៥ឆ្នាំ (ក្នុងឆ្នាំ១៩៧៧) ទីលំនៅភូមិអំពិល ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ស្ថិតនៅក្នុងតំបន់២២ ភូមិភាគបូព៌ា ។ មុនពេលត្រូវចាប់ខ្លួន ជិន អ៊ា មាននាទីជាប្រធានពាណិជ្ជកម្មតំបន់២២ ភូមិភាគបូព៌ា ។



គ្រែនិងតុសម្រាប់សួរចម្លើយអ្នកទោសនៅគុកទួលស្លែង

តាមការសង្ខេបចម្លើយសារភាពបានបង្ហាញថា ជិន អ៊ា ហៅ ស៊ូ ចូលធ្វើជាភ្នាក់ងារសេ.អ៊ី.អានៅឆ្នាំ១៩៦៣ មាននាទីតាមដានខ្មែរក្រហមនិងរាយការណ៍អំពីសិស្សណាដែលទំនាក់ទំនងជាមួយខ្មែរក្រហម ។ នៅឆ្នាំ១៩៧០ ជិន អ៊ា បានចូលបក្សនៅក្នុងជួរបដិវត្តន៍នៅភូមិភាគបូព៌ា បានទទួលតួនាទីជាប្រធានពាណិជ្ជកម្មតំបន់២២ ។ ក្រោមការដឹកនាំរបស់ “តាភឹម” (សោ ភឹម) លេខាភូមិភាគបូព៌ា ជិន អ៊ា ខិតខំកសាងកម្លាំងក្បត់ក្នុងតំបន់២២ ។ ឆ្នាំ១៩៧១ ជិន អ៊ា បានទទួលនាទីជាប្រធានមន្ទីរស្រុកស្រីសន្ធរ បានរួមសហការជាមួយវៀតណាមចូលរួមរៀបចំផែនការធ្វើរដ្ឋប្រហារដណ្ដើមអំណាចពីខ្មែរក្រហម បំផុសប្រជាជនឲ្យស្អប់បដិវត្តន៍ ។ នៅឆ្នាំ១៩៧៧ ជិនអ៊ា ត្រូវបានអង្គការចាប់ខ្លួនបញ្ជូនមកគុកទួលស្លែង ។

នៅក្នុងសំណៅដើមនៃចម្លើយសារភាពនេះ ជិន អ៊ា សរសេរថា ពីឆ្នាំ១៩៥០ដល់ឆ្នាំ១៩៥៤ ខ្លួនបានមករស់នៅភ្នំពេញជាមួយបងប្រុសឈ្មោះ កុយ ធន់ (កុយ ធួន) ដែលក្រោយមក (ក្នុងរបបខ្មែរក្រហម) ក្លាយជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។ ពីឆ្នាំ១៩៥៥ដល់ឆ្នាំ១៩៥៩ ជិន អ៊ា រៀននៅខេត្តកំពង់ចាមនិងក្រចេះវិញ ។ ឆ្នាំ១៩៦០គាត់ក៏វិលត្រឡប់មករៀននៅវិទ្យាល័យយុគន្ធរនៅភ្នំពេញដែលពេលនោះហើយ ជិន អ៊ា ត្រូវបានបងប្រុសឈ្មោះ កុយ ធន់ (កុយ ធួន) អប់រំអំពីរឿងនយោបាយ ។ ជិន អ៊ា សរសេរក្នុងចម្លើយសារភាពថា “ក្នុងឆ្នាំ១៩៦០ បងរបស់ខ្ញុំបានអប់រំខ្ញុំឲ្យយល់ពីសង្គមមូលធននិយម និងសង្គមកុម្មុយនិស្តនិយម គឺឲ្យខ្ញុំយល់អំពីរបបនៃសង្គមទាំង២នេះ” ។ ពីឆ្នាំ១៩៦២ដល់ឆ្នាំ១៩៦៤ ជិន អ៊ា មករៀននៅវិទ្យាល័យព្រះសីហនុ ក្រុងកំពង់ចាម ។ កុយ ធន់ (កុយ ធួន) ក៏ប្រគល់ ជិន អ៊ា ឲ្យទៅរស់នៅជាមួយឈ្មោះ ទិន គឹមហុង និង គីក គឹមអុន ។ “ជាបន្តបន្ទាប់មកឈ្មោះ ទិន គឹមហុង និង គីក គឹមអុន បានអប់រំខ្ញុំឲ្យស្គាល់របបកុម្មុយនិស្តនិងរបបរបស់លោកសេរីដូចបងប្រុសរបស់ខ្ញុំអប់រំខ្ញុំកាលពីឆ្នាំ១៩៦០ ហើយមកដល់ឆ្នាំ១៩៦៣ ឈ្មោះទាំងពីរនេះក៏បញ្ចូលខ្ញុំទៅក្នុងអង្គការសេ.អ៊ី.អា...” ។

ពីចុងឆ្នាំ១៩៦៤ ដល់ឆ្នាំ១៩៦៨ ជិន អ៊ា បានក្លាយជាគ្រូបង្រៀននៅវិទ្យាល័យឯកជន "ចំរើនវិជ្ជា" ទីក្រុងភ្នំពេញ បានទាក់ទងជាមួយឈ្មោះ សូ សាផន និង តាំង ខែត្រ ដែលធ្វើការនៅវិទ្យាល័យចំរើនវិជ្ជានេះស្រាប់ ។ ក្រៅពីនោះបានស្គាល់បក្ខពួកសេ.អ៊ី.អាចាស់នៅក្នុងសាលានេះចំនួន១១នាក់ទៀត ដែលរួមមានទាំងនាយកសាលាចំរើនវិជ្ជាឈ្មោះ អ៊ុក យឿន និងកសាងបានកម្លាំងថ្មី៣នាក់ទៀត ។ ពាក់កណ្តាលឆ្នាំ១៩៦៨ ជិន អ៊ា ផ្លាស់មកបង្រៀននៅវិទ្យាល័យកម្ពុជបុត្រវិញ ។

បន្ទាប់មក ជិន អ៊ា បានបន្តថា "ពីដើមឆ្នាំ១៩៦៩ រហូតដល់ដើមឆ្នាំ១៩៧០ ខ្ញុំត្រូវជាប់គុកនៅព្រៃស..." ។ នៅក្នុងគុកព្រៃស ជិន អ៊ា ឆ្លៀតកសាងបានកម្លាំង៧នាក់ទៀត ។ ចេញពីគុកនៅឆ្នាំ១៩៧០ ជិន អ៊ា ត្រូវបាន សូ សាផន ចាត់ឲ្យទៅជួបបន្តខ្សែរយៈសេ.អ៊ី.អាជាមួយឈ្មោះ ស៊ាត ឆែ ដែលនៅភូមិភាគបូព៌ា ដោយភ្ជាប់លិខិតមួយច្បាប់ទៅជាមួយផង ។

ជិន អ៊ា សារភាពទៀតថា រហូតដល់ខែ៣ ឆ្នាំ១៩៧១ ទើបគាត់បានជួបនឹង ស៊ាត ឆែ (ដែលបានប្តូរឈ្មោះថា ខឹម) និងបានភ្ជាប់ខ្សែរយៈសេ.អ៊ី.អាជាមួយគ្នា ។ "...រំលងមកបានមួយអាទិត្យ ឈ្មោះ ហេង ក៏បាននាំខ្ញុំដើម្បីទៅជួបជាមួយបង ស៊ាត ឆែ ហៅ ខឹម នៅមន្ទីរធ្វើការរបស់គាត់ នៅភូមិមហាលាភ ឃុំមហាលាភ ស្រុកកោះសូទិន តំបន់២២ ។ ពេលបានជួបបង ស៊ាត ឆែ ហៅ ខឹម ភ្លាម ខ្ញុំក៏ប្រគល់លិខិតដែលឈ្មោះ សូ សាផន បញ្ញើមកនោះជូនគាត់ គាត់ក៏យកលិខិតនោះទៅអានព្រមទាំងធ្វើមុខញញឹម..." ។

ស៊ាត ឆែ ហៅ ខឹម បានឲ្យសំបុត្រ១ច្បាប់ឲ្យ ជិន អ៊ា យកទៅជួបឈ្មោះ ងិន ប្រធានស្រុកស្រីសន្ធរ ដើម្បីចូលធ្វើការងារក្នុងជួរបដិវត្តន៍ ។ ជិន អ៊ា ក៏បានជួបឈ្មោះ ងិន "កន្លះខែក្រោយមក ខ្ញុំក៏បានយកលិខិតដែលបង ខឹម ផ្ញើតាមខ្ញុំនោះទៅជូនបង ងិន ។ ...តាំងពីពេលនោះមក ខ្ញុំក៏បានមករស់នៅជាមួយបង ងិន ដោយធ្វើជាលេខាធិការរបស់គាត់ ។ មួយរយៈក្រោយមក បងងិនបានប្រាប់ខ្ញុំថា បងខឹមជាលេខាតំបន់២២ យើងដូរឈ្មោះគាត់ពី ខឹម មកដាក់ ទុំ វិញ" ។ ធ្វើការជាមួយ ងិន បាន៣ខែ (ពីខែ៤ ដល់ខែ៦ ឆ្នាំ១៩៧១) ជិន អ៊ា និយាយថា ងិន បានចាត់តាំងឲ្យគាត់មកធ្វើជាប្រធានមន្ទីរស្រុកស្រីសន្ធរវិញ ។ "...លុះមកដល់ចុងខែ១១ ឆ្នាំ១៩៧១ បង ងិន បានប្រាប់ខ្ញុំថា បងទុំគាត់ឲ្យរៀបចំប្រដាប់ប្រដាដើម្បីឡើងទៅចូលរួមមហាសន្និបាតភូមិភាគដែលនឹងចាប់ផ្តើមធ្វើនៅថ្ងៃទី២៧ ខែ១១ ឆ្នាំ១៩៧១នេះ... ។ ពេលនោះខ្ញុំក៏សួរបញ្ជាក់ទៅបង ងិន វិញថា តើអ្នកដែលត្រូវទៅគឺមានតែបងទុំនិងខ្ញុំទេឬយ៉ាងណា បងងិនក៏បញ្ជាក់មកខ្ញុំវិញថា អ្នកដែលត្រូវទៅចូលរួមគឺមានលេខាស្រុកទាំងអស់ក្នុងតំបន់ទាំងមូលព្រមទាំងប្រធានក្រសួងមន្ទីរជុំវិញតំបន់និងស្រុកទាំងអស់ " ។ អង្គសន្និបាតប្រព្រឹត្តទៅនៅស្រុកក្រូចឆ្មារ តំបន់២១ ។ "...ថ្ងៃទី២៧ ខែ១១ ឆ្នាំ១៩៧១ សន្និបាតក៏ចាប់ដំណើរការដោយមានបង ភឹម ជាលេខាភូមិភាគបូព៌ាជាអធិបតី ។ បាន១អាទិត្យក្រោយមក សន្និបាតក៏បានបប់សព្វគ្រប់..." ។ ក្នុងឱកាសនៃសន្និបាតនោះ ជិន អ៊ា ក៏បានស្គាល់តាភឹមលេខាភូមិភាគបូព៌ា ។ "...បន្ទាប់មក បងទុំក៏បានខទ្មេសនាមខ្ញុំដើម្បីឲ្យតាភឹមបានស្គាល់..." ។ ជិន អ៊ា បន្តថា "ហើយតាំងពីពេលនោះមកទើបខ្ញុំដឹងថាអ្នកដឹកនាំការងារសម្ងាត់ប្រឆាំងជាមួយពួកខ្មែរក្រហមគឺតាភឹមនេះឯង មិនមែនមានតែបងទុំទេក្នុងភូមិភាគបូព៌ានេះ" ។

នៅចុងខែ៦ ឆ្នាំ១៩៧២ ជិន អ៊ា ទៅចូលរួមប្រជុំពិសេសមួយនៅឯមន្ទីររបស់តាភឹមនៅស្រុកក្រូចឆ្មារ តំបន់២១ ជាមួយនឹង ទុំ ។ "ពេលជួបខ្ញុំ បងទុំក៏បានប្រាប់ខ្ញុំថា ខ្ញុំទទួលលិខិតពីបងភឹមមួយថាឲ្យខ្ញុំទៅចូលរួមប្រជុំពិសេសមួយនៅឯមន្ទីររបស់គាត់នៅស្រុកក្រូចឆ្មារ តំបន់២១ ថ្ងៃទី២២-៦-៧២ កុំបីខាន" ។ អង្គប្រជុំនៅថ្ងៃទី២២ ខែ៦ ឆ្នាំ១៩៧២ ដំណើរការដោយមាន តាភឹម ជាប្រធាន ។ សមាជិកដែលចូលរួមគឺមកពីគ្រប់ស្ថាប័នក្រសួងមន្ទីរនៅភូមិភាគបូព៌ា ។ ខ្លឹមសារប្រជុំនិយាយដដែលៗអំពីការកសាងនិងពង្រីកកម្លាំងត្រៀមដណ្តើមរដ្ឋអំណាចពីពួកខ្មែរក្រហមមកវិញ ។ អង្គប្រជុំបានបញ្ចប់នៅរសៀលថ្ងៃទី២៤ ខែ៦ ឆ្នាំ១៩៧២ ។

នៅក្នុងចម្លើយសារភាព ជិន អ៊ា បាននិយាយអំពីទំនាក់ទំនងរវាង តាភឹម និងកងទ័ពវៀតណាមថា "...បន្តិចនិរសានោះក៏ចេញមកវិញហើយក៏បាននាំវៀតណាមមួយក្រុម

ចូលទៅជួបនឹងតាភីម ។ បន្តិចក្រោយមកខ្ញុំឮសំឡេងតាភីមនិងវៀតណាមជជែកគ្នាហើយយូរៗឮសូរសើចម្តង ។ ...បងទុំបាននិយាយប្រាប់ខ្ញុំថា វៀតណាមដែលមកអំបាញ់មិញនេះគឺមកពិភាក្សាជាមួយតាភីមអំពីផែនការដណ្តើមអំណាចពីពួកខ្មែរក្រហមដែរ ព្រោះកន្លងមកតាភីមបានស្នើឲ្យគេ(វៀតណាម)ជួយ ។ ហើយក្នុងពេលពិភាក្សានោះ ខ្ញុំឮវៀតណាមបានបញ្ជាក់ថាគេរង់ចាំជួយគ្រប់បែបយ៉ាងទាំងអស់ ឲ្យតែតាភីមត្រូវការគេ (វៀតណាម) ទោះបីជាពេលវេលាណាក៏ដោយ... ។ ក្នុងពេលពិភាក្សានោះវៀតណាមបានបញ្ជាក់ថាគេ(វៀតណាម)ពុំសូវសប្បាយជាមួយពួកខ្មែរក្រហមដែរ ព្រោះពួកខ្មែរក្រហមបង្កទំនាស់ជាមួយគេ (វៀតណាម) ច្រើនសន្ធឹកសន្ធាប់ណាស់...» ។ នៅថ្ងៃទី២៩ ខែ៦ ឆ្នាំ១៩៧២ ទុំក៏រៀបចំប្រជុំថ្នាក់ក្រោមដើម្បីផ្សព្វផ្សាយការណែនាំរបស់តាភីមឲ្យកងកម្លាំងទាំងអស់បានដឹង ។ ជិន អ៊ា បន្ថែមថា ក្នុងអង្គប្រជុំនោះឈ្មោះ មុត ងិន ផុន និង ឆន ក៏បានបញ្ជាក់ជូនអង្គប្រជុំវិញថា «ចំពោះប្រជាជនយើងក្នុងពេលនេះមិនថានរណាទេ ភាគច្រើនបំផុតគឺមិនរីករាយចំពោះរដ្ឋអំណាចថ្មីដែលពួកខ្មែរក្រហមគ្រប់គ្រងមកនេះ ។ គេទាំងឡាយមានសំណូមពរថាឲ្យយើងជួយរំដោះគេឲ្យបានឆាប់រហ័សបំផុត ព្រោះបើនៅយូរតទៅទៀតទាំងខ្លួនគេនិងគ្រួសារគេអស់ស្គាល់ហើយការសប្បាយរីករាយ » ។

ជិន អ៊ា សារភាពទៀតថា ក្នុងរយៈពេល២ឆ្នាំដែលខ្លួនធ្វើជាប្រធានសេដ្ឋកិច្ចស្រុកស្រីសន្ធរ (ពីខែ៤ ឆ្នាំ១៩៧២ ដល់ខែ២ ឆ្នាំ១៩៧៤) ខ្លួនកសាងកម្លាំងថ្មីបាន៩នាក់ ។ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៤ ជិន អ៊ា ត្រូវដកឲ្យទៅទទួលភារកិច្ចជាប្រធានពាណិជ្ជកម្មតំបន់២២វិញ ។ ជិន អ៊ា បញ្ជាក់ថាខ្លួនបានខិតខំយកចិត្តទុកដាក់កសាងកម្លាំងសម្ងាត់តទៅទៀត ។ កម្លាំងដែលកសាងបានមានចំនួន២៦នាក់ ។ ចម្លើយសារភាពរបស់ជិន អ៊ា បន្តថា ចាប់ពីចុងឆ្នាំ១៩៧៣ដែលតាភីមចុះមកលេងតំបន់២២ តាភីម និង ទុំ លែងបើកការប្រជុំសម្ងាត់ដែលមានទ្រង់ទ្រាយធំៗទៀតហើយ គ្រាន់តែហៅទៅណែនាំជាលក្ខណៈឯកជនក្នុងមួយខែម្តងប៉ុណ្ណោះ ។ រហូតដល់ថ្ងៃទី២៥ ខែ៥ ឆ្នាំ១៩៧៥ ទើបមានការប្រជុំសម្ងាត់បែបនេះម្តងទៀតនៅស្រុកក្រូចឆ្មារ ក្រោមអធិបតីភាពរបស់តាភីម ។ ក្នុងអង្គប្រជុំនោះមានអ្នកចូលរួមសុទ្ធតែថ្នាក់ដឹកនាំមកពីគ្រប់តំបន់ទាំងអស់ក្នុងភូមិភាគបូព៌ា ។ អង្គប្រជុំមានរបៀបវារៈ៣គឺ÷ ១)ជម្រាបអំពីមូលហេតុនៃការប្រជុំ ២)អំពីគម្រោងផែនការដណ្តើមអំណាចពីពួកកុម្មុយនិស្តក្នុងពេលខាងមុខ និង ៣)វិធានការផ្សេងៗសម្រាប់អនុវត្តពីពេលនេះរហូតដល់ពេលដណ្តើមអំណាច ។ តាមសេចក្តីសារភាពរបស់ ជិន អ៊ា ក្នុងអង្គប្រជុំនេះ តាភីមបានលើកឡើងថា÷ «ដោយសារពេលនេះពួកខ្មែរក្រហមទើបនឹងបានគ្រប់គ្រងអំណាចនៅទូទាំងប្រទេស ដូច្នេះខ្មែរក្រហមច្បាស់ជាជួបនូវឧបសគ្គធំៗពុំខានឡើយ ព្រោះអ្នកគ្រប់គ្រងអំណាចនៅតាមមូលដ្ឋានសុទ្ធតែមានប្រភពមកពីកសិករ ពុំដែលកាន់អំណាចទាល់តែសោះ ។ ម្យ៉ាងទៀតប្រជាជនដែលនៅតំបន់រំដោះជាង៥ឆ្នាំកន្លងទៅនេះ ត្រូវជួបប្រទះនូវឧបសគ្គគ្រប់បែបយ៉ាងតាំងពីការស៊ីចុកស្លៀកពាក់ឡើងទៅ ពេលចប់សង្គ្រាមភ្លាមប្រជាជនគ្មានស្រូវអង្ករមួយគ្រាប់នៅនឹងខ្លួនទេ នេះជាបន្ទុកដែលពួកខ្មែរក្រហមត្រូវដោះស្រាយ បូករួមនឹងបន្ទុកកាន់តែធ្ងន់មួយទៀតគឺប្រជាជនថ្មីដែលជម្លៀសចេញពីទីក្រុងរាប់លាននាក់សុទ្ធតែបាតដៃទទេ ដែលទាមទារឲ្យពួកខ្មែរក្រហមត្រូវតែដោះស្រាយដោយខានពុំបានដែរ ។ ពេលនេះមិនថាឡើយត្រឹមស្រូវអង្ករទេដែលពួកខ្មែរក្រហមដោះស្រាយមិនរួច សូម្បីតែអំបិលដែលជាការចាំបាច់របស់ប្រជាជនខានពុំបានទេនោះក៏ដោះស្រាយពុំរួចដែរ ប្រជាជនខ្លះយកដេះហូបជំនួសអំបិលទៅហើយ ធ្វើឲ្យប្រជាជនកើតជំងឺហើមខ្លួន មួយថ្ងៃៗចូលមន្ទីរពេទ្យរាប់មិនអស់ទេ ។ ...តាមខ្លឹមសារទីពីរយើងនឹងសម្រេចធ្វើការតស៊ូដណ្តើមអំណាចពីពួកខ្មែរក្រហមនៅក្នុងខែ៥ ឆ្នាំ១៩៧៦ខាងមុខនេះ ។ តែមុននឹងឈានទៅដណ្តើមអំណាចឲ្យបានជ័យជំនះ ខ្លឹមសារទីបីកំណត់ឲ្យយើងធ្វើសកម្មភាពមួយចំនួនជាបន្ថែមទៀតចាប់ពេលនេះតទៅ ដើម្បីធ្វើឲ្យពួកខ្មែរក្រហមកាន់តែអំពល់ខ្វល់ខ្វាយឡើងជារៀងរាល់ថ្ងៃ ។ សកម្មភាពដែលត្រូវអនុវត្តគឺត្រូវបំផុសប្រជាជនទាំងចាស់ទាំងថ្មីឲ្យឃើញថាពួកខ្មែរក្រហមគ្មានសមត្ថភាពក្នុងការគ្រប់គ្រងរដ្ឋអំណាចនិងការដោះស្រាយជីវភាពប្រជាជនឡើយ ។ ត្រូវបំផុសឲ្យប្រជាជនឃើញថាពួកខ្មែរក្រហមគាបសង្កត់

បំបិទសិទ្ធិសេរីភាពរបស់ប្រជាជន ទាំងការនិយាយស្តី ដើរហើរ ស៊ីចុក និងការប្រើប្រាស់របស់របរផ្សេងៗ ហើយម្យ៉ាងទៀត របស់របរផ្សេងៗដែលប្រជាជនខិតខំរកយ៉ាងលំបាកលំបិនតាំងពីណាពីណីមកត្រូវពួកខ្មែរក្រហមដកហូតអស់ មិនតែប៉ុណ្ណោះ គេចាប់បង្ខំឲ្យធ្វើពលកម្មរកពេលសម្រាកសឹងតែពុំបាន ។ ជាមួយនេះត្រូវយកចិត្តទុកដាក់បំផុសប្រជាជនឲ្យមើលឃើញអំពីគោលបំណងរបស់យើងក្នុងការវាយដណ្តើមអំណាចពីពួកខ្មែរក្រហមវិញនេះ គឺចង់ឲ្យប្រជាជនបានរស់នៅសុខស្រួលដូចកាលពីដើម មានសិទ្ធិធ្វើជាម្ចាស់លើដីស្រែចម្ការ ផលដំណាំនិងសម្ភារសព្វសារពើរបស់គេ គេរស់នៅជួបជុំគ្រួសារ មានសិទ្ធិស៊ីចុក ដើរហើរ និងប្រើប្រាស់របស់របរទៅតាមចំណង់របស់គេម្នាក់ៗដូចពេលកន្លងមក» ។ សមាជិកអង្គប្រជុំម្នាក់ៗបានឡើងប្តេជ្ញាចិត្តធ្វើតាមការណែនាំរបស់តាភឹមលុះត្រាតែបានសម្រេច ។ មុនពេលបិទអង្គប្រជុំ តាភឹម បានផ្តាំផ្ញើដល់មនុស្សមួយចំនួនដូចជា ឆោម សាវ៉ាត ឈូក និង នង សារឿន ដែលនៅតំបន់ជាប់ព្រំប្រទល់ជាមួយវៀតណាម ត្រូវទាក់ទងសហការជាមួយវៀតណាមឲ្យបានជិតស្និទ្ធបំផុតដើម្បីជាបង្អែកនាពេលខាងមុខ ។ អង្គប្រជុំបានបិទនៅល្ងាចថ្ងៃទី២៦ ខែ៥ ឆ្នាំ១៩៧៥ ។

ចម្លើយសារភាពបានបន្តទៀតថា នៅថ្ងៃទី១០ ខែ៦ ឆ្នាំ១៩៧៥ តាភឹម និង ទុំ បានរៀបចំប្រជុំពិសេសម្តងទៀតនៅក្នុងតំបន់២២ដើម្បីប្រកាសដំណឹងផ្លាស់ ទុំ ចេញពីតំបន់២២ទៅធ្វើការនៅភ្នំពេញនាពេលខាងមុខ ។ មនុស្សសំខាន់ក្នុងតំបន់២២ចំនួន១៥នាក់ត្រូវបានអញ្ជើញចូលរួមក្នុងអង្គប្រជុំសម្ងាត់នេះ ។ ក្នុងឱកាសនេះ តាភឹម ឆ្លៀតលើកយកគោលការណ៍៣ចំណុចដែលបានលើកឡើងកាលពីប្រជុំសម្ងាត់នៅភូមិភាគនោះមកបកស្រាយម្តងទៀត ហើយបានប្រាប់អង្គប្រជុំថា ទុំ ត្រូវអង្គការដកទៅធ្វើការនៅភ្នំពេញនៅខែ៧ ឆ្នាំ១៩៧៥ខាងមុខនេះហើយ ។ ពីពេលនេះទៅមិត្ត មុត ជាអ្នកទទួលខុសត្រូវដឹកនាំធ្វើការងារសម្ងាត់នៅក្នុងតំបន់២២នេះជំនួសវិញ ។ ទុំ ត្រូវទៅធ្វើការនៅភ្នំពេញមែន តែក៏នៅមានភារកិច្ចដឹកនាំធ្វើការជាសម្ងាត់នៅក្នុងតំបន់២២ដដែល គ្រាន់តែមិនបាននៅជាប់លាប់ដូចពីមុន ។ មានចំណារមួយរបស់ ឌុច នៅត្រង់នេះ(ទំព័រ៧០)ថា «មិត្តអ្នកសួរចម្លើយអា ជិន អ៊ា ហៅ ស៊ូ នេះរហូតមកទល់ថ្ងៃនេះក្តាប់សភាពការណ៍អា ទុំ លួចចុះទៅតំបន់២២អត់បានទេ ។ ឌុច ៧-៦-៧៧ » ។

ខែ៧ ឆ្នាំ១៩៧៥ ទុំ ក៏ចេញដំណើរមកធ្វើការនៅភ្នំពេញ ។ ការដឹកនាំការងារនៅតំបន់២២ក៏ប្រគល់ឲ្យឈ្មោះ មុត ទទួលខុសត្រូវវិញ ។ ជិន អ៊ា បញ្ជាក់ថា «...ចាប់តាំងពីពេលនោះមកគឺខ្ញុំបានប្រាស្រ័យទាក់ទងតែជាមួយបងមុតប៉ុណ្ណោះ» ។ ខែ១២ ឆ្នាំ១៩៧៥ ជិន អ៊ា បានជួប ទុំ ក្នុងឱកាសដែល ទុំ ឆ្លៀតចុះទៅតំបន់២២នារសៀលមួយ ដើម្បីជួបកម្លាំងសំខាន់ៗមួយចំនួនរួច ទុំ ក៏ប្រញាប់ប្រញាល់លាត្រឡប់ទៅវិញ ។ ជិន អ៊ា សារភាពទៀតថាបានជួប ទុំ ម្តងទៀតនៅលើកំណាត់ផ្លូវពីស្រុកស៊ីធរកណ្តាលទៅអូររាំងឪ ។ ទុំ បានប្រាប់ពីកាលបរិច្ឆេទធ្វើរដ្ឋប្រហារ ដើម្បីផ្សព្វផ្សាយដល់គ្រប់កម្លាំងទាំងអស់ គឺថ្ងៃទី២៨ ខែ៥ ឆ្នាំ១៩៧៦ ។ «...រួចហើយបងទុំក៏បានប្រាប់មកខ្ញុំវិញថា ...ឥឡូវនេះបង ភឹម គាត់បានបញ្ជាក់ប្រាប់ខ្ញុំថា ពេលវេលាកំណត់ត្រូវធ្វើរដ្ឋប្រហារដើម្បីដណ្តើមរដ្ឋអំណាចពីពួកខ្មែរក្រហមមកវិញនោះគឺខាងលើយើងសម្រេចកំណត់ធ្វើនៅថ្ងៃទី ២៨-៥-៧៦ខាងមុខនេះ...» ។ ដំណឹងនៃកាលបរិច្ឆេទធ្វើរដ្ឋប្រហារត្រូវបានផ្សព្វផ្សាយដល់គ្រប់បណ្តាញទាំងអស់ ស្រាប់តែផែនការនេះត្រូវផ្អាកទៅវិញ ។ ក្នុងចម្លើយសារភាព ជិន អ៊ា សរសេរថា «...ស្រាប់តែមកដល់ថ្ងៃទី២០-៤-៧៦ បងមុតបានអញ្ជើញមកកន្លែងរបស់ខ្ញុំក្នុងសភាពមានការអ៊ឺប្រញាប់ប្រញាល់ ។ ...បងមុតក៏បានបញ្ជាក់ប្រាប់ខ្ញុំថាគាត់ទើបនឹងបានទទួលលិខិតណែនាំរបស់បងទុំ ...ក្នុងលិខិតនេះបងទុំបានបញ្ជាក់ថា ចំពោះផែនការដណ្តើមអំណាចដែលខាងលើយើងកំណត់ធ្វើនៅថ្ងៃ២៨-៥-៧៦នេះ ឥឡូវនេះត្រូវបែកការណ៍ដឹងដល់ពួកខ្មែរក្រហមអស់រលីងទៅហើយ មូលហេតុដោយមានមនុស្សក្បត់នៅក្នុងជួររបស់យើង...មកដល់ឥឡូវនេះពួកយើងមួយចំនួនត្រូវពួកខ្មែរក្រហមចាប់យកទៅបាត់ហើយ មិនដឹងយកទៅកន្លែងណាទេ ហើយក្នុងពេលនេះទៀតពួកខ្មែរក្រហមក៏កំពុងធ្វើការតាមដាននិងស្រាវជ្រាវជាបន្តទៀត. ..ដើម្បីរកអ្នកដឹកនាំធ្វើរដ្ឋប្រហារដណ្តើមអំណាចនិងបក្ខពួកទាំង

*អស់...។ បងទុំបានបញ្ជាក់ថា គាត់ក៏ត្រូវពួកខ្មែរក្រហមតម្រូវឲ្យស្រាវជ្រាវនៅក្នុងជួរយោធាជាទូទៅដែរ...ជាមួយនេះដែរបងទុំបានណែនាំក្នុងលិខិតរបស់គាត់នោះជាបន្ថែមទៀតថា ...ព្រមជាមួយនេះឲ្យបណ្តាមិត្តយើងឈប់ធ្វើសកម្មភាពអ្វីទាំងអស់...លុះត្រាតែមានការណែនាំជាថ្មីទៀត»។*

*ថ្ងៃទី១៥-១៦ ខែ១១ ឆ្នាំ១៩៧៦ មានការប្រជុំពិសេសមួយទៀតនៅមន្ទីរភូមិភាគដែលស្ថិតនៅក្នុងស្រុកក្រូចឆ្មារដោយមានតាភីមជាអ្នកដឹកនាំការប្រជុំ។ នៅក្នុងចម្លើយសារភាពរបស់ ជិន អ៊ា សរសេរថា «...លុះព្រឹកឡើងថ្ងៃទី១៥-១១-៧៦ ...សមាជិកទាំងអស់ក៏បាននាំគ្នាចូលទៅអង្គុយក្នុងកន្លែងប្រជុំដែលស្ថិតនៅក្បែរនោះដែរ ...មួយសន្ទុះក្រោយមកតាភីមក៏បានមកដល់កន្លែងប្រជុំដែរ ហើយគាត់ក៏ចាប់ផ្តើមបើកធ្វើការប្រជុំតែម្តង»។ ខ្លឹមសារប្រជុំគឺ÷ ១) បញ្ជាក់អំពីមូលហេតុនៃរដ្ឋប្រហារមិនបានសម្រេច ២) អំពីផែនការរដ្ឋប្រហារដណ្តើមអំណាចពីខ្មែរក្រហមជាលើកទីពីរ ៣) វិធានការផ្សេងៗសម្រាប់អនុវត្តពីពេលនេះតទៅមុខទៀត។ តាភីមបានលើកចំណុចនីមួយៗមកពន្យល់អង្គប្រជុំយ៉ាងក្បោះក្បាយ។ អំពីកាលបរិច្ឆេទធ្វើរដ្ឋប្រហារលើកទី២ តាភីម បញ្ជាក់ថា «...ខាងលើយើងក៏សម្រេចថាការធ្វើរដ្ឋប្រហារដណ្តើមអំណាចពីបដិវត្តន៍នឹងធ្វើនៅថ្ងៃ ១៧-៤-៧៧ខាងមុខនេះ...»។*

*អង្គប្រជុំដែលមានខ្លឹមសារដូចគ្នានេះមួយទៀតដោយមានឈ្មោះ មុត អនុលេខាតំបន់២២ ជាអ្នកដឹកនាំ បានធ្វើឡើងនៅមន្ទីរសេនាធិការចាស់នៅភូមិទូរីកណ្តាល ស្រុកស្រីសន្ធរ នៅថ្ងៃទី២០ ខែ១១ ឆ្នាំ១៩៧៦។ ជិន អ៊ា សារភាពបន្តថា «មកដល់ថ្ងៃ២០-១១-៧៦ ខ្ញុំក៏បានធ្វើដំណើរទៅដល់មន្ទីរសេនាធិការចាស់ដើម្បីចូលរួមប្រជុំពិសេសតាមការបញ្ជារបស់បង មុត កាលពីពេលមុននោះ»។ បន្ទាប់ពីអង្គប្រជុំផ្សព្វផ្សាយផែនការនេះមក កម្លាំងសេ.អុី.អារបស់ភូមិភាគបូព៌ាក៏បន្តសកម្មភាពឡើងវិញ ហើយ ជិន អ៊ា ក៏ត្រូវចាប់ខ្លួននៅដើមខែ៣ ឆ្នាំ១៩៧៧ និងត្រូវបញ្ជូនមកគុកទួលស្លែង។ នៅទីបញ្ចប់នៃចម្លើយសារភាពរបស់ខ្លួនដែលធ្វើនៅទួលស្លែង ជិន អ៊ា សរសេរថា «ចាប់តាំងពីពេលនោះមកខ្ញុំនិងបណ្តាមិត្តទាំងអស់ក៏ចាប់ផ្តើមបន្តសកម្មភាព...រហូតដល់ដើមខែ៣ ឆ្នាំ១៩៧៧ ខ្ញុំក៏ត្រូវអង្គការឃាត់ខ្លួនហើយឃុំឃាំងរហូតមកដល់សព្វថ្ងៃនេះ»។*

*តាមរយៈកាលបរិច្ឆេទដែលមាននៅលើចម្លើយសារភាពរបស់ ជិន អ៊ា បង្ហាញថា ជិន អ៊ា ត្រូវបានសួរចម្លើយនៅក្នុងគុកទួលស្លែងអស់រយៈពេល២០ថ្ងៃ គឺពីថ្ងៃទី១៤ ដល់ថ្ងៃទី២៦ ខែ៥ ឆ្នាំ១៩៧៧។ ចម្លើយសារភាពត្រូវបាន ជិន អ៊ា សរសេរដោយផ្ទាល់ដៃមានចំនួន១១៦ទំព័រ។ នៅទំព័រខាងមុខនៃចម្លើយសារភាពមានបញ្ជាក់ថា «ចម្លើយ ជិន អ៊ា ហៅ ស៊ូ លើកទី៣ អំពីប្រវត្តិសកម្មភាពរបស់ ជិន អ៊ា ហៅ ស៊ូ ផ្ទាល់»។ នៅទំព័រខាងមុខដដែលនេះ មានអក្សរ«ស»(សម្ងាត់) ដែលសរសេរដោយដៃនៅក្នុងស៊ុមមួយនិងមានចំណារថា «ជូនអ.ក (អង្គការ) ហើយ ២៧-៧-៧៧»។ ទំព័របន្ទាប់ជាកំណត់ហេតុរបស់អ្នកសួរចម្លើយឈ្មោះ ណាន សរសេរនៅថ្ងៃទី៤ ខែ៦ ឆ្នាំ១៩៧៧ រាយការណ៍ជូនទៅថ្នាក់លើអំពីការសួរចម្លើយ ជិន អ៊ា ដែលមានចំណុចខ្លះគួរឲ្យចាប់អារម្មណ៍ៈ «...ក្រោយមកខ្ញុំក៏ធ្វើទារុណកម្មវាមួយសាហើយក៏វាមិនព្រមនិយាយ... បន្ទាប់មកខ្ញុំធ្វើទារុណកម្មមួយសាទៀតបានវានិយាយ កុយ ធួន-យ៉ា ខ្ញុំធ្វើទារុណកម្មមួយសាទៀតបានវានិយាយតាភីម...»។ ទំព័របន្តទៀតចំនួន៩សន្លឹកជាបញ្ជីឈ្មោះមនុស្សចំនួន៩២នាក់ដែល ជិន អ៊ា សារភាពថាបានរួមសកម្មភាពក្បត់ជាមួយខ្លួន ត្រូវបានចែកតាមផ្នែកដាច់ពីគ្នាមាន÷ ផ្នែកខាងភូមិភាគបូព៌ា១៦នាក់ ផ្នែកខាងតំបន់២២ចំនួន១៥នាក់ បក្ខពួកដែលស្គាល់នៅវិទ្យាល័យចំរើនវិជ្ជា១១នាក់ បក្ខពួកដែលស្គាល់នៅវិទ្យាល័យកម្ពុជបុត្រ ៣នាក់ បក្ខពួកកាលនៅជាប់គុក៧នាក់ បក្ខពួកនៅកំពង់ចាម ២នាក់ និងកម្លាំងដែលកសាងបានចំនួន៣៨នាក់។*

**សាន់ កល្យាណ**

## ទ្រឹស្តីខ្មែរក្រហម

- ◆ដាំទឹកឱ្យពុះចាក់ចូលប្រហុកទើបឃើញដង្កូវ។
- ◆កញ្ច្រែងរវែងយកតែដើមអង្ករ។

# រណ្តៅសាកសពប្រល័យពូជសាសន៍នៅខេត្តបន្ទាយមានជ័យ

## ១) ចម្ការខ្នុរ

ក្រុមធ្វើផែនទីរណ្តៅប្រល័យពូជសាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅខេត្តបន្ទាយមានជ័យជាថ្មីម្តងទៀតនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៨ វេលាម៉ោង១២ និង ៥៥នាទី ។ ក្រុមស្រាវជ្រាវនេះបានចុះទៅទីតាំងសម្លាប់នៅចម្ការខ្នុរដដែល និងរកបានសាក្សីថ្មីៗជាច្រើននាក់ ។

ទីតាំងគុកសន្តិសុខនិងកន្លែងសម្លាប់ "ចម្ការខ្នុរ" ស្ថិតនៅក្នុងភូមិអូរអំបិល ឃុំអូរអំបិល ស្រុកស៊ីសុផុន ខេត្តបន្ទាយមានជ័យ ។ ទីតាំងនេះនៅក្រោយវត្តគិរីជុំ មានផ្ទៃដី១ហិកតា រាងការ៉េ នៅចន្លោះភ្នំកូនខ្លា ភ្នំស្វាយ និងភ្នំជញ្ជាំង ។ បច្ចុប្បន្នទីនេះជាចម្ការរបស់អ្នកស្រុក ។ យោងតាមផែនទីនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យដែលបោះពុម្ពឆ្នាំ១៩៧៦ ទីតាំង "ចម្ការខ្នុរ" នេះស្ថិតក្នុងតំបន់៣ ភូមិភាគពាយ័ព្យ ។ ប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោក (Global Positioning System) បានបង្ហាញថា ទីតាំងនេះស្ថិតនៅត្រង់ចំណុចប្រសព្វរវាងខ្សែស្រប១៣º៣៥'២៨៤" និងខ្សែបណ្តោយ១០៣º៥៦'២៥៨២" ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនេះត្រូវបានកំណត់ទុកក្នុងឧបករណ៍អេឡិចត្រូនិក ឯកសារលេខ R០៨១៩០៥A សម្រាប់បំលែងទៅជាចំណុចទីតាំងរណ្តៅផែនទីប្រល័យពូជសាសន៍នៅកម្ពុជា ។

ព្រះតេជគុណ សៀន ញាណ ព្រះជន្ម៦៩ព្រះវស្សា ជាព្រះគ្រូសូត្រនៅវត្តសុភមង្គល បានមានពុទ្ធដីកាថា នៅក្នុងវត្តចម្ការខ្នុរនេះមានការសម្លាប់មនុស្សទាំងខ្សែៗ ។ ប្រភេទជនរងគ្រោះនៅទីនេះមានលាយចម្រុះគ្នា ប៉ុន្តែភាគច្រើនគឺជាជនជាតិវៀតណាមដែលបានមករស់នៅប្រទេសកម្ពុជាតាំងពីយូរណាស់មកហើយ ។ ជនជាតិចិន ចាម និងឡាវ ក៏មានស្លាប់នៅទីនេះដែរ ។ ព្រះតេជគុណ សៀន ញាណ បានប៉ាន់ស្មានថាមានមនុស្សប្រហែលពី ៤០០០ ទៅ ៥០០០នាក់ បានស្លាប់នៅទីតាំងចម្ការខ្នុរនេះ ។ ចំពោះអដ្ឋិធាតុជនរងគ្រោះវិញត្រូវបានប្រជាជនក្នុងស្រុកជីកកកាយរកមាសក្រោយឆ្នាំ១៩៧៩រួចមិនលុបដីវិញ ធ្វើឲ្យផ្ទៃដីស្ថិតនៅរណ្ដូករណ្ដែលពេញដី ។ ព្រះតេជគុណ សៀន ញាណ ជាអ្នកដឹកនាំប្រជាជនក្នុងភូមិទៅជីកយកមកតម្កល់នៅក្នុងបូជនីយដ្ឋាននាវត្តសុភមង្គលដែលស្ថិតនៅក្នុងភូមិអូរអំបិល ឃុំអូរអំបិលនេះដែរ ។ ព្រះតេជគុណបានបន្ថែមថា ការសម្លាប់មនុស្សនៅចម្ការខ្នុរនេះគឺចាប់ផ្តើមនៅឆ្នាំ១៩៧៦ ហើយបន្តរហូតដល់ចុងឆ្នាំ១៩៧៨ ។


សោម ឡាង

លោក សោម ឡាង អាយុ៦៣ឆ្នាំ គណៈកម្មការវត្តសុភមង្គល គឺជាអ្នកដែលបានទៅមើលប្រជាជនជីករកមាសនៅរណ្តៅសាកសពជនរងគ្រោះនៅចម្ការខ្នុរនៅក្រោយឆ្នាំ១៩៧៩ ។ លោកបានបញ្ជាក់ថា រណ្តៅដែលធំបំផុតមានទទឹង៥ម៉ែត្រ បណ្តោយ២០០ម៉ែត្រ និងជម្រៅ១ម៉ែត្រ ។ ក្រៅពីនេះមានរណ្តៅបន្ទាប់បន្សំមួយចំនួនទៀតដែលមានទំហំ៤ម៉ែត្រការ៉េ ។ លោក សោម ឡាង ប៉ាន់ស្មានថា សាកសពដែលស្លាប់នៅចម្ការខ្នុរអាចមានចំនួនដល់រាប់ពាន់នាក់ ព្រោះគ្រាន់តែរណ្តៅធំមួយលោកគិតថាអាចមានមនុស្សស្លាប់លើសពី៥០០នាក់ឯណោះ ។

បច្ចុប្បន្នអដ្ឋិធាតុជនរងគ្រោះនៅចម្ការខ្នុរត្រូវបានតម្កល់នៅក្នុងបូជនីយដ្ឋានមួយនាវត្តសុភមង្គលសម្រាប់ធ្វើបុណ្យរំឭកការឈឺចាប់ចំពោះពួកខ្មែរក្រហម ។

## ២) ស្រុកភ្នំស្រុក

នៅស្រុកភ្នំស្រុកនេះមានទីតាំងគុកសន្តិសុខដ៏ធំមួយគឺត្រង់កន្លែងសាលាស្រុកបច្ចុប្បន្ននេះតែម្តង ។ ទីតាំងគុកសន្តិសុខនេះស្ថិតនៅក្នុងតំបន់៥ យោងតាមផែនទីនយោបាយរបបកម្ពុជាប្រជាធិបតេយ្យបោះពុម្ពឆ្នាំ១៩៧៦ ។ ទីតាំងគុកនេះស្ថិតនៅត្រង់ចំណុចប្រសព្វរវាងខ្សែស្រប១៣º៤៨'៣២០៣" និងខ្សែបណ្តោយ ១០៣º២០'០៧៦៧" តាមប្រព័ន្ធកំណត់ទីតាំង

ភូមិសាស្ត្រពិភពលោក ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនៃទីតាំងប្រល័យពូជសាសន៍នេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិក ឯកសារលេខ R០៨២០០៣A ។ ក្រុមធ្វើផែនទីនៃមជ្ឈមណ្ឌលឯកសារបានចុះទៅដល់ទីតាំងគុកនៅស្រុកភ្នំស្រុកនេះនៅវេលាម៉ោង១០និង២០នាទី ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៨ ។

លោក គង់ លឿ អភិបាលស្រុកភ្នំស្រុក បានរាយការណ៍ថា ទីតាំងសាលាស្រុកនេះជាអតីតមន្ទីរសន្តិសុខនាសម័យប៉ុលពត ។ ប្រភេទមនុស្សដែលជាប់នៅទីនេះមានលាយចម្រុះគ្នាដែលត្រូវបានប្រមូលមកពីគ្រប់ឃុំទូទាំងស្រុកនេះ ។ លោកបន្តថា ជនរងគ្រោះទាំងអស់ត្រូវបានខ្មែរក្រហមកោះឲ្យមកប្រជុំនៅវត្តជ័យឧត្តមដើម្បីស្រាវជ្រាវរកមនុស្សដែលមានចំណេះដឹងបញ្ញវន្ត មន្ត្រីរាជការ ដោយសន្យាថា“អនុញ្ញាតឲ្យអ្នកទាំងនោះវិលទៅបំពេញការងាររដ្ឋដូចដើមវិញ” ។ ប៉ុន្តែជនរងគ្រោះទាំងនោះត្រូវបានពួកខ្មែរក្រហមដឹកយកទៅសម្លាប់ចោលទាំងអស់នៅស្ពានត្បែង ក្នុងភូមិព្រៃមាន់ ឃុំរហាល ស្រុកព្រះនេត្រព្រះ ។ ហេតុការណ៍សម្លាប់មនុស្សនេះកើតឡើងនៅអំឡុងឆ្នាំ១៩៧៥-៧៦ ។ អ៊ីស្រី ឆាយ រិន បច្ចុប្បន្នរស់នៅភ្នំពេញ មានប្រសាសន៍ថាក្នុងដំណើរវិលត្រឡប់មកភ្នំពេញវិញកាលពីឆ្នាំ១៩៧៩ អ៊ីបានដើរកាត់ទីតាំងសម្លាប់មនុស្សនៅត្រង់ដើមពោធិបីដើមក្នុងភូមិព្រៃមាន់នេះ បានឃើញសាកសពយ៉ាងច្រើននៅទីនោះ ។ អ៊ីស្រីបន្ថែមថា ស្រុកភ្នំស្រុកជាកន្លែងដែលដាក់អ្នកជម្លៀសពីភ្នំពេញទៅ សុទ្ធតែជាមុខសញ្ញាដែលត្រូវសម្លាប់ ហើយអ្នកទាំងនោះរស់នៅវេទនាណាស់ ។


ឈុំ រួម

លោក ឈុំ រួម អាយុ៥០ឆ្នាំ អភិបាលរងស្រុកភ្នំស្រុក ក៏ជាមនុស្សម្នាក់ក្នុងចំណោមប្រជាជនដែលត្រូវបានពួកខ្មែរក្រហមហៅឲ្យទៅជួបប្រជុំនៅវត្តជ័យឧត្តមដែរ ។ លោកមានប្រសាសន៍ថា ពួកខ្មែរក្រហមបោកប្រាស់ប្រជាជនថាឲ្យទៅទទួលសម្តេចឪ ។ នៅលើកទី២ពួកខ្មែរក្រហមបោកប្រាស់ថាឲ្យត្រឡប់ទៅធ្វើការតាមតួនាទីចាស់វិញ ។ តែមនុស្សទាំងអស់ត្រូវពួកខ្មែរក្រហមយកទៅសម្លាប់នៅភូមិព្រៃមាន់អស់ ចំណែករូបលោកបានរួចជីវិតដោយសារអ្នកមូលដ្ឋានម្នាក់ជួយ ។ លោក ឈុំ រួម បានបន្ថែមថា មានតំណាងរាស្ត្រសម័យសាធារណរដ្ឋខ្មែរម្នាក់ឈ្មោះ ជួ ផុត ក៏មកជាប់ឃុំឃាំងនៅទីនេះដែរ ហើយត្រូវបានពួកខ្មែរក្រហមយកទៅសម្លាប់ចោលនៅដើមត្រមែង ស្ថិតក្នុងភូមិស្រះជីក ឃុំស្រះជីក ស្រុកភ្នំស្រុកនេះ ។

## ៣) ព្រៃគោកគ្រោច

ព្រៃគោកគ្រោចជាទីតាំងសម្លាប់ដ៏ធំមួយស្ថិតក្នុងឃុំគោកគ្រោច ស្រុកភ្នំស្រុក មានចម្ងាយ១៥០០ម៉ែត្រពីសាលាស្រុកភ្នំស្រុក ។ តាមផែនទីនយោបាយរបបកម្ពុជាប្រជាធិបតេយ្យបោះពុម្ពឆ្នាំ១៩៧៦ ទីតាំងព្រៃគោកគ្រោចនេះស្ថិតនៅក្នុងតំបន់៥ ។ នៅទីនេះមានដើមពោធិ៍មួយដើមសម្គាល់ថាជាកន្លែងសម្លាប់រង្គាលនាសម័យនោះ ។ តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោក ទីតាំងសម្លាប់មនុស្សនេះស្ថិតនៅត្រង់ចំណុចប្រសព្វរវាងខ្សែស្រប១៣°៤៤'៤៥៩៧” និងខ្សែបណ្តោយ១០៣°១៩'៤៣០៧” ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនៃទីតាំងប្រល័យពូជសាសន៍នេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិក ឯកសារលេខ R០៨២០០៥A ។ ក្រុមធ្វើផែនទីរណ្តៅប្រល័យពូជសាសន៍បានទៅដល់ទីតាំងនេះនៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៨ ។

លោកយាយ ថន រស់នៅភូមិប៉ោយស្នួល ឃុំប៉ោយចារ ស្រុកភ្នំស្រុក បានប្រាប់យើងថា លោកយាយបានឃើញខ្មែរក្រហមបណ្តើរមនុស្សយកទៅសម្លាប់នៅព្រៃគោកគ្រោចយ៉ាងជាក់ស្តែង ។ លោកយាយមានប្រសាសន៍ថា នៅរៀងរាល់២ថ្ងៃម្តង ពួកខ្មែរក្រហមចាប់មនុស្សចងបណ្តើរមកសម្លាប់ចោលនៅព្រៃគោកគ្រោចនេះ ។ បណ្តើរម្តងៗមាន២ខ្សែ ១ខ្សែមានជនរងគ្រោះប្រហែល១០នាក់ ។ លោកយាយបញ្ជាក់ថាការសម្លាប់ពេលនោះគឺមានខ្លះត្រូវសម្លាប់ទាំងគ្រួសារតែម្តង ។ លោកយាយមិនអាចប៉ាន់ស្មានពីចំនួនមនុស្សដែលបានស្លាប់នៅព្រៃគោកគ្រោចនេះបានទេ តែលោកយាយបញ្ជាក់ថាមានចំនួនច្រើនណាស់ ។

លោក ឈុំ រួម បានបន្ថែមថា នៅព្រៃគោកគ្រោចនេះគ្មានលក្ខណៈជារណ្តៅសាកសពទេ ព្រោះពេលនោះពួកខ្មែរក្រហម

គ្រាន់តែវាយសម្លាប់ចោលៗប៉ុណ្ណោះ មិនមានដីករណ្តៅកប់ទេ ។ អ៊ីស្រី ឆាយ រិន ក៏បានបន្ថែមថាព្រៃគោកត្រាចនេះមានសាកសពច្រើនដែរកាលដែលអ៊ីដើរកាត់តាមនេះនៅឆ្នាំ១៩៧៩ ។ ទាក់ទងនឹងការសម្លាប់មនុស្សនៅព្រៃគោកត្រាចនេះ លោក គាត់ ឈឿម នៅភូមិប៉ោយស្នួល ឃុំប៉ោយចារ បានអះអាងថា ក្រោយឆ្នាំ១៩៧៩ គាត់ដើរទៅដកសំណាបកាត់តាមព្រៃគោកត្រាចនេះ គាត់បានឃើញសាកសព ឃើញខ្សែក្រវាត់ ខ្សែចងដៃ ក្រណាត់ចងមុខ ។ល ។ ក្រៅពីនោះប្រជាជនដែលធ្វើស្រែនៅគោកត្រាចនេះបានប៉ះឆ្អឹងខ្មោចនៅពេលភ្ជួរដីធ្វើស្រែ ។ លោកបញ្ជាក់ថា ព្រៃដែលពួកខ្មែរក្រហមយកមនុស្សទៅសម្លាប់នោះមានចម្ងាយតែកន្លះគីឡូម៉ែត្រពីផ្លូវតែប៉ុណ្ណោះ ។ ជនរងគ្រោះទាំងអ្នកមូលដ្ឋាន ទាំងអ្នកជម្លៀស ឲ្យតែធ្វើខុសសុទ្ធតែត្រូវយកទៅសម្លាប់ចោលនៅទីនោះទាំងអស់ ។

## ៤) អាងទឹកត្រពាំងថ្ម

អាងទឹកត្រពាំងថ្មគឺជាកន្លែងសម្លាប់ដ៏ធំមួយទៀតស្ថិតនៅក្នុងភូមិត្រពាំងថ្មកណ្តាល ឃុំប៉ោយចារ ស្រុកភ្នំស្រុក មានចម្ងាយ៥គីឡូម៉ែត្រនិង៩០០ម៉ែត្រពីសាលាស្រុក ។ អាងនេះចាប់ផ្តើមជីកនៅឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៦ ។ អាងទឹកត្រពាំងថ្មមានបណ្តោយ១០គីឡូម៉ែត្រ និងទទឹង៧គីឡូម៉ែត្រ អាចផ្ទុកទឹកបានចំនួន៧លានម៉ែត្រគូប សម្រាប់ធ្វើស្រែប្រាំងក្នុងស្រុកពីរគឺស្រុកព្រះនេត្រព្រះនិងស្រុកភ្នំស្រុក ។ លោកអភិបាលរងស្រុកភ្នំស្រុកមានប្រសាសន៍ថា ពួកខ្មែរក្រហមប្រមូលប្រជាជនមកពីគ្រប់ស្រុកក្នុងតំបន់៥ មានស្រុកថ្មពួក សេរីសោភ័ណស្រុកព្រះនេត្រព្រះ និងប្រជាជនជម្លៀសមកពីភ្នំពេញផងមកជីកអាងនេះ ។


អាងទឹកត្រពាំងថ្ម

តំបន់អាងទឹកត្រពាំងថ្មស្ថិតនៅក្នុងតំបន់៥ យោងតាមផែនទីភូមិសាស្ត្របបកម្ពុជាប្រជាធិបតេយ្យបោះពុម្ពឆ្នាំ១៩៧៦ ។ ទីតាំងសម្លាប់មួយនេះស្ថិតនៅត្រង់ចំណុចប្រសព្វរវាងខ្សែស្រប ១៣°៤៧'០២២" និងខ្សែបណ្តោយ១០៣°១៨'១៨៥២" យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោក ។ ទិន្នន័យចំណុចទីតាំងភូមិសាស្ត្រនៃទីតាំងប្រល័យពូជសាសន៍នេះត្រូវបានថតទុកក្នុងឧបករណ៍អេឡិចត្រូនិក ឯកសារលេខ R០៨២០០៨A ។

លោក គាន់ មិញ អាយុ៣៩ឆ្នាំ ជាអ្នកដែលបានចូលរួមជីកអាងទឹកត្រពាំងថ្មនេះអស់រយៈពេលជាង១ខែ បានអះអាងថា មានមនុស្សស្លាប់នៅអាងទឹកនេះរាប់ពាន់នាក់ រួមទាំងការសម្លាប់ ការអត់ឃ្លាន និងធ្វើការបាក់កម្លាំងផង ។ អ្នកស្លាប់នៅទីនេះគ្មានយកមកពីក្រៅឯណាទេ គឺអ្នកដែលចូលរួមជីកអាងនេះតែម្តងដែលត្រូវយកទៅសម្លាប់ដោយសារតែមានកំហុសបន្តិចបន្តួចដូចជា ធ្វើមិនគ្រប់ផែនការ ធ្វើឲ្យបាក់ដងចប បាក់ដងរែក ។ល ។ ពួកខ្មែរក្រហមដាក់កម្រិតឲ្យជីកដីក្នុងម្នាក់២ម៉ែត្រគូបក្នុងមួយថ្ងៃ ។ អ្នកខ្លះធ្វើមិនគ្រប់ផែនការក៏ត្រូវសម្លាប់ ខ្លះប្រឹងធ្វើទាល់តែបាក់កម្លាំងស្លាប់ ខ្លះទៀតស្លាប់ដោយសារតែហូបមិនគ្រប់គ្រាន់ ។ លោក គាន់ មិញ បញ្ជាក់ថា រណ្តៅសាកសពនៅឃ្លាតពីអាងបន្តិចតែប៉ុណ្ណោះ ជនរងគ្រោះខ្លះត្រូវកប់នៅជើងទំនប់នេះតែម្តង សូម្បីតែនៅបាតអាងនេះក៏មានរណ្តៅសាកសពដែរ ។ អ៊ីស្រី ឆាយ រិន ក៏បាន បញ្ជាក់ថាមានការសម្លាប់មនុស្សច្រើននៅអាងទឹកត្រពាំងថ្មនេះដែរ ។ រូបអ៊ីនិងកូនក៏ត្រូវពួកខ្មែរក្រហមយកទៅសម្លាប់ដែរ តែមិនស្លាប់ ។

អដ្ឋិធាតុដែលប្រមូលមកពីទីតាំងសម្លាប់នានានៅទូទាំងស្រុកភ្នំស្រុក ត្រូវបានយកមកតម្កល់ទុកនៅស្តូបមួយនៅវត្តកណ្តាលដែលមានចម្ងាយប្រមាណ៥០០ម៉ែត្រពីទីរួមស្រុកភ្នំស្រុក ស្ថិតនៅក្នុងភូមិស្រះឈូក ឃុំស្រះជីក ស្រុកភ្នំស្រុក ។

**សាន់ កល្យាណ**

# ខួបឆ្នាំទី២៥នៃកំណើតបក្សកុម្មុយនិស្តកម្ពុជា

## ញត្តិរបស់យុវជនយុវនារីបដិវត្តជូនពរបក្ស

(កត់ត្រាតាមសំណៅដើមទាំងស្រុង)





សួន ធឿន

ថ្ងៃ៣០ កញ្ញា ឆ្នាំ១៩៧៦នេះ ជាថ្ងៃខួបកំណើតឆ្នាំទី២៥ នៃបក្សកុម្មុយនិស្តកម្ពុជាដ៏រុងរឿង។ ថ្ងៃនេះប្រជាជនកម្ពុជាទាំងមូល កងទ័ពបដិវត្តកម្ពុជាទាំងមូល និងយុទ្ធជន យុទ្ធនារី កម្មាភិបាលបដិវត្តគ្រប់ប្រភេទទាំងអស់ ប្រារព្ធបុណ្យខួបកំណើតឆ្នាំទី២៥នៃបក្សកុម្មុយនិស្តកម្ពុជាយើងក្នុងបរិយាកាសមហាសាមគ្គីជាតិទាំងមូល និងសប្បាយរីករាយក្នុងការទទួលជ័យជំនះធំៗថ្មីៗទៀតក្នុងការកិច្ចបដិវត្តថ្មី ការពារប្រទេស កសាងប្រទេសតាមទិសនៃបដិវត្តន៍សង្គមនិយមនិងការកសាងសង្គមនិយមរបស់បក្ស។ យើងធ្វើបុណ្យទទួលអំណរខួបទី២៥នៃកំណើតបក្សកុម្មុយនិស្តកម្ពុជាយើងក្នុងឆ្នាំនេះ ម្យ៉ាងដើម្បីរំលឹកគុណូបការៈដ៏ធំធេងរបស់បក្សដែលបានដឹកនាំយើងរាល់គ្នាធ្វើបដិវត្តន៍វាយបណ្តេញចក្រពត្តិអាមេរិកនិងបរិវារ រំដោះប្រជាជននិងរំដោះខ្លួនប្រកបដោយជោគជ័យទាំងស្រុងនិងជាស្ថាពរ។ តែម្យ៉ាងទៀតក៏ដើម្បីរៀនសូត្រនូវគំរូលះបង់ គំរូវីរភាពបដិវត្ត គំរូប្រយុទ្ធស្រួចស្រាល់ដាច់ខាតរបស់បក្ស គឺរៀនសូត្រនូវគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯង ដែលជាប្រពៃណីរុងរឿងរបស់បក្សតាំងពីដើមរៀងរហូតមក។

ចាប់តាំងពីពេលបដិសន្ធិក្លាមមក (៣០-៩-១៩៥១) បក្សកុម្មុយនិស្តកម្ពុជាយើងបានដឹកនាំប្រជាជននិងយុវជនយុវនារីកម្ពុជាធ្វើការតស៊ូអាវុធ វាយបណ្តេញអាណានិគមនិយមបារាំងឲ្យចេញអស់ពីទឹកដីកម្ពុជានៅឆ្នាំ១៩៥៤។

នៅឆ្នាំ១៩៥៥ បក្សកុម្មុយនិស្តកម្ពុជាយើងទើបតែមានអាយុត្រឹម៥ឆ្នាំប៉ុណ្ណោះ បក្សត្រូវដឹកនាំប្រជាជាតិ ប្រជាជន និងយុវជនយុវនារីកម្ពុជាធ្វើការតស៊ូនយោបាយប្រឆាំងនឹងការជ្រៀតជ្រែកឈ្លានពានវិទ្ធង្សនារបស់ចក្រពត្តិអាមេរិកនិងបរិវារ ដើម្បីការពារឯករាជ្យនៃប្រទេសយើងផង ហើយតស៊ូទាមទារសិទ្ធិសេរីភាពប្រជាធិបតេយ្យប្រឆាំងនឹងការរឹបជាន់ឆក់ប្លន់យ៉ាងឃោរឃៅហ្វាស៊ីសរបស់ពួកវណ្ណៈកាន់អំណាច ជាសក្តិភូមិ នាយទុន ប្រតិកិរិយា នៅក្នុងប្រទេសផង។ បក្សកុម្មុយនិស្តកម្ពុជាយើងបានដឹកនាំប្រជាជនយុវជនយុវនារីកម្ពុជា ធ្វើការតស៊ូនយោបាយក្នុងរយៈពេល ១៣ឆ្នាំ (៥៥-៦៧) ដោយឆ្លងកាត់សភាពការណ៍ស្មុគស្មាញបត់បែនច្រើនរាប់មិនអស់។ បក្សយើងបានដឹកនាំការតស៊ូបដិវត្តនេះតាំងពីបាតដៃទទេ។ ពោលគឺយើងគ្មានអ្វីទាំងអស់ មាគ៌ាជាយុទ្ធសាស្ត្រ-យុទ្ធវិធីក៏ពុំទាន់មាន លក្ខន្តិកៈបក្សក៏មិនទាន់មាន សេដ្ឋកិច្ចឧបត្ថម្ភខ្លួនក៏មិនទាន់មាន កងទ័ពក៏មិនទាន់មាន។ ដូច្នេះបក្សមានតែបាតដៃទទេនិងគោលជំហរបម្រើប្រជាជន គោលជំហរប្រយុទ្ធដាច់ខាតជាមួយខ្មាំង ទាំងខ្មាំងសត្រូវប្រជាជាតិ ទាំងខ្មាំងសត្រូវវណ្ណៈ ដោយគ្មានរាថយនិងគ្មានសម្រុះសម្រួលឡើយ។ ក្នុងរយៈកាលដំបូងនេះបក្សបានពុះពារគ្រប់ឧបសគ្គនិងការលំបាកវេទនាសព្វបែបយ៉ាង ដោយធ្វើពលិកម្មកម្រិតខ្ពស់បំផុតធ្វើការឃោសនាអប់រំប្រជាជន យុវជនយុវនារីកម្ពុជាយើងផង

បំផុសបំផុលមហាជនឲ្យក្រោកឡើងធ្វើការតស៊ូបដិវត្តផង ដឹកនាំចលនាតស៊ូយ៉ាងអង់អាចក្លាហានដោយផ្ទាល់ផង ហើយកសាងពង្រឹងពង្រីកខ្លួននៅក្នុងចលនាបដិវត្តន៍របស់មហាជននេះផង ។

រហូតដល់ឆ្នាំ១៩៦០ទើបបក្សប្រយុទ្ធកសាងបានដោយឯករាជ្យម្ចាស់ការនូវមាគ៌ាជាយុទ្ធសាស្ត្រ និងមាគ៌ាជាយុទ្ធវិធីសម្រាប់ជាត្រីវិស័យ ឬជាប្រទីបទ្រោលបំភ្លឺផ្លូវក្នុងការតស៊ូបដិវត្តតទៅមុខទៀត ព្រមទាំងប្រយុទ្ធកសាងបាននូវលក្ខន្តិកៈរបស់បក្ស ។ ឈរលើលក្ខណ៍ការជាមូលដ្ឋាននៃលក្ខន្តិកៈរបស់បក្សនេះ និងឈរយ៉ាងរឹងមាំលើមាគ៌ាជាយុទ្ធសាស្ត្រនិងជាយុទ្ធវិធីដែលកសាងបានដោយឈាមស្រស់របស់ប្រជាជនយុទ្ធជនយុទ្ធនារី និងកម្មាភិបាលរបស់បក្សច្រើនឥតគណនា បក្សបានបន្តដឹកនាំចលនាតស៊ូនយោបាយនេះរហូតដល់ឆ្នាំ១៩៦៧ ហើយផ្តើមបានជោគជ័យធំៗជាបន្តបន្ទាប់ ។ មានការវាយបំបែកផែនការធ្វើរដ្ឋប្រហារយោធាផែនការធ្វើរដ្ឋប្រហារដណ្តើមអំណាចដោយស្របច្បាប់ដោយសន្តិវិធីរបស់ចក្រពត្តិអាមេរិកនិងបរិវារជាច្រើនលើក ការទាត់ចោលជំនួយសេដ្ឋកិច្ចដ៏មានពិសពុលរបស់ចក្រពត្តិអាមេរិក ការវាយបណ្តេញស្ថានទូតអាមេរិកនិងស្ថានទូតនៃប្រទេសជាបរិវារចេញអស់ពីប្រទេសកម្ពុជាជាដើម ហើយរក្សាការពារឯករាជ្យសន្តិភាព អព្យាក្រឹតនៃកម្ពុជាបានជារៀងរហូតមក ។

ឆ្នាំ១៩៦៨-៦៩ បក្សបានដឹកនាំប្រជាជននិងយុវជនយុវនារីកម្ពុជាធ្វើការតស៊ូអាវុធរួមផ្សំនយោបាយដើម្បីទប់ទល់និងវាយកម្ចាត់សង្គ្រាមផ្ទៃក្នុងដ៏សាហាវឃោរឃៅហ្វាស៊ីសដែលចក្រពត្តិអាមេរិកនិងបរិវារវាបង្កឡើងនៅប្រទេសកម្ពុជាយើង ។ រយៈកាលនេះជារយៈកាលតឹងតែងបំផុត ស្មុគស្មាញបំផុតទាំងនៅក្នុងប្រទេសក៏ដូចជានៅលើឆាកអន្តរជាតិ ។ ដូច្នេះជារយៈកាលលំបាកវេទនាបំផុតដែលទាមទារនូវគោលជំហរវីរភាពបដិវត្តខ្ពង់ខ្ពស់ ជំហរលះបង់កម្រិតខ្ពស់បំផុត និងជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួនរឹងប៉ឹងបំផុតដែរ ដើម្បីទ្រសភាពការណ៍ខាងលើនេះបាន ។ ប៉ុន្តែបក្សយើងបានធ្វើពលិកម្មគ្រប់បែបយ៉ាង ដាច់ខាតប្រយុទ្ធដឹកនាំប្រជាជននិងយុវជនយុវនារីកម្ពុជាធ្វើការតស៊ូអាវុធវាយកម្ទេចខ្មាំងនិងវាយកម្ចាត់នូវសង្គ្រាមផ្ទៃក្នុងដ៏កំណាចឃោរឃៅហ្វាស៊ីសបំផុតរបស់ខ្មាំងនេះ ។ ក្នុងរយៈកាលនេះ យើងមិនគ្រាន់តែអាចតស៊ូទប់ទល់ខ្មាំងការពារកម្លាំងបដិវត្ត ការពារមូលដ្ឋានបផ្អែកបដិវត្តន៍បានដោយជោគជ័យប៉ុណ្ណោះទេ តែបក្សនៅបានដឹកនាំចលនាតស៊ូបដិវត្តបានខ្លាំងក្លាសន្ធោសន្ធៅ វាយកម្ទេចកម្លាំងរបស់ខ្មាំងអស់ជាច្រើន និងវាយសំរុកខ្មាំងវិញយ៉ាងខ្លាំងក្លា ទាំងខាងយោធាទាំងខាងនយោបាយ យ៉ាងអាម៉ាស់ជាបន្តបន្ទាប់ជាប់រហូត ។



ចំណែកឯបក្សវិញមិនគ្រាន់តែអាចការពារខ្លួនបានប៉ុណ្ណោះទេ តែបក្សនៅបានពង្រឹងពង្រីកខ្លួនទាំងគុណភាពទាំងបរិមាណបានខ្លាំងក្លានិងឆាប់រហ័សទៀតផង ។ ព្រមជាមួយនេះ បក្សក៏នៅបានចាត់តាំងនិងកសាងកងកម្លាំងប្រដាប់អាវុធដែលជាឧបករណ៍ផ្តាច់ការរបស់បក្សបានទាន់ពេលវេលាផង ។

ដោយសង្គ្រាមផ្ទៃក្នុងរបស់វាត្រូវបរាជ័យស្ទារពុំរួច

ដូច្នេះទើបនៅថ្ងៃ១៨-៣-៧០ ចក្រពត្តិអាមេរិកនិងបរិវារក្បត់ជាតិក៏ធ្វើរដ្ឋប្រហារយោធា រំលំឯករាជ្យ សន្តិភាព អព្យាក្រឹតនៃប្រទេសកម្ពុជាយើង ប៉ុនប៉ងយកប្រទេសកម្ពុជាយើងធ្វើជាមូលដ្ឋានយោធានិងធ្វើជាអាណានិគមថ្មីរបស់វា ។ ពេលនោះសភាពការណ៍កម្ពុជាមានការប្រែប្រួលក្រឡាប់ចាក់ ។ សង្គ្រាមផ្ទៃក្នុងបានប្រែក្លាយទៅជាសង្គ្រាមឈ្លានពានយ៉ាងកាចសាហាវរបស់ចក្រពត្តិអាមេរិកនិងបរិវារមកលើប្រទេសជាតិកម្ពុជាភ្លាម ។ គ្រោះអាសន្នបានចោទឡើងដល់អាយុជីវិតនៃប្រទេសជាតិ ប្រជាជន និងយុវជនយុវនារីកម្ពុជាយើង ។ តែបក្សកុម្មុយនិស្តកម្ពុជាយើងគ្មានរួញរាគក់ស្លុតអ្វីឡើយ ព្រោះបក្សបានត្រៀមជាមុនស្រេចហើយ ទាំងទស្សនៈគោលជំហរ ទាំងលក្ខណៈសម្បត្តិផ្សេងទៀត ។ ដូច្នោះជាបន្ទាន់ភ្លាមនោះបក្សបានប្រយុទ្ធដឹកនាំប្រជាជាតិនិងប្រជាជនកម្ពុជាទាំងមូល ក្រោកឡើងតស៊ូធ្វើសង្គ្រាមបដិវត្ត វាយកម្ទាត់សង្គ្រាមឈ្លានពាននេះរបស់ចក្រពត្តិអាមេរិកនិងបរិវារយ៉ាងអង់អាចក្លៀវក្លាបំផុត ដោយឈរលើជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯងយ៉ាងរឹងមាំ ហើយដណ្តើមបានជ័យជំនះធំៗថ្មីៗទៀតជាបន្តបន្ទាប់ជាប់ជានិច្ច ។ ក្នុងរយៈកាលដំបូងនៃសង្គ្រាមបដិវត្តនេះ បក្សមិនគ្រាន់តែអាចដឹកនាំចលនាតស៊ូបដិវត្តទប់ទល់នឹងសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិកនិងបរិវារបានដោយជោគជ័យប៉ុណ្ណោះទេ តែបក្សនៅបានពង្រីកពង្រីកខ្លួនយ៉ាងឆាប់រហ័ស ពង្រីកពង្រីកទាំងជួរបក្ស ពង្រីកពង្រីកទាំងតំបន់រំដោះបានធំល្វឹងល្វើយ (៧០ភាគរយនៃទឹកដីប្រទេសកម្ពុជាទាំងមូល) ពង្រីកពង្រីកទាំងជួរកងទ័ពបដិវត្តទាំងបីប្រភេទ កសាងហើយពង្រឹងពង្រីកសេដ្ឋកិច្ចសម្រាប់ទប្បត្ថម្ភខ្លួនដោយឯករាជ្យម្ចាស់ការ ព្រមទាំងចាត់តាំងកសាងរដ្ឋអំណាចបដិវត្តន៍សម្រាប់គ្រប់គ្រងតំបន់រំដោះដ៏ធំល្វឹងល្វើយនេះដោយឯករាជ្យម្ចាស់ការបានទាន់ពេលវេលាភ្លាមដែរ ។

ឆ្នាំ១៩៧៣ជាដំណាក់កាលដ៏ធំមួយក្នុងប្រវត្តិសាស្ត្រនៃចលនាបដិវត្តយើង ។ ពេលនោះវៀតណាមនិងលាវគេចរចាឈប់បាញ់ ។ បញ្ហាចោទឡើងជាបន្ទាន់ តើបដិវត្តន៍កម្ពុជាយើងត្រូវចរចាឈប់បាញ់ដូចគេដែរឬក៏បន្តលើកជ្រោងគ្រវីទង់ប្រយុទ្ធវាយចក្រពត្តិអាមេរិកនិងបរិវារទោលតែម្នាក់ឯងតទៅទៀត?

ពេលនោះសភាពការណ៍មានការតឹងតែងស្មុគស្មាញខ្លាំងពិសេសនៅលើសកលលោក ។ ស្ថិតនៅចំពោះមុខសភាពការណ៍ធ្ងន់ធ្ងរតឹងតែងស្មុគស្មាញដូច្នេះ ទាំងនៅក្នុងប្រទេស ទាំងនៅលើសកលលោក បក្សកុម្មុយនិស្តកម្ពុជាយើងបានប្តេជ្ញាធ្វើពលិកម្មគ្រប់បែបយ៉ាង លើកជ្រោងទង់ប្រយុទ្ធបន្តដឹកនាំប្រជាជាតិប្រជាជន និងយុវជនយុវនារីកម្ពុជា វាយចក្រពត្តិអាមេរិកនិងបរិវារ ទោលតែម្នាក់ឯងតទៅទៀត ដើម្បីអត្តភាពនិងកិត្យានុភាពនៃប្រជាជាតិយើង ប្រជាជនយើង ចលនាបដិវត្តន៍យើង និងអត្តភាពបក្សកុម្មុយនិស្តកម្ពុជាយើង ។ បក្សបានធ្វើពលិកម្មគ្រប់បែបយ៉ាង ដឹកនាំប្រជាជននិងប្រជាជាតិកម្ពុជាទាំងមូល វាយកម្ទាត់សង្គ្រាមអាកាសរបស់ចក្រពត្តិអាមេរិកដែលមានទំហំធំធេងសម្បើមពុំធ្លាប់ដែលមានឡើយក្នុងប្រវត្តិសាស្ត្រសង្គ្រាមសកលលោក ។ ពោលគឺចក្រពត្តិអាមេរិកបានប្រមូលយន្តហោះគ្រប់ធុនរាប់ពាន់គ្រឿងរបស់វាដែលបោះប្រចាំនៅអាស៊ី-អគ្នេយ៍ទាំងមូលនិងនៅប៉ាស៊ីហ្វិក មកវាយប្រហារប្រជាជនកម្ពុជាដ៏តូចយើងនេះទាំងយប់ទាំងថ្ងៃក្នុងរយៈពេល១៩៥ថ្ងៃពេញ ។ ថ្ងៃ១៥ សីហា ១៩៧៣ បក្សបានដឹកនាំចលនាតស៊ូបដិវត្ត វាយបំបាក់សង្គ្រាមអាកាសដ៏កំណាចឃោរឃៅរបស់ចក្រពត្តិអាមេរិកនេះដោយជោគជ័យ ។ ហើយបក្សបានដឹកនាំប្រជាជាតិ ប្រជាជន និងយុវជនយុវនារីកម្ពុជាយើង បន្តវាយកម្ទាត់សង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិកនិងបរិវារ បន្តវាយទ្រឹស្តីខ្មែរបនីយកម្មរបស់អា និចសុនដែលយកខ្មែរវាយខ្មែរ យ៉ាងអង់អាចក្លាហានជាបន្តទៀត រហូតដល់ដណ្តើមបានមហាជ័យជំនះទាំងស្រុងនិងជាស្ថាពរនៅថ្ងៃ១៧ មេសា ១៩៧៥ កន្លងទៅនេះ ។

នេះជាប្រវត្តិតស៊ូសង្ខេបរបស់បក្សកុម្មុយនិស្តកម្ពុជាយើងដែលពោរពេញទៅដោយពលិកម្មដ៏ខ្ពង់ខ្ពស់បំផុត វីរភាពបដិវត្តអង់អាចមោះមុតបំផុត គោលជំហរប្រយុទ្ធស្រួចស្រាវដាច់ខាតគ្មានសម្រុះសម្រួលជាមួយខ្មាំងម្តងណាឡើយ ។ ប្រវត្តិតស៊ូរបស់បក្សនេះក៏ជាប្រវត្តិនៃការតស៊ូដោយគោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯង

យ៉ាងរឹងមាំគ្រប់ពេលវេលាដែរ ។ បក្សបានដឹកនាំចលនាតស៊ូបដិវត្តតាំងពីបាតដៃទទេរហូតដល់កសាងបាននូវលក្ខន្តិកៈរបស់បក្សនិងមាគ៌ានយោបាយជាយុទ្ធសាស្ត្រនិងជាយុទ្ធវិធីដោយឯករាជ្យម្ចាស់ការ កសាងបាននូវកងកម្លាំងប្រដាប់អាវុធទាំង៣ប្រភេទដ៏អង់អាចក្លាហាននិងខ្លាំងពូកែរហូតដល់ចាត់តាំងបាននូវរដ្ឋអំណាចរឹងប៉ឹង កសាងបាននូវសេដ្ឋកិច្ចស្តុកស្តម្ភ អាចខបត្តម្ភខ្លួនបានក្នុងពេលសង្គ្រាម ដោយឯករាជ្យម្ចាស់ការរហូតដល់ដណ្តើមបានមហាជ័យជំនះទាំងស្រុងនិងជាស្ថាពរ ។ នេះគឺជាប្រវត្តិតស៊ូដ៏រុងរឿងរបស់បក្សក្នុងរយៈកាល២-៣ឆ្នាំកន្លងទៅ ។

សរុបមក ដោយបក្សមានគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯងយ៉ាងរឹងមាំជាប់ជានិច្ច ដូច្នេះហើយទើបបក្សអាចកសាងពង្រឹងពង្រីកខ្លួនបានឆាប់រហ័ស អាចកសាងអ្វីៗទាំងអស់ដែលមិនទាន់មានឲ្យកើតមានឡើង បានគ្រប់សព្វទាំងអស់ រហូតដល់សម្រេចបដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យបានទាំងស្រុងក្នុងរយៈពេលតែ២៨ឆ្នាំប៉ុណ្ណោះ ដែលជារយៈពេលខ្លីនិងឆាប់ជាងគេបំផុតនៅក្នុងប្រវត្តិសាស្ត្រនៃចលនាបដិវត្តន៍សកលលោក ។


សោម ហុកស្រេង អាយុ ២៨ឆ្នាំ
ថ្ងៃចូលបដិវត្ត ១០.៨.៧១

ក្រោយមហាជ័យជំនះដ៏ល្បីខ្ទរខ្ទារថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥នេះ បក្សបានដឹកនាំប្រជាជន កម្មករ កសិករ កងទ័ពបដិវត្តកម្ពុជា និងយុវជនយុវនារីទាំងមូល បន្តធ្វើបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយមនៅកម្ពុជាយ៉ាងអង់អាចក្លៀវក្លា ដោយឈរលើគោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯងយ៉ាងរឹងប៉ឹងជាបន្តទៀត ដើម្បីការពារប្រទេស និងកសាងប្រទេសឲ្យខ្លាំងពូកែ និងចម្រើនថ្មីថ្មើងរុងរឿងដោយល្បឿនមហាលោតផ្លោះមហាអស្ចារ្យ ។ គ្រាន់តែក្នុងរយៈពេលជាង១ឆ្នាំក្រោយសង្គ្រាមមហាវិនាសកម្មកន្លងទៅនេះ បក្សបានដឹកនាំប្រជាជាតិ ប្រជាជនកម្ពុជា និងយុវជនយុវនារីកម្ពុជា ការពារប្រទេស ការពារផលបដិវត្តន៍បានគង់វង្សល្អប្រសើរ ទោះបីខ្មាំងសត្រូវគ្រប់ទិសទីធ្វើសកម្មភាពប៉ុនប៉ងបំផ្លិចបំផ្លាញនិងវាយរំលំរបបបដិវត្តន៍យើង និងប៉ុនប៉ងលេបយកទឹកដីយើងជាបន្តបន្ទាប់យ៉ាងណាក៏ដោយ ។ ព្រមជាមួយនេះ បក្សក៏បានដឹកនាំប្រជាជាតិ ប្រជាជន និងយុវជនយុវនារីកម្ពុជាយើង ស្តារសេដ្ឋកិច្ចគ្រប់ផ្នែកឲ្យមានដំណើរការប្រក្រតីឡើងវិញ ព្រមទាំងវាយសម្រុកបង្កបង្កើនផល ដោះស្រាយជីវភាពប្រជាជនបានដោយជោគជ័យនិងដោយឯករាជ្យម្ចាស់ការទៀត ។

ឥឡូវយើងឈានចូលដំណាក់កាលមួយដែលត្រូវកសាងសង្គមនិយម និងការពារប្រទេសជាខ្សែសង្វាក់ហើយ ។ យើងចង់កសាងប្រទេសឲ្យបានឆាប់រហ័សផង ហើយរក្សាជំហរឯករាជ្យម្ចាស់ការនិងការពារអធិបតេយ្យភាពរបស់ប្រទេសជាតិយើងបានរឹងប៉ឹងផង ដើម្បីដោះស្រាយនិងលើកស្ទួយជីវភាពប្រជាជនយើងឲ្យបានឆាប់រហ័សផង កសាងប្រទេសយើងឲ្យចំរើនលូតលាស់លោតផ្លោះផង ព្រមទាំងការពារប្រទេសឲ្យបានកាន់តែរឹងប៉ឹងខ្លាំងពូកែ កាន់តែល្អប្រសើរថែមទៀត ។ ដូច្នេះមាគ៌ាកសាងសង្គមនិយមនិងការពារប្រទេសជាខ្សែសង្វាក់តទៅឆ្នាំក្រោយៗទៀតនេះ ត្រូវតែឈរយ៉ាងរឹងមាំលើជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯងជាបន្តទៅទៀត ។ ព្រោះតាមពិសោធន៍របស់យើងកន្លងមក កាលក្នុងសម័យតស៊ូបដិវត្តប្រជាជាតិ-ប្រជាធិបតេយ្យ យើងឃើញច្បាស់ហើយថាទាល់តែឈរលើមាគ៌ាឯករាជ្យ-ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួន ដោយខ្លួនឯងយ៉ាងរឹងមាំជាប់ជានិច្ចឥតងាករេ ក្នុងគ្រាស្រួលក៏ដូចក្នុងគ្រាលំបាក ទើបយើងដណ្តើមបានជ័យជំនះឆាប់រហ័ស ។ **(នៅមានត)**


វន វេត
គួប ភឿន


កុយ ធួន


យុន យ៉ាត


សុន សេន

## ប្រវត្តិរូប វន វ៉េត ហៅ សុខ ធួក ហៅ ធួក

វន វេត បានចូលរួមធ្វើបាតុកម្មនៅខែឧសភា ឆ្នាំ១៩៥២ ។ ឆ្នាំ១៩៥៤ រត់ចេញពីភ្នំពេញនៅពេលដែលឪពុកមាររបស់គាត់ត្រូវប៉ូលិសចាប់ខ្លួន ។ វន វេត ត្រូវបានចាប់ខ្លួននិងដាក់គុកអស់រយៈពេល៤ខែ ។ ឆ្នាំ១៩៥៦ វន វេត បង្រៀននៅវិទ្យាល័យចំរើនវិជ្ជា ភ្នំពេញ ហើយឆ្នាំ១៩៥៨ ជាសមាជិកគណៈកម្មាធិការបក្សក្រុង ទទួលខុសត្រូវលើកម្មករនិងប្រជាជននៅទីក្រុង ។ ឆ្នាំ១៩៦២ វន វេត ជាលេខាសាខាបក្សក្រុងភ្នំពេញ និងឆ្នាំ១៩៦៣ ជាសមាជិកមជ្ឈិមបក្ស ប្រឆាំងនឹងការតស៊ូប្រដាប់អាវុធ ។ ឆ្នាំ១៩៦៨ វន វេត មានមូលដ្ឋាននៅភូមិភាគនិរតី ភ្នំក្រវាញ ប៉ុន្តែត្រូវត្រឡប់មកភ្នំពេញបន្ទាប់ពីមានជំងឺគ្រុនចាញ់ ។ ឆ្នាំ១៩៦៩ វិលមកភូមិភាគនិរតីវិញ ប៉ុន្តែនៅឈឺនៅឡើយ រហូតដល់ឆ្នាំ១៩៧០ ទើបជាសះស្បើយ ។ ឆ្នាំ១៩៧៣ វន វេត គ្រប់គ្រងតំបន់២៥ ហើយក្នុងឆ្នាំ១៩៧៤គ្រប់គ្រងតំបន់១១ (ខេត្តកោះកុង) មានមន្ទីរការិយាល័យនៅអមលាំង ។ ឆ្នាំ១៩៧៥ វន វេត មាននាទីជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការពារជាតិ ។ ឆ្នាំ១៩៧៦ មាននាទីជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកសេដ្ឋកិច្ច ។ ឆ្នាំ១៩៧៧ ត្រូវបានអង្គការចាប់ខ្លួន ហើយសម្លាប់ក្រោយពីធ្វើទារុណកម្មនៅគុកទួលស្លែង ។

**ឆាំង យុ**



សមមិត្ត គង់ ឬ សួន ស៊ីគឿន

(កត់ត្រាតាមសំណៅដើមទាំងស្រុង)

**(តពីលេខមុន) ១) រយៈកាលទី១:** ១៩៥៨-១៩៦០ ខ្ញុំបានចូលរួមសកម្មភាពជាមួយនិស្សិតនិងបញ្ញាជន ប្រយុទ្ធបង្រួបបង្រួមអាណិកជនកម្ពុជានៅបរទេស ជាវណសិរ្សប្រឆាំងចក្រពត្តិនិងពួកសក្តិភូមិនាយទុនប្រតិកិរិយា ដើម្បីសម្រេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យនៅកម្ពុជា ។ ខ្ញុំទទួលខុសត្រូវធ្វើសកម្មភាពក្នុងក្របខ័ណ្ឌគណៈកម្មាធិការ“ផ្ទះខ្មែរ”ដែលភាគច្រើនជាសមាជិក “សហភាពនិស្សិតខ្មែរ” ក្នុងរយៈកាលនេះស្មារតីប្រយុទ្ធដែលបានទទួលការអប់រំពីកម្ពុជាមកខ្ញុំនៅរក្សាបាន ។

**២) រយៈកាលទី២:** ១៩៦១-១៩៦៦ ជារយៈកាលដែលឥទ្ធិពលសេរីវិគ្រុបដណ្តប់ធ្វើឲ្យទស្សនៈនិងគោលជំហរចំពោះខ្មាំងជាចក្រពត្តិនិងខ្មាំងវណ្ណៈច្របូកច្របល់ ខ្ញុំឃើញថា ចក្រពត្តិអាមេរិកនៅតែជាសត្រូវស្លាប់រស់របស់ប្រជាជាតិប្រជាជនយើង ហើយបរិវារវាគឺពួកអា ចៅ សាយ, លន់ ណុល, ញឹក ជូឡុង ។ តែមាគ៌ាដោះស្រាយទំនាស់ស្លាប់រស់នេះនៅមិនច្បាស់លាស់ ។ ខ្ញុំបានលើកថាទស្សនៈ “ប្រជាធិបតេយ្យជាតិ” អាចយកមកអនុវត្តបាននៅកម្ពុជា ។ ប៉ុន្តែបញ្ហាដឹកនាំខ្ញុំឃើញពួកសីហនុគ្មានសមត្ថភាពទេ ។ បញ្ហានេះមានតែបក្សម៉ាក្ស-ឡេនីនទេអាចដឹកនាំបាន ។ ប៉ុន្តែបញ្ហាទំនាស់ជាមួយចក្រពត្តិនិងជាមួយបរិវារផ្ទៃក្នុងពេលនោះខ្ញុំយល់ថាអាចដោះស្រាយដោយជំរុញរដ្ឋអំណាចសីហនុឲ្យទប់ទល់និងប្រឆាំងខបាយកលជ្រៀតជ្រែកឈ្លានពាននិងវិទ្ធង្សនារបស់ចក្រពត្តិអាមេរិកនិងពួកអាក្បត់ជាបរិវារវា ។ សូមបញ្ជាក់ថានៅឆ្នាំ១៩៦២ យើងខ្ញុំមិនបានអានឬដឹងទស្សនៈនិងគោលជំហររបស់បក្សឡើយ ។ ឯកសារជាទស្សនៈសភាពការណ៍បក្សបានខិតខំផ្ញើទៅឃោសនាអប់រំយើងខ្ញុំ តែអ្នកទទួលខុសត្រូវ “វង្សម៉ាក្ស-ឡេនីន”ពេលនោះគឺ ជួន មុម្ម មិនបានផ្សព្វផ្សាយឲ្យយើងខ្ញុំដឹងនិងយល់ទេ ។ ពេលខ្លះដែលខ្ញុំធ្លាប់បានថាបក្សបានផ្ញើឯកសារទៅគឺដោយចាប់បានពាក្យសម្តីខ្លះដែលលេចឡើងហើយយោងទៅតាមឯកសារនោះ ។ ដល់ខ្ញុំបានសួរពីបញ្ហានេះចម្លើយគឺមិនបានច្បាស់លាស់ទេ ច្រើនផ្អែកថាឯកសារទាំងនោះជាសំបុត្រផ្ទាល់ខ្លួន ។

តែទោះជាដាច់ពីការណែនាំរបស់បក្សក្តី ទស្សនៈនិងគោលជំហរសេរីវិរបស់ខ្ញុំបានធ្វើឲ្យឃ្លាតចេញពីប្រទេសជាតិខ្លួន ពីប្រជាជនខ្លួន ពីបក្សរបស់ខ្លួន ។

នៅខែមេសា ១៩៦៣ បងៗអ្នកដឹកនាំបានចូលទៅបន្តដឹកនាំការតស៊ូនៅមូលដ្ឋានជនបទ ។ ព្រឹត្តិការណ៍នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយដែលមានអត្ថន័យជាយុទ្ធសាស្ត្រជ្រាលជ្រៅណាស់ចំពោះអនាគតប្រទេសជាតិយើង អនាគតបដិវត្តន៍កម្ពុជាយើង ។ តើទស្សនៈនិងគោលជំហររបស់ខ្ញុំយ៉ាងណា? ជាដំបូងខ្ញុំភ្ញាក់នឹងព្រឹត្តិការណ៍នេះ ព្រោះពេលនោះចលនាមហាជនប្រឆាំងចក្រពត្តិអាមេរិកសន្ធោសន្ធៅ សីហនុ ប្រកាសឈប់ទទួលជំនួយចក្រពត្តិអាមេរិក ។ ដូច្នេះជាជម្រៅមិនឯកភាពទេ ហើយជាចំហក៏មិនសកម្មការពារអាកប្បកិរិយាត្រឹមត្រូវនេះរបស់បក្សដែរ ។ ពេលខ្មាំងវាយច្រើនតែឆ្លើយក្នុងឋានៈវង្សដឹងថាបងៗភៀសខ្លួនដើម្បីកុំឲ្យពួកអា លន់ ណុល ចាប់កាប់សម្លាប់ ។ ហើយក្នុងចិត្តក៏ស្មានជាអត្តនោម័តិថាប្រហែលជាយ៉ាងដូច្នេះមែន ។ ខ្លួនខ្ញុំបានគិតពិចារណាច្រើនចំពោះបញ្ហានេះ ។ តែរវាងបដិវត្តន៍និងប្រឆាំងបដិវត្តន៍ពេលនោះច្របូកច្របល់ ហើយជាទស្សនៈយល់ដូចខ្មាំងថាកាលៈទេសៈដែលបងៗចូលព្រៃនេះមិនសមស្របទេ ព្រោះមហាជនមិនយល់ដោយ សីហនុ កំពុងវាយចក្រពត្តិអាមេរិក ម្តេចក៏រត់ចោល សីហនុ ទុកឲ្យ សីហនុ នៅឯកោចំពោះការវាយប្រហាររបស់ខ្មាំង ។

-នេះជាទស្សនៈនិងគោលជំហរសេរីវិរបស់ខ្ញុំដែលពាក់ព័ន្ធដល់បញ្ហាជាអាយុជីវិតរបស់ប្រទេសជាតិ របស់បដិវត្តន៍កម្ពុជារបស់បុព្វហេតុកុម្មុយនិស្តនិយមដែលតាំងពីយុវវ័យមកខ្ញុំប្តេជ្ញាបម្រើរហូតដល់ជីវិតបង់ ។

**៣) រយៈកាលទី៣:**

ចាប់ពីឆ្នាំ១៩៦៧មកដល់រដ្ឋប្រហារ សភាពការណ៍នៅកម្ពុជាកាន់តែតឹងតែង ។ អា លន់ ណុល ឡើងកាន់អំណាចលើកទី១ ។ ខ្ញុំចាប់អារម្មណ៍ថា ផ្លូវសន្តិវិធីតាមសភានៅកម្ពុជាមិនអាចទៅបានទេ ។ រដ្ឋប្រហារប្រតិកិរិយាដែលបើកផ្លូវឲ្យចក្រពត្តិអាមេរិកមកតាំងមូលដ្ឋាននៅកម្ពុជាចៀសមិនផុតទេ ។ នេះគ្រាន់តែចាប់អារម្មណ៍ប៉ុណ្ណោះ មិនមែនចេញគោលជំហរទស្សនៈសភាពការណ៍ច្បាស់លាស់និងវិធានការជាក់ស្តែងយ៉ាងណាទេ ។

ដល់ផ្ទុះព្រឹត្តិការណ៍នៅសំឡូត យើងខ្ញុំឃើញច្បាស់ថា នេះជាស្នាដៃពួកបរិវារខ្ញុំកញ្ជះចក្រពត្តិអាមេរិកដែលមានពួក សីហនុ ជាអ្នកចូលដៃធ្វើការរាតត្បាតកាប់សម្លាប់ប្រជាជនស្លូតត្រង់ និងយុទ្ធជនយុទ្ធនារីនិងកម្មាភិបាលបដិវត្តយើង ។ យើងខ្ញុំក៏បានថ្កោលទោសអំពើហ្វាស៊ីសនេះរបស់វណ្ណៈកាន់អំណាចពេលនោះដែរក្នុងព្រឹត្តិបត្រប្រចាំត្រីមាសរបស់“សហភាពនិស្សិតខ្មែរ” ។ ក្នុងព្រឹត្តិបត្រដដែលយើងខ្ញុំក៏បានសម្តែងនូវជំនឿនិងការទុកដាក់របស់យើងខ្ញុំចំពោះបង ខៀវ សំផន ក្នុងឋានៈគាត់ជាអតីតអនុប្រធាន“សហភាពនិស្សិតខ្មែរ” ។ តែពេលនោះក៏យើងខ្ញុំដាក់ឈ្មោះ ហ៊ូ យន់ និងឈ្មោះអាក្បត់ ហ៊ូ នឹម ចូលជាមួយដែរ ។

យើងខ្ញុំមិនបានដឹងថាពួកអាសេរីរើសូវៀតនិយាយថា “ពួកខ្មែរក្រហមជាពួកឆ្វេងនិយមហួសហេតុ”ទេ ។ យើងខ្ញុំដឹងបញ្ហានេះនៅឆ្នាំ១៩៧០ ក្រោយរដ្ឋប្រហារ ដោយ សីហនុ បានប្រាប់យើងខ្ញុំថា នៅពេលផ្ទុះព្រឹត្តិការណ៍សំឡូតភ្លាម ឯកអគ្គរដ្ឋទូតសូវៀតនៅភ្នំពេញបានទៅជួប សីហនុ ហើយនិយាយថាសូវៀតគាំទ្រ សីហនុ ក្នុងការរាតត្បាតព្រឹត្តិការណ៍សំឡូតនេះ ។

- ដោយក្តាប់បាននូវសភាពការណ៍ដែលវិវត្តកាន់តែតឹងតែងឡើង បានជាពេលរដ្ឋប្រហារខ្ញុំគ្មានភ្ញាក់ផ្អើលអ្វីទេ ហើយ “សហភាពនិស្សិតខ្មែរ” បានថ្កោលទោសរដ្ឋប្រហារនេះភ្លាមក្នុងមិទ្ទីងរបស់អាណិកជនកម្ពុជានៅប្រទេសបារាំងថ្ងៃ ២២ ខែ៤ ឆ្នាំ១៩៧០ ។

សភាពការណ៍តឹងតែងនេះជះឥទ្ធិពលមកដល់អាណិកជនកម្ពុជានៅប្រទេសបារាំងដែរ ។ ទស្សនៈនិងគោលជំហរសេរីរើរបស់“វង្សម៉ាក្ស-ឡេនីន”ដែលនិយម សីហនុ ហួសហេតុធ្វើឲ្យប្រមូលកម្លាំងនិស្សិតនិងបញ្ញាជនស្នេហាជាតិនៅបរទេសមិនបាន ។ យុវជនស្នេហាជាតិគេមិនទុកចិត្តលើ“វង្សម៉ាក្ស-ឡេនីន” ព្រោះប្រកាន់ជំហរសូវៀតហើយនិយមវៀតណាម ។ ទំនាស់ផ្ទៃក្នុងកាន់តែខ្លាំង ។ គ្មានអ្នកណាស្តាប់អ្នកណា ។ ចំពោះខ្លួនខ្ញុំផ្ទាល់ខ្ញុំបាត់ទស្សនៈអនាគតបដិវត្តន៍ គិតវិលវល់តែបញ្ហាផ្ទាល់ខ្លួនជាការងារដើម្បីចិញ្ចឹមជីវិត ជាបញ្ហាគ្រួសារ ។ គឺក្នុងសភាពការណ៍នេះហើយដែលខ្ញុំរៀបចំគ្រួសារជាជាតិបារាំង ធ្វើគ្រូបង្រៀនបឋមសិក្សា នៅថ្ងៃទី៩ ខែ១១ ឆ្នាំ១៩៦៧ ។ មូលហេតុក្នុងសភាពការណ៍ស្មុគស្មាញ គ្មានការរកក់ក្តៅពីសមូហភាពជា “វង្សម៉ាក្ស-ឡេនីន” ដោយមិនចង់រស់នៅតែឯងយូរពេក ខ្ញុំក៏សុខចិត្តរៀបចំគ្រួសារសព្វថ្ងៃនេះ ។ ពេលនោះខ្ញុំមានអាយុ ៣០ឆ្នាំគ្រួសារខ្ញុំ២០ឆ្នាំ ។

-នៅឆ្នាំ១៩៦៩ អា តូច ខាំឌឿន លាឈប់ពីប្រធាន “សហភាពនិស្សិតខ្មែរ” ទុកជា“វង្សម៉ាក្ស-ឡេនីន”មិនយល់ព្រមក៏ដោយ ។ “វង្ស” បានស្នើឲ្យសមាជិក “តុរ” ម្នាក់ទៀតគឺទុនជោតិ ស៊ីរិន ធ្វើជាប្រធាន តែឈ្មោះនេះប្រកែក ។ “វង្ស” ក៏ប្រគល់ភារកិច្ចនេះឲ្យខ្ញុំ ។ ខ្ញុំធ្វើជាប្រធាន“សហភាពនិស្សិតខ្មែរ” រហូតដល់ថ្ងៃដែលខ្ញុំមកប៉េកាំង (១៥ ឧសភា ១៩៧០) ។ នៅខែឧសភា ១៩៧០ មហាសន្និបាតនៃ“សហភាពនិស្សិតខ្មែរ” បានជ្រើសរើសខ្ញុំធ្វើជាប្រធានម្តងទៀត ។ ប៉ុន្តែសមាជិកមួយចំនួនដឹកនាំដោយ អ៊ុន សុភាព (មី) បានជំទាស់ហើយដើរចេញពីអង្គប្រជុំ ។ មូលហេតុ ១) សមាជិកនោះមិនទុកចិត្តព្រោះយើងខ្ញុំសេរីរើ ២) ម្យ៉ាងទៀតខ្លាំងវណ្ណៈពួក សារិន ឆាក់ វ៉ាន់ ពីនី ក៏ធ្វើសកម្មភាព ។

-ក្នុងរយៈកាលនោះអាក្បត់ ហាក់ ស៊ាងឡាយនី បានទៅប្រទេសបារាំង២ដង ម្តងនៅឆ្នាំ១៩៦៥ ហើយម្តងទៀតនៅឆ្នាំ ១៩៦៦ ។ ទាំងពីរលើកនេះខ្ញុំមិនបានទាក់ទងជាមួយវាជាចាត់តាំងអ្វីទេ ព្រោះជាជំហរអា តូច ខាំឌឿន ជាប្រធាន“សហភាពនិស្សិតខ្មែរ” ហើយជាសម្ងាត់ ជួន មុម្ម ជាអ្នកទទួលខុសត្រូវ “វង្សម៉ាក្ស-ឡេនីន ” អាក្បត់នេះវាបានទាក់ទងធ្វើការច្រើនជាមួយ ជួន មុម្ម ពិសេសនៅខែកក្កដា ១៩៦៦ ។ ជាចំហអានេះច្រើនលើកពីបញ្ហាធ្វើសហព័ន្ធនិស្សិតកម្ពុជានៅអឺរ៉ុប ។ តែខាងយើងខ្ញុំក៏ប្រុងប្រយ័ត្នដែរ ព្រោះមិនចង់ឲ្យមានបញ្ហាជាមួយរដ្ឋការបារាំងដោយការជាប់ទាក់ទិនជាមួយប្រទេសអឺរ៉ុបខាងកើត ។

-នៅឆ្នាំ១៩៦៨ ឈ្មោះ រឿង ម៉ាច បានមកប្រទេសបារាំងដោយនាំមកជាមួយដើម្បីផ្សាយនូវសៀវភៅទិតៀនចំពោះសង្គមនិយមព្រះពុទ្ធសាសនារបស់ សីហនុ និងខិត្តប័ណ្ណដែលមានហត្ថលេខាថា “បក្សកុម្មុយនិស្តខ្មែរ” ដែលសរសេរ

ដោយក្រុមនិស្សិតសេរីកម្ពុជានៅសូវៀត ។ ឯកសារទាំងនេះវាផ្ញើតាមប៉ុស្តិ៍មកឲ្យ“សហភាពនិស្សិតខ្មែរ” ។ ក្រៅពីផ្សាយឯកសារនេះខ្ញុំមិនបានដឹងតើវាមកប្រទេសបារាំងក្នុងទិសដៅអ្វីទៀតទេ ។

ក្នុងរយៈកាលនេះ “វង្សម៉ាក្ស-ឡេនីន”មានការទាក់ទងកាន់តែជិតស្និទ្ធជាមួយនិស្សិត “ចំរើន” យួន ពិសេស ដួន មុម្ម និង ផៀង ខាច់វៀន ប្រធាន“សហភាពវៀតណាម”នៅប្រទេសបារាំង ។ “វង្ស”បានលង់ខ្លួនចូល ១០០ ភាគរយក្នុងទស្សនៈឥណ្ឌូចិន ដោយយល់ភាន់ច្រឡំថាយួនវាគ្មានមហិច្ឆតាលេបទឹកដីយើងទេ ព្រោះវាជាបដិវត្តន៍ ហើយយើងក៏បដិវត្តន៍ដូចគ្នា គឺទាក់ទងគ្នាដោយស្មើភាពគ្នាគោរពគ្នាទៅវិញទៅមក ដូយខបត្តម្ភគ្នាជាបងប្អូនក្នុងគ្រួសារតែមួយ ។ ក្រោយសន្និសីទកំពូលប្រជាជន“ឥណ្ឌូចិន” ក្នុងឆ្នាំ១៩៧០ សមាគមនិស្សិតខ្មែរ យួន និងឡាវ បានរៀបមិទ្ទីងរួមមួយដើម្បីទទួលអំណរសន្និសីទនេះនៅក្រុងប៉ារីស ។ ខ្លួនខ្ញុំផ្ទាល់បានធ្វើជាប្រធានមិទ្ទីងនេះ នៅថ្ងៃទី១២ ឧសភា ១៩៧០ ។

-នៅថ្ងៃ១៥ ឧសភា ១៩៧០ ខ្ញុំបានធ្វើដំណើរមកប៉េកាំងដើម្បីពាំនាំនូវការគាំទ្ររបស់ “សហភាពនិស្សិតខ្មែរ” ដល់រណសិរ្សរួបរួមជាតិកម្ពុជា ហើយដើម្បីមើលសភាពការណ៍ជាក់ស្តែងនៅប៉េកាំង ។

តាមផ្លូវមកប៉េកាំងខ្ញុំឆ្លងកាត់ម៉ូស្គូ ហើយបាននៅសម្រាកពីរថ្ងៃនៅស្ថានទូតកម្ពុជាដែល ជា សាន ជាឯកអគ្គរដ្ឋទូតប្រចាំសហភាពសូវៀត ។ ក្នុងពេលស្នាក់អាស្រ័យនៅម៉ូស្គូនេះក្នុងឋានៈជាប្រធាន “សហភាពនិស្សិតខ្មែរ” ខ្ញុំបានសុំជួបអង្គការនិស្សិតសូវៀតដើម្បីខទ្មេសនាមសភាពការណ៍នៅកម្ពុជាក្រោយរដ្ឋប្រហារ ហើយក្នុងពេលដែលចក្រពត្តិអាមេរិកកំពុងលើកទ័ពវាទីងទ័ពបរិវាររវាមកឈ្លានពានកម្ពុជា ។ ខ្ញុំក៏បានសូមអង្គការនិស្សិតសូវៀតគាំទ្រការតស៊ូប្រជាជនកម្ពុជា ហើយឲ្យរដ្ឋាភិបាលសូវៀតទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ ការទទួលរបស់និស្សិតសូវៀតសោះអង្គើយជាទីបំផុត ត្រជាក់មែនទែន ។ គេគ្រាន់តែឆ្លើយមួយម៉ាត់ថា “អង្គការនិស្សិតសូវៀតគាំទ្រគោលជំហររបស់រដ្ឋាភិបាលសូវៀតក្នុងបញ្ហាកម្ពុជា” ។ ខ្ញុំចេញពីការជួបសន្ទនានេះដោយអាក់អន់ស្រពោនក្នុងចិត្តយ៉ាងខ្លាំងព្រោះឃើញថាសូវៀតមិនទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។

-នៅថ្ងៃ១៩ ឧសភា ១៩៧០ ខ្ញុំមកដល់ប៉េកាំង ។ ខ្ញុំគ្មានទទួលតំណែងអ្វីទេ ។ ខ្ញុំជួយធ្វើការគេឯណេះបន្តិចឯណោះបន្តិច ។

-នៅថ្ងៃ ២៥ ឧសភា ១៩៧០ ខ្ញុំបានចូលជាសមាជិកគណៈប្រតិភូរណសិរ្សរួបរួមជាតិកម្ពុជានិងរាជរដ្ឋាភិបាលកម្ពុជាទៅធ្វើទស្សនកិច្ចនៅហាណូយជាមួយ សីហនុ ។ ខ្ញុំរំភើបនឹងទស្សនកិច្ចនេះណាស់ ព្រោះទស្សនកិច្ចរបស់ខ្ញុំនេះសេរីច្របូកច្របល់ ឃើញវៀតណាមដូចជាឃើញប្រទេសឯងអ៊ីចឹង ។

ប៉ុន្តែខ្ញុំបានចាប់អារម្មណ៍ថាវៀតណាមទទួល សីហនុ ដូចពីពេលសង្គមចាស់ ចាក់ភ្លេងលេងសិល្បៈកម្ពុជាតាមចំណូលចិត្តរបស់ សីហនុ គ្មានបដិវត្តអ្វីទេ ។ ម្យ៉ាងទៀត វៀតណាមដែលបម្រើការងារជិតគណៈប្រតិភូ មានទស្សនៈមិនត្រឹមត្រូវ ចូលចិត្តនិយាយពីនារី ពីចម្រៀងប្រទេសខាងលិចមានអ៊ីតាលីឬបារាំងជាដើម ។

ថ្ងៃ ៨ មិថុនា ១៩៧០ យើងត្រឡប់មកប៉េកាំងវិញ ។ ខ្ញុំក៏រស់នៅប្រទេសចិនមួយរយៈពេលទើបសម្រេចមិនត្រឡប់ទៅប្រទេសបារាំងវិញ ហើយក៏សុំរណសិរ្សអនុញ្ញាតឲ្យគ្រួសារខ្ញុំមកប៉េកាំងដែរ ។ គាត់មកដល់ប្រទេសចិននៅថ្ងៃ៧ ខែ៧ ឆ្នាំ១៩៧០ ។

## មូលហេតុដែលឲ្យខ្ញុំនៅប៉េកាំងមិនត្រឡប់ទៅប៉ារីសវិញ÷

១) ចង់រួមចំណែកក្នុងការតស៊ូប្រឆាំងសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិក

២) ចង់មានមុខមានមាត់ក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ។ ពេលនោះយើងខ្ញុំរស់នៅក្នុងបរិយាកាសសក្តិភូមិនាយទុនភ្លើតភ្លើននឹងមុខមាត់បុណ្យសក្តិតំណែងនាទី ។

ដោយយកគំនិតផ្តួចផ្តើមខ្លួនឯង ហើយដោយបានទទួលការគាំទ្រពីសមាជិករណសិរ្សក្មេងៗ ខ្ញុំក៏ចាប់ផ្តើមសរសេរនិងបោះពុម្ពផ្សាយ“ព្រឹត្តិបត្ររណសិរ្សរួបរួមជាតិកម្ពុជា”ក្នុងមួយអាទិត្យម្តង ។ ក្រោយមកមានបង្កើតជាការិយាល័យឃោសនាការអមការិយាល័យនយោបាយរណសិរ្សរួបរួមជាតិកម្ពុជា ។ ចាប់ពីពេលនោះក៏ចាប់ផ្សាយអត្ថបទវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជាក្នុងចំណោមអាណិកជនកម្ពុជានៅបរទេស ។ យើងខ្ញុំធ្វើការនេះរហូតដល់ទីភ្នាក់ងារ “អា.កា.អ៊ី” បានបង្កើតនៅថ្ងៃ១០ ខែ៨ ឆ្នាំ១៩៧០ ។

ក្នុងការផ្សាយព្រឹត្តិបត្រប្រចាំអាទិត្យ យើងខ្ញុំប្រកាន់យកទស្សនៈសេរីរើប្រឬកប្របល់ធ្ងន់ធ្ងរយ៉ាងខ្លាំង ។ ឧទាហរណ៍យើងខ្ញុំចំផ្សាយសកម្មភាពឬសេចក្តីថ្លែងការណ៍របស់សូវៀតឬបក្សពួកវាដែលធ្វើជាគាំទ្រដល់ការតស៊ូរបស់ប្រជាជនកម្ពុជាយើង ។ ម្យ៉ាងទៀត ក្នុងចំណោមប្រទេសជាមិត្តយើងខ្ញុំទុកវៀតណាមមុនចិន ព្រោះវៀតណាមឬឡាវជាសមភូមិប្រយុទ្ធដូចគ្នាឯចិនជាសមរភូមិក្រោយ ភ្លេចគិតថាចិនជាបង្អែកយុទ្ធសាស្ត្រយើង ។

-ចំពោះវិវាទរវាងសេរីរើសូវៀតនិងចិនក្នុងរយៈកាលយើងខ្ញុំមកដល់ប្រទេសចិនប្រមាណ១ឆ្នាំមុនបានជួបបក្សឡើងវិញ ជំហរយើងខ្ញុំ មនោសញ្ចេតនាផ្ទាល់របស់យើងខ្ញុំ គឺឈរនៅខាងសេរីរើ ។ ឧទាហរណ៍យើងខ្ញុំបានប្រឆាំងមិនឲ្យមិត្តចិនយកខ្សែភាពយន្តស្តីពីឧបទ្ទវហេតុព្រំដែនរវាងសូវៀតនិងចិនមកបញ្ចាំងឲ្យពួករណសិរ្សមើលដោយយកលេសថាបញ្ហានេះជាបញ្ហារវាងសូវៀតនិងចិនទេ មិនត្រូវឲ្យជនជាតិកម្ពុជាប្រកាន់គោលជំហរខាងណាៗឡើយ ។

ទាំងនេះជាទស្សនៈនិងគោលជំហរ អាកប្បកិរិយាសេរីរើធ្ងន់ធ្ងររបស់យើងខ្ញុំក្នុងរយៈកាលដ៏យូរមុនមកបានជួបបក្សនៅខែកក្កដា ឆ្នាំ១៩៧១ ។

**មូលហេតុនៃទស្សនៈនិងគោលជំហរសេរីរើនេះមានដូចតទៅ÷**

១) ជាទស្សនៈ ជាគោលជំហរ ខ្ញុំឈរខាងទស្សនៈនិងគោលជំហរកម្មសិទ្ធិឯកជនរបស់វណ្ណៈជិះជាន់ ការលះបង់ការតស៊ូ ធ្វើឡើងដើម្បីកិត្តិយសកិត្តិស័ព្ទបុគ្គលខ្លួនផ្ទាល់ បម្រើការលោភលន់ជាមុខមាត់បុណ្យសក្តិរបស់ខ្លួនផ្ទាល់ ។ ក្នុងសភាពការណ៍ដែលកម្លាំងបដិវត្តន៍ កម្លាំងប្រជាជនជាទូទៅលើសកលលោកភ្ញាក់រឭក ហើយកាន់តែខ្លាំងក្លាឥទ្ធិពលសង្គមនិយមក៏ជះកាន់តែខ្លាំងទៀត ផ្លូវកិត្តិយសគឺឈរនៅខាងផ្លូវបដិវត្តន៍ជាមួយប្រជាជនក្រីក្រ ។ ក៏ប៉ុន្តែបើតស៊ូដាច់ខាតជាមួយខ្មាំងត្រូវទ្រាំទ្រការលំបាកត្រូវលះបង់កម្រិតខ្ពស់រហូតដល់អាយុជីវិត ។ ដូច្នេះផ្លូវសេរីរើគឺមានឈ្មោះជាអ្នកបដិវត្តន៍ផង មានកិត្តិយសផង ហើយកម្រិតលះបង់ កម្រិតទ្រាំទ្រការលំបាកក៏មិនខ្លាំងក្លាប៉ុន្មាន ខ្លួនយើងខ្ញុំអាចធ្វើបានដោយឈរលើឋានៈជាអ្នកចេះដឹងបច្ចេកទេសខ្លះ ។

**(នៅមានត)**



ប្រវត្តិរូប ខៀវ ប៉ុណ្ណារី ហៅ យឹម

កើតនៅខេត្តបាត់ដំបង ជាសិស្សវិទ្យាល័យស៊ីសុវត្ថិ ។ ឪពុកជាចៅក្រម ។ ជាស្ត្រីខ្មែរទី១ដែលមានសញ្ញាប័ត្រមធ្យមសិក្សាពីប្រទេសបារាំង ។ ប៉ុណ្ណារីត្រឡប់មកពីបារាំងវិញនៅឆ្នាំ១៩៥១ ហើយចាប់ផ្តើមចេញផ្សាយទស្សនាវដ្តីស្ត្រីដែលមានឈ្មោះថា "នារី" ជាមួយអ្នកស្រី សុង សាន ។ ខៀវ ប៉ុណ្ណារីរៀបការជាមួយ សាឡុត ស (ប៉ុល ពត) នៅឆ្នាំ១៩៥៦ ។ នៅខែកក្កដាឆ្នាំ១៩៦១ បានបង្កើតអង្គការស្ត្រីកុម្មុយនិស្តសម្ងាត់មួយ ។ ឆ្នាំ១៩៦៥រត់ចូលព្រៃតាមការជួយរំដោះចេញពីក្រុងភ្នំពេញដោយបណ្តាញទាក់ទងវៀតណាម ។ ឆ្នាំ១៩៧៣ក្លាយជាលេខាបក្សប្រចាំនៅខេត្តកំពង់ធំដែលជាតំបន់ក្តៅ ។ ឆ្នាំ១៩៧៦ជាប្រធានសមាគមស្ត្រីកម្ពុជាប្រជាធិបតេយ្យ ។ ឆាំង យុ



# មន្ទីរពេទ្យវិកលចរិតក្លាយជាមន្ទីរឃុំឃាំង

មន្ទីរពេទ្យជ័យជំនះបច្ចុប្បន្នជាឈ្មោះរបស់អតីតមន្ទីរពេទ្យវិកលចរិតព្រែកត្នោតដែលប្រជាជនយើងបានដឹងនិងពុគ្រប់ៗគ្នាថាជាមន្ទីរពេទ្យសម្រាប់ទទួលព្យាបាលជំងឺសរសៃប្រសាទកាលពីពីរជំនាន់មុនរបបខ្មែរក្រហម ។

តាំងពីឆ្នាំ១៩៥៥រហូតដល់ឆ្នាំ១៩៦៤ មន្ទីរពេទ្យវិកលចរិតនេះគ្រប់គ្រងដោយលោកវេជ្ជបណ្ឌិត សុន ម៉ម ។ មន្ទីរពេទ្យនេះត្រូវបានផ្លាស់ប្តូរឈ្មោះជាមន្ទីរពេទ្យ សុន ម៉ម ចាប់ពីឆ្នាំ១៩៦៤មកទល់នឹងឆ្នាំ១៩៧៥ បន្ទាប់ពីមានការផ្លាស់ប្តូរអ្នកគ្រប់គ្រងថ្មីរួចមក ។ វេជ្ជបណ្ឌិត ចំរើន សំអឿន ជាអ្នកគ្រប់គ្រងថ្មីជំនួសលោកវេជ្ជបណ្ឌិតចាស់ឈ្មោះ សុន ម៉ម ដែលបានទទួលមរណភាពនៅមន្ទីរពេទ្យកាល់ម៉ែតដោយជម្ងឺកាលពីឆ្នាំ១៩៦៤ ។ មន្ទីរពេទ្យនេះបានបំពេញការងាររបស់ខ្លួនរហូតដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមចូលមកកាន់អំណាច ។ បន្ទាប់ពីនោះមកត្រូវបានក្លាយជាកន្លែងឃុំឃាំងដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

ជនរងគ្រោះដែលជាអតីតបុគ្គលិកមន្ទីរពេទ្យវិកលចរិតតាំងពីឆ្នាំ១៩៥៥ ឈ្មោះ ដោក សុខខៃ បានប្រាប់ថា នៅក្រោយឆ្នាំ១៩៧៩ លោកបានឃើញមានស្លាមទម្ពុះជញ្ជាំងដើម្បីស៊ករនុកដែកដែលភ្ជាប់ទៅនឹងខ្នោះដាក់ជើងជនរងគ្រោះ ។ លោកមានប្រសាសន៍ថា ជនរងគ្រោះនៅក្នុងបរិវេណមន្ទីរពេទ្យនេះសុទ្ធតែជនពិការដែលប្រមូលមកពីទីក្រុងភ្នំពេញក៏ដូចជាពីកន្លែងផ្សេងៗទៀត ។ ពួកខ្មែរក្រហមបានយកជនពិការទាំងនោះទៅសម្លាប់ក្រោយពេលធ្វើទារុណកម្មនៅក្នុងបរិវេណមន្ទីរឃុំឃាំងនៃមន្ទីរពេទ្យវិកលចរិត ។ សាកសពដែលបានស្លាប់ហើយនោះត្រូវបានពួកខ្មែរក្រហមយកទៅកប់រួចដាំដើមដូងពីលើផ្នូរនោះក្នុងគំនិតធ្វើជាជីឲ្យដូងលូតលាស់ល្អ ។ ដើមដូងដែលបានដាំជាង ១៣០ដើមកាលពីជំនាន់ប៉ុលពតនៅក្នុងបរិវេណមន្ទីរពេទ្យនេះសុទ្ធតែត្រូវបានកប់សាកសពពីក្រោមទាំងអស់ ។ បច្ចុប្បន្នដើមដូងទាំងនោះរីកលូតលាស់យ៉ាងធំធាត់ស្មើរស្មានមិនដល់ ។ នៅឆ្នាំ១៩៨០នៅឃើញមានខ្នោះជាច្រើនស្ថិតនៅរាយប៉ាយទាំងក្នុងបន្ទប់និងក្រៅបន្ទប់នៃអគារ “ជ” ដែលបច្ចុប្បន្នជាអគារពិនិត្យជម្ងឺទូទៅនៃមន្ទីរពេទ្យជ័យជំនះ ជាពិសេសមានរំពាត់និងតុដែលទំនងជាតុសម្រាប់សួរចម្លើយ ។

រហូតមកដល់សព្វថ្ងៃយើងនៅតែអាចសង្កេតឃើញនៅមានគំនូរខុសប្លែកពីធម្មតាត្រង់ថាគំនូរចាស់ពណ៌ស តែត្រូវប៉ះភ្លិតដោយគំនូរពណ៌ក្រហមបុណ្យ ។ ចម្រឹងដែកនៅតាម



បន្ទប់គ្រប់កន្លែងនៃអគារ “ដ” ដែលមានស្រាប់តាំងពីដើមមក នៅតាមកន្លែងផ្សេងៗដូចជាបន្ទប់រដ្ឋបាលជាដើម ក៏មានការដាក់ជំនួសថែមខ្លះៗទៀត ។ ចម្រឹងដែកដែលត្រូវបានបង្កើតថ្មីនេះ គឺកើតមានឡើងនៅក្នុងជំនាន់ខ្មែរក្រហមនៅកាន់អំណាច ។ ហើយចម្រឹងដែលមានស្រាប់ពីសង្គមចាស់នោះគឺត្រូវបានធ្វើឡើងសម្រាប់ការពារមនុស្សវិកលចរិតមិនឲ្យដើរពាសវាលពាសកាល ។

អគារមួយនេះស្ថិតនៅតាមបណ្តោយថ្ងៃ មានពីរជាន់ និងមានជាង៣០បន្ទប់ ។ ថ្វីដ្បិតតែមានការជួសជុលខ្លះក៏ដោយ អគារមួយនេះហាក់មិនដូចជាអគារសម្រាប់ព្យាបាលអ្នកជំងឺទេ គឺដូចទាំងស្រុងទៅនឹងមន្ទីរឃុំឃាំង ព្រោះមានចម្រឹងដែកបញ្ឈរយ៉ាងជន្រឹងនៅច្រកទ្វារធំមុនពេលចូលទៅកាន់បន្ទប់នីមួយៗ ។ ស្លាកស្នាមទាំងឡាយដូចជាការទម្លុះជញ្ជាំងសម្រាប់ស៊ីករនុកដែកចោះប្រហោងសម្រាប់អ្នកទោសនោម... មិនត្រូវបានលុបបំបាត់ទាំងស្រុងឡើយ ។ នៅក្នុងបន្ទប់នីមួយៗនៃអគារពិនិត្យជំងឺទូទៅ នៅមានស្លាកស្នាមយ៉ាងច្បាស់ក្រឡែតបង្ហាញនូវភាពខុសគ្នាទាំងស្រុងរវាងឥដ្ឋការ៉ូពណ៌ស លឿង និងក្រហម ។ ក្នុងចំណោមជាង៣០បន្ទប់ (ទាំងជាន់ក្រោមនិងជាន់ទី១) មាន២៨បន្ទប់ត្រូវបានពួកខ្មែរក្រហមយកធ្វើជាកន្លែងឃុំឃាំងអ្នកទោស ។ ចំណែកសល់ពីនោះជាបន្ទប់តូចៗដែលជាអតីតបន្ទប់ចែកថ្នាំនិងបង្គន់ ។

ខាងក្រោមនេះជាសម្តីរបស់ជនរងគ្រោះដែលបានដឹងរឿងរ៉ាវជាច្រើននៅក្នុងមន្ទីរពេទ្យនេះតាំងពីមុននិងក្រោយបែកទីក្រុងតាខ្មៅ និងនៅក្រោយឆ្នាំ១៩៧៩÷

**លោក ដោក សុខែ បុគ្គលិកផ្នែករដ្ឋបាលនៅមន្ទីរពេទ្យជ័យជំនះ**

ខ្ញុំមានអាយុ៦៥ឆ្នាំ មានស្រុកកំណើតនៅឃុំតាខ្មៅ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បច្ចុប្បន្នរស់នៅភូមិព្រែកអញ្ចាញ ឃុំព្រែកឫស្សី ស្រុកតាខ្មៅ ខេត្តកណ្តាល ។ ពីឆ្នាំ១៩៥៥ ដល់ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានបម្រើការនៅមន្ទីរពេទ្យវិកលចរិត ហើយនៅក្រោយថ្ងៃរំដោះ ១៩៧៩ ខ្ញុំបានចូលមកមន្ទីរពេទ្យនេះនៅឆ្នាំ១៩៨០ ។ កិច្ចការរដ្ឋបាលជាកិច្ចការរបស់ខ្ញុំតាំងពីចូលបម្រើការងារដំបូងរហូតដល់ចូលនិវត្តន៍នៅឆ្នាំ១៩៩២ ។ កាលពីជំនាន់ខ្មែរក្រហមកាន់អំណាច (១៩៧៥-៧៩) ខ្ញុំពុំបានរស់នៅជាប់នឹងមន្ទីរពេទ្យនេះហើយក៏មិនបានរស់នៅក្នុងខេត្តកណ្តាលដែរ គឺត្រូវបានជម្លៀសទៅនៅឯខេត្តពោធិ៍សាត់ ឯណោះបន្ទាប់ពីមានការដេញយ៉ាងសង្អើញពីពួកខ្មែរក្រហមពីររូប (មិនស្គាល់ឈ្មោះ) នៅយប់ថ្ងៃទី៤ ខែឧសភា ឆ្នាំដដែល ។

រយៈពេល២០ថ្ងៃក្រោយវាយបែកទីក្រុងតាខ្មៅនាថ្ងៃ១៥ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវរស់នៅលាក់ខ្លួនរហូតជាមួយហ្វូងមនុស្សវិកលចរិតដល់ថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៥ ។ ពួកខ្មែរក្រហមបានមកដេញបុគ្គលិកមន្ទីរពេទ្យចេញទាំងអស់ដោយប្រាប់ថា ប្រសិនបើនៅតទៅទៀតពិតជាត្រូវពួកអាមេរិកមកទម្លាក់គ្រាប់បែកស្លាប់មិនខាន ។ គ្រួសាររបស់ខ្ញុំមានសមាជិកទាំងអស់១៣នាក់ ។ ក្នុងរយៈកាលនោះ (ថ្ងៃទី១៥ ខែមេសា ដល់ថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៥) ខ្ញុំបានឃើញហេតុការណ៍កើតឡើងដូចជាមានការបាញ់ទម្លុះសោរទ្វារបញ្ចេញមនុស្សវិកលចរិតឲ្យដើរពាសវាលពាសកាលក្នុងបរិវេណពេទ្យនិងក្រៅមន្ទីរពេទ្យ បាញ់ទម្លាយឃ្លាំងគ្រប់គ្រងឪសថ ។ល ។ នៅថ្ងៃទី១៦ ខែមេសា ឆ្នាំដដែល ពួកខ្មែរក្រហមបានដញ្ជូនឥវ៉ាន់ដែលប្រមូលបាននោះយកទៅដាក់ឡានរួចដឹកយកទៅអស់ដោយមិនដឹងយកទៅទីណា ។ ក្នុងរយៈពេល២០ថ្ងៃនៃការស្នាក់នៅរបស់ខ្ញុំជាមួយពួកមនុស្សវិកលចរិតនានា ខ្ញុំត្រូវបានក្មេងខ្មែរក្រហមម្នាក់អាយុប្រមាណ១២-១៣ឆ្នាំបាញ់ដោយកាំភ្លើងកាប៊ីនសំដៅទៅរកខ្ញុំនៅក្នុងបន្ទប់មួយនៃអគារដីក្លែរ៉ុបុល ដែលបច្ចុប្បន្នជាអគាររបេង ។ សំណាងល្អគ្រាប់ដែលហើរចេញពីកាណុងកាំភ្លើងនោះមិនបានហោះទៅត្រូវខ្ញុំឡើយ ។ បន្ទាប់មក ក្មេងខ្មែរក្រហមនោះបានដើរចេញទៅយ៉ាងព្រងើយក្រោយពីការបាញ់មួយគ្រាប់នេះមក ។ ខ្ញុំថែមទាំងបានឃើញពួកមនុស្សវិកលចរិតមួយចំនួនដែលដើរពាសវាលពាសកាលនោះ ទៅរើសយកខោអាវទាហានដែលពួកទាហាន លន់ ណុល បានដោះចោលនៅពីមុខទីធ្លាក៏ដូចជានៅខាងក្រោមន្ទីរពេទ្យយកមកស្លៀក ។ ប្រសិនបើមានកាំភ្លើងទៀតនោះ មនុស្សវិកលចរិតទាំងនោះនឹងយកកាំភ្លើងនោះមកកាន់រួចធ្វើពុកក្អេងក្អាងហាក់ដូចជាខ្លួនជានាយទាហានពិតៗ ។ ក្នុងចំណោមអ្នកទាំងនោះ មានខ្លះត្រូវបានពួកខ្មែរក្រហមសម្លាប់ភ្លាមៗ និងខ្លះទៀតត្រូវបានកៀរឲ្យទៅកន្លែងឆ្ងាយៗពីមន្ទីរពេទ្យ ព្រោះពួកខ្មែរក្រហមយល់ថាជាទាហានរបស់ពួក លន់ ណុល យ៉ាងពិតប្រាកដ ។ កាលនោះ (ពាក់កណ្តាលខែមេសា ឆ្នាំ១៩៧៥) ខ្ញុំត្រូវបានពួកខ្មែរក្រហមឲ្យនៅចិញ្ចឹមជ្រូកព្រមទាំងកាប់ជ្រូកនៅពេលដែលពួកវាត្រូវការបរិភោគ ។ ដោយសារតែមានឱកាសចេញក្រៅយ៉ាងនេះហើយទើបបានជាខ្ញុំដឹងរឿងរ៉ាវដូច្នេះ ។ ប្រហែលជាម៉ោង៨យប់ថ្ងៃទី៨ ខែឧសភា ឆ្នាំដដែល ខ្ញុំត្រូវបានពួកខ្មែរក្រហមពីរនាក់មកគោះទ្វារព្រមទាំងហៅឈ្មោះខ្ញុំចំៗតែម្តងថា "ខែ ខែ ចេញមកក្រៅមានការបន្តិច" ។ ទ្វាររបើកឡើងខ្ញុំបានឃើញមនុស្សពីរនាក់មានកាន់ពិលពីរនៅក្នុងដៃ ។ ក្នុងនោះមានម្នាក់បានដកកាំភ្លើងខ្លីមកភ្ជង់ចំដើងសក់របស់ខ្ញុំដោយចោទថាខ្ញុំជាប្រធានមន្ទីរពេទ្យ ។ ពេលនោះខ្ញុំបានប្រាប់ទៅវិញថា ខ្ញុំមិនមែនជាប្រធានមន្ទីរពេទ្យទេ គឺជាមនុស្សវិកលចរិតដូចគេដូចឯងដែរ តែនៅក្នុងលក្ខណៈច្បាប់របស់ពេទ្យខ្ញុំជាបុគ្គលិកពេទ្យនៅមន្ទីរពេទ្យស្រុកកំពង់ហ្លួងឯណោះ ប៉ុន្តែមានជំងឺទើបត្រូវបានបញ្ជូនមកកាន់មន្ទីរពេទ្យនេះ ដើម្បីជាទម្លាប់ធ្វើការក្នុងការលើកក្រដាសលើកនេះលើកនោះ ប៉ុន្តែឲ្យសរសេរជាផ្លូវការមិនបានទេ ព្រោះខ្ញុំជាមនុស្សឆ្កួតទៅហើយ ។ ក្រោយពីបានស្តាប់ហេតុផលរួច ខ្មែរក្រហមពីររូបនោះបានដេញខ្ញុំចេញពីបរិវេណមន្ទីរពេទ្យដោយដាក់កម្រិតថា "ខែឯងត្រូវតែចេញនៅថ្ងៃស្អែកដាច់ខាត" ។

ក្នុងអំឡុងពីថ្ងៃ១៥ ខែមេសា ដល់ថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៥ ជីវិតរបស់ខ្ញុំព្រមទាំងគ្រួសារបានរស់ក្នុងសភាពភ័យខ្លាចយ៉ាងខ្លាំង ។ ក្រោយពេលចាកចេញពីមន្ទីរពេទ្យខ្ញុំបានធ្វើដំណើររហូតទាល់តែដល់ខេត្តពោធិសាត់នៅឆ្នាំ១៩៧៦ ។

ប៉ុន្តែនៅក្រោយឆ្នាំ១៩៨០ ខ្ញុំបានវិលមករស់នៅស្រុកកំណើតវិញជាមួយកូនប្រុសម្នាក់និងកូនស្រីម្នាក់ ។ ខ្ញុំក៏បានវិល


លោក ដោក សុខៃ បង្ហាញស្នាមប្រហោងជញ្ជាំងមន្ទីរពេទ្យដែលពួកខ្មែរក្រហមបានចោះ

ត្រឡប់មកមន្ទីរពេទ្យវិកលចរិតវិញដើម្បីរៀបចំមន្ទីរពេទ្យឡើងវិញសម្រាប់បម្រើដល់ប្រជាជនដែលនៅសេសសល់ពីការស្លាប់ ។ ខ្ញុំបានឃើញមានស្លាកស្នាមម្រាមដៃប្រឡាក់ឈាមដែលមានស្នាមអូសពីលើមកក្រោមនៅជាប់នឹងជញ្ជាំងបន្ទប់នៃអគារមួយដែល

ស្ថិតនៅតាមបណ្តោយថ្ងៃដែលសព្វថ្ងៃហៅថា អគារ“ជ” ឬអគារពិនិត្យជំងឺទូទៅ ។ ខ្នោះជើងជាច្រើនដែលស្ថិតនៅពាសពេញក្នុងនិងក្រៅបន្ទប់នៃបរិវេណមន្ទីរពេទ្យ ត្រូវបានខ្ញុំរួមជាមួយបុគ្គលិកពេទ្យមួយចំនួនទៀតប្រមូលយកទៅបោះចោលនៅប៉ែកខាងក្រោយនៃមន្ទីរពេទ្យ គឺយកទៅគរនៅក្នុងចម្ការចេកនិងក្រោមដើមម៉ៃសាក់ ។ ខ្នោះទាំងនេះមានរាងជាអក្សរអ៊ុយ (U) រួចមានពត់មូលក្រវង់នៅផ្នែកខាងក្បាលទាំងពីរសម្រាប់ស៊កនុកដែកមួយដែលមានទំហំ២០លី និងមានចាក់សោរផង ។ បន្ទប់នីមួយៗនៃអគារ“ជ”សុទ្ធតែមានស្នាមបោះទម្លុះប្រហោងនៅសងខាងមាត់ទ្វារចូលដើម្បីស៊កនុកដែកដែលភ្ជាប់ជាមួយខ្នោះដាក់កជើងអ្នកទោស រួចចាក់សោរភ្ជាប់ជាមួយនឹងគន្លឹះដែកដែលស្ថិតនៅប៉ែកខាងក្រៅបន្ទប់ ។ សព្វថ្ងៃប្រហោងទាំងនោះត្រូវបានខ្ញុំនិងបុគ្គលិកនៃមន្ទីរពេទ្យដទៃទៀតបិទភ្ជិតតាំងពីអំឡុងទសវត្សរ៍ឆ្នាំ៨០ម្ល៉េះ ។ ឥដ្ឋការ៉ូដែលបានប្រើសម្រាប់ប៉ះប្រហោងទាំងនោះមិនត្រូវបានបិទឲ្យដូចឥដ្ឋការ៉ូចាស់ឡើយ ព្រោះកាលនោះ (ឆ្នាំ១៩៨០) ខ្ញុំបានដើររើសយកឥដ្ឋការ៉ូពីនេះបន្តិចពីនោះបន្តិចយកមកប៉ះ ។

ដើម្បីឲ្យបានដឹងច្បាស់ជាងហ្នឹងទៅទៀតសូមតាមដានពីបទសម្ភាសន៍ជាមួយលោក សាយ ពេញ ប្រធានផ្នែករដ្ឋបាលនៃមន្ទីរពេទ្យជ័យជំនះ និងជាមនុស្សដំបូងដែលបានចូលមកបម្រើការនៅក្នុងមន្ទីរពេទ្យនេះនៅក្រោយឆ្នាំ១៩៧៩ដូចខាងក្រោមនេះ÷

**លោក សាយ ពេញ ប្រធានផ្នែករដ្ឋបាលនៃមន្ទីរពេទ្យជ័យជំនះ**

បច្ចុប្បន្នខ្ញុំមាននាទីជាប្រធានផ្នែករដ្ឋបាលនៃមន្ទីរពេទ្យជ័យជំនះ ។ ក្នុងរបបសីហនុខ្ញុំធ្វើការនៅក្នុងមន្ទីរពេទ្យអង្គឌួង ។ លុះក្រោយឆ្នាំ១៩៧៩ ក្នុងខែមិថុនា ខ្ញុំបានចូលមកធ្វើការនៅក្នុងមន្ទីរពេទ្យវិកលចរិតដែលជាមន្ទីរពេទ្យជ័យជំនះបច្ចុប្បន្ននេះតាមសំណើរសុំរបស់មន្ទីរខេត្តកណ្តាល ។ ពេលមកដល់ដំបូងខ្ញុំបានឃើញមន្ទីរពេទ្យនេះមានសុទ្ធតែព្រៃក្រាស់ៗសឹងតែមើលមិនឃើញពីអគារមួយទៅអគារមួយទៀត ។ ខ្ញុំនិងលោក ផូវ ហ៊ិន (មិនបានបញ្ជាក់ពីមុខងារ ទីលំនៅ ឬស្លាប់-រស់ទេ) ដែលជាអ្នកចូលមកធ្វើការមុនគេនោះ បានទៅចូលរៀបចំតាមបន្ទប់នីមួយៗនៃគ្រប់អគារទាំងអស់ក្នុងមន្ទីរពេទ្យ ដើម្បីរៀបចំឲ្យអ្នកជំងឺស្នាក់នៅព្យាបាល ។ ក្នុងពេលរៀបចំបន្ទប់នៅក្នុងអគារ“ជ” ខ្ញុំឃើញមានសុទ្ធតែខ្នោះឃ្នាង ឡោស៊ី...ព្រមទាំងមានតុ រំពាត់... ។ តាមការសន្និដ្ឋានរបស់ខ្ញុំទីនេះប្រហែលជាកន្លែងសួរចម្លើយនិងជាកន្លែងឃុំឃាំងអ្នកទោស ។ នៅតាមបន្ទប់នីមួយៗមានស្នាមបោះប្រហោងសម្រាប់ឲ្យអ្នកទោសនោម ។ នៅពេលដែលខ្ញុំចូលមកដល់មន្ទីរពេទ្យនេះ ដំបូងខ្ញុំបានឮអ្នកជំងឺដែលមានសភាពធ្ងន់ធ្ងរអស់កម្លាំង...ដោយសារការបង្អត់អាហាររបស់ខ្មែរក្រហមនិយាយប្រាប់ថា មន្ទីរពេទ្យនេះជាគុកមួយសម្រាប់ដាក់តែជនពិការដែលប្រមូលមកពីទីក្រុងឬពីកន្លែងនានាក្នុងប្រទេស ។ ជនពិការទាំងនោះត្រូវបានពួកខ្មែរក្រហមបញ្ជាឲ្យជីកអណ្តូងចំនួនបីក្នុងបរិវេណមន្ទីរពេទ្យប៉ែកខាងជើង ។ អណ្តូងទាំងបីដែលបានជីកនោះនឹងត្រូវយកធ្វើជាកន្លែងកប់មនុស្សនៅថ្ងៃ២០ ខែឧសភា ឆ្នាំ១៩៧៥ ដែលជាថ្ងៃសម្លាប់មនុស្សដំបូងរបស់ពួកខ្មែរក្រហមនៅទីនេះ ។ សព្វថ្ងៃមន្ទីរពេទ្យនេះមានសុទ្ធតែដើមដូងជាជួរៗតាមបណ្តោយដងផ្លូវក្នុងមន្ទីរពេទ្យ ដែលពីជំនាន់សីហនុលន់ណុល មិនដែលមានសោះ ។ តាមរបាយការណ៍ដែលខ្ញុំបានធ្វើឡើងគឺមានចំនួនជាង១៣០ដើម ។ ដើមដូងទាំងនេះត្រូវបានដាំនៅក្នុងជំនាន់ប៉ុលពត ។ មុនពេលដាំដើមដូងនេះពួកខ្មែរក្រហមបានយកសាកសពមួយមកកប់សិន បន្ទាប់មកក៏យកដើមដូងមួយមកដាំពីលើសាកសពនោះ ។ មានសាកសពចំនួនប្រហែលជាង១៣០នាក់នៅពីក្រោមដើមដូងជាង១៣០ដើមនោះ ។ សាកសពដែលត្រូវយកមកកប់នេះគឺសុទ្ធសឹងជាជនពិការទាំងអស់ ។ នៅជុំវិញបរិវេណខាងក្រៅមន្ទីរពេទ្យនោះមានសុទ្ធតែជនពិការដែលភាគច្រើនជាកម្មាភិបាលនិងជាអ្នកធ្លាប់មានគុណសម្បត្តិរបស់ពួកខ្មែរក្រហម មកស្នាក់នៅតាមបញ្ជារបស់ថ្នាក់លើ ព្រមទាំងមានរៀបការប្រពន្ធស្អាតៗដែលជាកូនរបស់អ្នកស្រុកឲ្យពួកជនពិការទាំងនោះទៀតផង ។ ជនពិការដែលត្រូវមកជាប់នៅមន្ទីរឃុំឃាំងនៅក្នុងមន្ទីរពេទ្យនេះ ភាគច្រើនយកមកពីភ្នំពេញដែលសុទ្ធតែជាអ្នកមានបុណ្យសក្តិគ្រាន់បើ ។ ចំណែកឯជនពិការដែលស្ថិតនៅជាប់នឹងបរិវេណខាងក្រៅមន្ទីរពេទ្យវិញ មិនត្រូវបានយកបន្តមកដាក់នៅក្នុងមន្ទីរសន្តិសុខនេះទេ ព្រោះជាកម្មាភិបាលនិងជាអ្នកមានគុណសម្បត្តិរបស់ពួកខ្មែរក្រហម ។

**វេង ពន្សូ វ៉ាស៊ី**

**(តពីលេខមុន)** មានសៀវភៅសរសេរអំពីផ្នែកវេជ្ជសាស្ត្រជាច្រើន ត្រូវបានរកឃើញនៅមន្ទីរស-២១ ប៉ុន្តែពុំមានដាក់ឈ្មោះគ្រូបង្រៀន សិស្ស និងមេរៀន ឲ្យបានច្បាស់លាស់ទេ ។ កូនសៀវភៅសរសេរតូចអាចដាក់ក្នុងហោប៉ៅបាន សរសេរថា ជួនកាលពិសោធន៍ប្លែកៗត្រូវបានធ្វើឡើងដោយបុគ្គលិកពេទ្យ ដូចជាបង្ហូរឈាមអ្នកទោសទាល់តែស្លាប់ និងដាក់សាកសពទៅក្នុងអាងទឹក ហើយរង់ចាំមើលថាតើយូរប៉ុណ្ណាទើបសាកសពនោះអណ្តែតឡើង ។ នៅកន្លែងផ្សេងៗទៀតតាមជនបទ ជួនកាលមានការធ្វើពិសោធន៍វះកាត់ដែលមានគ្រោះថ្នាក់ដល់ជីវិតទៅលើអ្នកទោសដែលត្រូវបានធ្វើឲ្យសន្លប់ ដើម្បីជាមេរៀនសរីរាង្គដាក់ស្តែងបង្រៀនដល់កម្មាភិបាលពេទ្យខ្មែរក្រហម ។ ពិសោធន៍បែបនេះអាចកើតមាននៅក្នុងគុកស-២១ ហើយមិនមែនជាការភ្ញាក់ផ្អើលឡើយ ប្រសិនបើរបាយការណ៍ទាំងនោះមិននៅសល់ទេនោះ ។

### ប្រវត្តិរបស់បុគ្គលិកមន្ទីរ ស-២១

តើមនុស្សធ្វើការនៅក្នុងអង្គភាពនានា នៅក្នុងមន្ទីរស-២១ជាមនុស្សប្រភេទណាទៅ? ឌុច ចាន់ និង ប៉ុន ជាជនជាតិខ្មែរកាត់ចិន ។ ស្ថិតក្នុងវ័យ៣០ឆ្នាំ អ្នកទាំងបីនាក់នោះធ្វើជាគ្រូបង្រៀន ។ ហើយអ្នកសួរចម្លើយជាន់ខ្ពស់ផ្សេងទៀតឈ្មោះ បូ និង ទុយ ប្រហែលមានប្រវត្តិប្រហាក់ប្រហែលនេះដែរ ។ ភាគច្រើននៃអ្នកដែលស្ថិតនៅក្រោមបញ្ជារបស់អ្នកខាងលើនេះគឺសុទ្ធសឹងតែជនជាតិខ្មែរដែលមកពីតំបន់ជនបទដាច់ស្រយាល ។ មុនពេលចូលបដិវត្តន៍ក្នុងសង្គ្រាមស៊ីវិល បុគ្គលិកភាគច្រើននៅមន្ទីរស-២១គឺជាសិស្សសាលាបឋមសិក្សា សាមណេ ឬក៏អ្នកជួយសម្រាលការងារស្រែចម្ការឪពុកម្តាយរបស់ខ្លួន ។ មានមួយចំនួនតូចប៉ុណ្ណោះដែលរស់នៅទីក្រុង ឬក៏ស៊ីឈ្នួលគេ ។



**សម្លេងពីមន្ទីរ ស-២១**
**វគ្គទី២: ស្ថាប័នស្វយ័ត**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

ក្នុងចំណោមបុគ្គលិកធ្វើការនៅស-២១ចំនួន១៦៦នាក់ ដែលបានបំពេញប្រវត្តិរូបនៅក្នុងឆ្នាំ១៩៧៦ពេលដែលខ្លួនមកធ្វើការនៅគុក មានបុគ្គលិក៤៤នាក់សរសេរថាខ្លួនជា“កសិករក្រីក្រ” ៩៩នាក់ជា“កសិករកណ្តាលថ្នាក់ក្រោម” ១៦នាក់ជា“កសិករកណ្តាល” ១នាក់ជា“កម្មករ” ហើយ៦នាក់ទៀតជា“វណ្ណៈអនុធន” ។ ៥នាក់ចុងក្រោយពេលដែលចូលក្នុងជួរបដិវត្តន៍គឺជាសិស្សសាលាធម្មតា ។ ចំណែកម្នាក់ទៀតជាគ្រូបង្រៀន ។ ដោយឲ្យមានបុគ្គលិកប្រុសច្រើនជាងបុគ្គលិកស្រី ប្រវត្តិរបស់អ្នកធ្វើការនៅមន្ទីរស-២១ដូចគ្នាទៅនឹងរចនាសម្ព័ន្ធវណ្ណៈនៅក្នុងសង្គមខ្មែរនៅជនបទមុនបដិវត្តន៍ ដែលក្នុងសង្គមនោះគ្រួសារភាគច្រើនមានកម្មសិទ្ធិដីធ្លី ហើយត្រូវបានចាត់ទុកជា“កសិករកណ្តាល” ។

ខ្មែរក្រហមដូចជាដៃគូរបស់ខ្លួននៅក្នុងលទ្ធិម៉ៅរបស់ចិន គឺឲ្យតម្លៃទៅលើការគ្មានបទពិសោធន៍និងអវិជ្ជា ដោយចូលចិត្តអ្នកដែលនៅក្នុងឃ្លាមួយរបស់ ម៉ៅ និយាយថា “ក្រហើយស្អាតស្អំ” ជាងជនពុករលួយនាយទុន ឬអ្នកដែលបានរៀនសូត្រជ្រៅជ្រះ ។ ដោយមានការសរសើរចំពោះគំនិត“ក្រហើយស្អាតស្អំ”នេះ ម៉ៅ បានអះអាងថា “ក្រដាសសសុទ្ធគ្មានទទួលនូវបន្ទុកអ្វីឡើយ ហើយអក្សរឬគំនូរស្អាតៗអាចត្រូវបានសរសេរឬគូរនៅលើក្រដាសសនោះ” ។ នៅក្នុងប្រទេសកម្ពុជា “បងៗថ្នាក់លើ” ជាអ្នកទទួលខុសត្រូវខាងធ្វើចំណារនៅលើក្រដាសនោះ ហើយ “បងៗ”ដែលមើលការខុសត្រូវនៅក្នុងគុកនិងស៊ាំនឹងការគោរពបញ្ជាដែលភាគច្រើនចម្លងមកពីការរៀនសូត្រជ្រៅជ្រះរបស់ខ្លួននៅតាមសាលារៀននោះ មានការពេញចិត្តណាស់ក្នុងការចម្លងនូវគំនិតរបស់ខ្លួនទៅឲ្យអ្នកផ្សេងទៀត ។ អ្នកទាំងនោះបានជ្រើសរើសមនុស្សដែលមានការហ៊ឹកហ៊ឺនតិចតួចនិងមានការ

គោរពទិនលំទោន មកធ្វើជាអ្នកធ្វើការនៅក្រោមបញ្ជារបស់ខ្លួន ។ ក្នុងចំណោមអ្នកចូលធ្វើការទាំងអស់ដែលបំពេញបែបបទធ្វើការនៅមន្ទីរស-២១នៅឆ្នាំ១៩៧៦ មានតែ២៥នាក់ប៉ុណ្ណោះដែលមានអាយុលើសពី២៥ឆ្នាំ ។ ២០នាក់ស្ថិតនៅក្រោមអាយុ១៨ឆ្នាំ ។ ១០៨នាក់មានអាយុចន្លោះ១៨-២០ឆ្នាំ ។ គក ស្រស់ ដែលមានអាយុ២៥ឆ្នាំពេលមកដល់ស-២១ បាននិយាយថា អ្នកដែលត្រូវបានជ្រើសរើសមកធ្វើការងារនៅស-២១នៅពាក់កណ្តាលឆ្នាំ១៩៧៧ មានវ័យក្មេងជាងអ្នកដែលត្រូវបាន


គក ស្រស់ អាយុ ២៦ឆ្នាំ
ថ្ងៃចូលបដិវត្ត ១៥.៣.៧៤

ជ្រើសរើសមកធ្វើការកាលពីដំបូងដែរច្រើនណាស់ ។

អ្នកធ្វើការថ្នាក់ក្រោមស្ទើរតែទាំងអស់នៅក្នុងគុក សុទ្ធតែមានវ័យក្មេងៗហើយនៅលីវ ។ តាមប្រវត្តិសាស្ត្រពិភពលោក បុរសជាភេទងាយនឹងត្រូវបានបង្ខូចទម្លាប់និងងាយបង្ខូចទម្លាប់ដោយខ្លួនឯងណាស់ ក្នុងការចាប់យកអាជីពថ្មីជាមួយអ្នកដទៃដែលមានវ័យប្រហាក់ប្រហែលគ្នា ។ ការហាមប្រាមក្នុងការធ្វើដំណើរ ការបម្រើយោធា ជីវិតផ្នែកសាសនា ការឆក់ប្លន់ ការធ្វើព្យុហយាត្រា ការធ្វើការងារជាអ្នកស៊ីឈ្នួល និងការសិក្សានៅសកលវិទ្យាល័យ គឺជាសញ្ញាណនៃការឆ្លងកាត់ពីវ័យកុមារមកវ័យចេះដឹងខុសត្រូវ ។ នៅក្នុងបដិវត្តន៍កម្ពុជាមានស្ត្រីក្មេងៗជាច្រើនពាន់នាក់ក៏ត្រូវបាន «រំដោះ» ឲ្យធ្វើជាទាហាន កម្មាភិបាល និងថ្នាក់ដឹកនាំស្រុក ជាឋានៈមិនអាចគិតដល់ដែលស្ត្រីខ្មែរមានកាលពីមុនបដិវត្តន៍ ។ ជនជាតិកម្ពុជាក្មេងៗដែលច្បាំងគ្នាដោយដៃទាំងពីរ ដក់ចិត្តក្នុងការធ្វើសង្គ្រាមណាស់ ។ ក្នុងខណៈដែលទាហានជាច្រើនត្រូវបានឃុំខ្លួននៅមន្ទីរស-២១ ត្រូវបានដកហូតឋានៈដោយសារតែខ្លួននឹកឪពុកម្តាយនោះ អ្នកទោសម្នាក់បានបញ្ជាក់ក្នុងចម្លើយសារភាពរបស់ខ្លួនថា "ខ្ញុំចូលបដិវត្តដោយសារទឹងនឹងឪពុកម្តាយខ្ញុំ" ។ មានអ្នករួចរស់ជីវិតពីសម័យកម្ពុជាប្រជាធិបតេយ្យជាច្រើននាក់ដែលឥឡូវនេះស្ថិតក្នុងវ័យពាក់កណ្តាល៣០ឆ្នាំ ពេញចិត្តចំពោះសេរីភាពរបស់ខ្លួនក្នុងការធ្វើដំណើរជុំវិញប្រទេសក្នុងនាមជាកងកុមារវ័យជំទង់ ដូចជាករណីរបស់សន្តិសុខក្រហមរបស់ ម៉ៅ នៃប្រទេសចិនដែរ ។

អ្នកធ្វើការនៅមន្ទីរស-២១ភាគច្រើនបាន«ចូលបដិវត្ត» ក្នុងវ័យក្មេងបំផុត ។ ញ៉ែម អេន ចូលបដិវត្តតាំងពីអាយុ១០ឆ្នាំម្ល៉េះ ។ ៦ឆ្នាំក្រោយមក ពេលដែលគាត់ចូលមកមន្ទីរស-២១ គាត់បានធ្វើការជាមួយមនុស្សដែលមានវ័យប្រហែលគាត់ជាច្រើននាក់ ។ រូបថតរបស់អ្នកដែលពេញចិត្តនឹងខ្លួនឯងកុមារវ័យជំទង់ដែលមានពាក់មួកកន្ទឹបចិនញញឹមពព្រាយត្រូវបានព្យួរលម្អតាមជញ្ជាំងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ចំពោះភាគច្រើននៃកុមារទាំងនោះយល់ថាអង្គការគឺជាឪពុកម្តាយរបស់ខ្លួន ។ កុមារទាំងនោះត្រូវបានអង្គការចម្រាញ់តាមបញ្ជារបស់ "បងៗ" ឲ្យមានភាពសាហាវយង់ឃ្នង ។

ក្មេងជំទង់ៗបានទទួលនូវកេរ្តិ៍ឈ្មោះល្បីពីប្រទេសជាច្រើនខាងភាពងាយទទួលការបត់បែន គំនិតនិយមការស្រេកឃ្លានសុំការអនុញ្ញាត និងកាយវិការឃោរឃៅរបស់ខ្លួន ។ និយាយទៅកាន់ហ្វីលីព ហ្គូរីក ក្នុងឆ្នាំ១៩៩៦ ចិត្តវិទូមួយរូបឈ្មោះ រីឆាដ ម៉ូលីកា បានរែកញែកអំពីអ្នកធ្វើសឹកជាតិហ៊ូទូនៅប្រទេសរ៉ាន់ដា ដែលមានអាយុនិងប្រវត្តិប្រហាក់ប្រហែលគ្នានឹងក្រុមធ្វើការងារនៅមន្ទីរស-២១ ។ "តាមគំនិតខ្ញុំ ចិត្តសាស្ត្ររបស់ក្មេងមិនស្មុគស្មាញដល់ថ្នាក់នោះឡើយ ហើយអ្នកដែលប្រព្រឹត្តអំពើឃោរឃៅភាគច្រើនក្នុងសភាពបែបនេះគឺជាស្ត្រីភេទក្មេងៗ ។ នៅលើផែនដីយើងនេះ មនុស្សដែលគ្រោះថ្នាក់បំផុតគឺស្ត្រីភេទដែលមានវ័យក្មេងៗ ពីព្រោះក្មេងទាំងនោះងាយនឹងឆ្លើយតបនឹងអំណាចដែលបញ្ជាទៅលើខ្លួន និងរង់ចាំតែទទួលការអនុញ្ញាត


ម៉ោង ថា អាយុ ១៩ឆ្នាំ
ថ្ងៃចូលបដិវត្ត ១.២.៧៣

ប៉ុណ្ណោះក្នុងការធ្វើអ្វីមួយ ។ ក្រុមស្ត្រីក្មេងៗទាំងនេះត្រូវបានលើកទឹកចិត្តចំពោះការចូលខ្លួនទៅក្នុងប្រព័ន្ធឋានានុក្រម និងដើម្បីមានជំនឿថាខ្លួនកំពុងតែកសាងឋានសួគ៌នៅលើផែនដី ។ ក្មេងៗមានគំនិតនិយមណាស់ ហើយអំណាចគឺជាអ្នកធ្វើឲ្យក្មេងទាំងនោះរងគ្រោះ» ។

បញ្ហាដែលកើតឡើងចំពោះក្មេងៗនៅគុកទួលស្លែងគឺបណ្តាលមកពីក្មេងទាំងនោះ«ក្រីក្រហើយស្អាតស្អំ» ។ ការប្រឡូកជាមួយវិន័យបដិវត្តន៍ដោយមិននិយាយដល់គំនិតម៉ាក្ស-លេនីនផង គឺកើតឡើងដោយមានលក្ខណៈជាការជំរុញជាសន្ទេបនិងគ្មានសណ្តាប់ធ្នាប់ ។ អ្វីដែលក្មេងទាំងនោះធ្លាប់បានរៀនតាមរយៈវគ្គសិក្សាផ្សេងៗ គឺមិនអាចធានាបាននូវទម្លាប់ធ្វើការងារល្អទេ ។ ចំពោះមនុស្សមានវ័យចំណាស់ជាងខ្លួនពិបាកនឹងទប់ទល់នូវថាមពលពិតៗរបស់ក្មេងៗ ទាំងនោះដែលមានផលប្រយោជន៍ចំពោះបដិវត្តន៍ណាស់ ។ នៅក្នុងអំឡុងពេលខ្លីមួយក្រោមរបបកម្ពុជាប្រជាធិបតេយ្យ មានក្មេងទាំងប្រុសទាំងស្រីជាច្រើននាក់មិនអាចទទួលការអប់រំបាន ដូចដែលអ្នកនាំពាក្យរបស់បក្សបានកត់សម្គាល់ដោយក្តីសោកស្តាយនៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីកាលពីឆ្នាំ១៩៧៥ថា «និយាយអំពីក្មេងៗដែលមិនមានការហ្វឹកហាត់ក្មេងទាំងនោះមានការស្មោះត្រង់ អារម្មណ៍ផ្តោតមូល និងក្លាក្លៃ ។ ទាំងនេះគឺជាចំណុចខ្លាំងរបស់ក្មេងៗ ។ ចំពោះកន្លះខាតផ្សេងៗបងប្អូនក្មេងៗរបស់យើងនៅលេងច្រើនណាស់ វប្បធម៌របស់គាត់នៅខ្សោយហើយមិនចេះអក្សរ និងមិនចេះដោះស្រាយរាល់ការលំបាកដែលកើតឡើងពីការងាររបស់ខ្លួនឡើយ» ។

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្តួលរំលំ អៀង សារី បានធ្វើការពន្យល់អំពីប្រវត្តិវិនាសកម្មរបស់កម្ពុជាប្រជាធិបតេយ្យទៅកាន់អ្នកកាសែតអាមេរិកាំងឈ្មោះ ហេនរី ខាម ថា «យើងមិនបានជ្រើសរើសបុគ្គលិករដ្ឋឲ្យបានត្រឹមត្រូវ» ។ អៀង សារី បាននិយាយទាំងមិនស្មោះត្រង់ថា «យើងបានបាត់បង់ការគ្រប់គ្រងខ្លះ» ។ អៀង សារី ព្យាយាមបញ្ចៀសមិននិយាយថា កម្ពុជាប្រជាធិបតេយ្យ«ជ្រើសរើសបុគ្គលិក» របស់ខ្លួនពីមជ្ឈដ្ឋានអ្នកដែលមានការអប់រំទាបបំផុតនៅក្នុងស្រុក ហើយបណ្តេញអ្នកដែលកំពុងតែធ្វើការចេញ ព្រមទាំងសម្លាប់អស់ជាច្រើនពាន់នាក់ដោយគ្មានរកហេតុផលនោះទេ ។

មានអ្នកធ្វើការនៅមន្ទីរស-២១តិចណាស់ដែលអាចស្ថិតនៅក្នុងភាពជាជនបដិវត្តបានយូរគ្រាន់បើ ។ មានតែ២៩នាក់ដែលបានបំពេញបែបបទបុគ្គលិកកាលពីឆ្នាំ១៩៧៦ បានចូលបដិវត្តន៍មុនឆ្នាំ១៩៧៣ ពេលដែលកងទ័ពវៀតណាមដកថយពីកម្ពុជា និងដោយសារយុទ្ធនាការទម្លាក់គ្រាប់បែកអាមេរិកាំងស្កាត់ពួកខ្មែរក្រហមនៅទីក្រុងភ្នំពេញ ។ បុគ្គលិកចំនួន៥៨នាក់បានចូលបដិវត្តនៅក្នុងឆ្នាំនោះ ៤៣នាក់ចូលក្នុងឆ្នាំ១៩៧៤ និង៤២នាក់ចូលពីរ-បីខែមុនឆ្នាំ១៩៧៥ ។ ហើយ៥នាក់ចុងក្រោយចូលក្រោយពីការវាយបែកទីក្រុងភ្នំពេញ ។ វគ្គសិក្សាដែលបុគ្គលិកម្នាក់ៗត្រូវទទួលមុនពេលចូលបម្រើការនៅមន្ទីរស-២១ គឺវគ្គសិក្សានយោបាយដែលមានរយៈពេល២សប្តាហ៍ធ្វើឡើងនៅសាលាបច្ចេកទេសមួយនៅតាខ្មៅ ក្រុម២៥ បង្រៀនដោយ«បងទុយ»ដែលក្រោយមកធ្វើជាអ្នកសួរចម្លើយនិងគ្រប់គ្រងរដ្ឋបាលនៅឯមន្ទីរស-២១ ។

ចំពោះប្រជាជនជាច្រើនទៀត សាលានោះគឺជាកន្លែងទីមួយហើយដែលខ្លួនបានជួបជុំគ្នារៀននូវអ្វីដែលទើបតែបង្កើតថ្មីសុទ្ធសាធ ។ ប្រសិនបើវគ្គសិក្សាតាំងពីសម័យកម្ពុជាប្រជាធិបតេយ្យធ្វើជាមាគ៌ាបង្ហាញផ្លូវមែននោះ ម្ល៉េះសមអ្នកដែល គីម ទុយ បង្រៀនប្រហែលជាបានស្តាប់នូវបទខុទ្ទេសនាម ជំរុញទឹកចិត្តបងចាំនូវពាក្យស្លោកនានា និងរៀបចំជីវប្រវត្តិផ្ទាល់ខ្លួនមិនខាន ។ សិស្សអាចបានដើរពី


សំ រិតនាង អាយុ ២២ឆ្នាំ
ថ្ងៃចូលបដិវត្ត ៥.៨.៧៥

កន្លែងមួយ ទៅកន្លែងមួយ ដោយ ច្រៀងចម្រៀងបដិវត្ត ។ អ្នកទាំងនោះប្រហែលជាត្រូវបានអនុញ្ញាតឲ្យដេកតែមួយស្រឡេតប៉ុណ្ណោះ ។ ដូចជាសមាជិកដែលទើបតែបានចុះឈ្មោះថ្មីៗនៃចលនាសាសនាអ៊ីចឹងដែរ សិក្ខាកាមទាំងអស់ត្រូវតែចេញពីសាលាដោយមានការផ្ដោតអារម្មណ៍និងមានគំនិតភ្លឺស្វាង ។

ក្រុមអ្នកធ្វើការនៅក្នុងមន្ទីរស-២១ហាក់ដូចជាមានភាពស្អិតល្មួតណាស់ ។ ក្នុងចំណោមអ្នកដែលបានបំពេញប្រវត្តិរូបហើយ មានបុរសចំនួន១០១នាក់និងស្ត្រីចំនួន៣២នាក់ បានកើតនិងត្រូវបានចិញ្ចឹមនៅតំបន់២៥ស្ថិតនៅខាងត្បូងទីក្រុងភ្នំពេញ ២៩នាក់ទៀតមកពីតំបន់៣១ ៣នាក់មកពីតំបន់៣២ ១៣នាក់មកពីតំបន់៣៣ដែលនៅភូមិភាគឦសានទាំងមូល ហើយមានម្នាក់មកពីតំបន់៤១ដែលស្ថិតនៅភាគខាងជើង ។ អ្នកទាំងនោះត្រូវបានដកមកពីអង្គភាពយោធាដែលបញ្ជូនទៅទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥ ។

តំបន់២៥មានប្រជាជនរស់នៅច្រើនហើយធូរធារទៀត ។ នៅទីនោះមានប្រជាជនរស់នៅជាច្រើនពាន់នាក់រួមទាំងជនជាតិចិននិងខ្មែរកាត់ចិនដែលធ្វើចម្ការយកភោគផលទៅលក់នៅទីផ្សារ មានអ្នកទីរួមខេត្ត និងមួយភាគធំទៀតជាខ្មែរសុទ្ធសាធដែលធ្វើស្រែចម្ការ ។ ក្នុងទសវត្សរ៍ឆ្នាំ៦០តំបន់នេះត្រូវបានតំណាងដោយ ខៀវ សំផន ដែលមានប្រជាប្រិយក្នុងចំណោមក្រុមបោះឆ្នោត និងបានឃោសនាប្រជាជនឲ្យចូលបក្សកុម្មុយនិស្តដែលបង្កើតឡើងដោយស្ងាត់ៗ ។ ហ៊ឹម ហ៊ុយ បានរំឭកឡើងវិញថា «នរណាក៏ស្រឡាញ់ ខៀវ សំផន ដែរនៅតំបន់នេះ» ។ ៤ឆ្នាំក្រោយពីការរត់ចូលព្រៃម៉ាគីសនៅឆ្នាំ១៩៦៧ ពេលដែលមានមនុស្សជាច្រើនគិតថា ខៀវ សំផន បានស្លាប់បាត់ទៅហើយនោះ ខៀវ សំផន បានក្លាយជាសមាជិកសំខាន់មួយរូបនៃមជ្ឈិមបក្ស ។ ពេលចុះចូលជាមួយរដ្ឋាភិបាលភ្នំពេញក្នុងឆ្នាំ១៩៩៨ ខៀវ សំផន គឺជាអ្នកដែលរស់រានមានជីវិតគួរឲ្យខ្លាចនិងគួរឲ្យស្អប់ខ្ពើមជាទីបំផុត ។


ហ៊ឹម ហ៊ុយ

សរុបមក អ្នកធ្វើការនៅមន្ទីរ ស-២១ សុទ្ធតែស្ថិតក្នុងវ័យស្របាលគ្នា មានបទពិសោធន៍ប្រហាក់ប្រហែលគ្នា និងមកពីប្រភពដើមដូចគ្នា លើកលែងតែ«បងៗធំៗ»ដែលភាគច្រើនជាបញ្ញវន្តកំប៉ិកកំប៉ុកតែប៉ុណ្ណោះ ។ អ្នកទាំងនោះក៏មានលក្ខណៈសម្បត្តិប្រហាក់ប្រហែលនឹងអ្នកដែលឃុំឃាំងនៅក្នុងគុកដែរ ។

## អ្នកទោសនៅមន្ទីរ ស-២១

ចំនួនអ្នកទោសនៅមន្ទីរ ស-២១ មិនទៀង ជួនតិចជួនច្រើន ។ នេះបង្ហាញពីការធ្វើវិសុទ្ធកម្មដែលកើតមានទូទាំងកម្ពុជាប្រជាធិបតេយ្យចាប់ពីពាក់កណ្ដាលឆ្នាំ១៩៧៦ឡើងទៅ ។ ចំណុចនេះមានធ្វើការវែកញែកលម្អិតនៅក្នុងជំពូក៣ ។ ចំនួនអ្នកទោសក្នុងឆ្នាំ១៩៧៧មានប្រហែល១៥០០នាក់ ។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំដដែលនោះ មន្ទីរសន្តិសុខឃុំឃាំងអ្នកទោសចំនួន១២៤២នាក់ ក្នុងនោះមានស្ត្រី១០៥នាក់ ។ ប្រហែលជាពេលនោះហើយដែល ញ៉ែម អេន ឃើញគេដឹកអ្នកទោសទាំងឡានៗចូលមកមន្ទីរស-២១ ហើយដឹកយកទៅសម្លាប់ភ្លាមដោយមិនទាន់ទាំងបានថតរូបឬសួរចម្លើយផងពីព្រោះតែអ្នកទោសទាំងនោះមិនសំខាន់ ហើយមន្ទីរសន្តិសុខគ្មានកន្លែងដាក់ ។

មានពេលខ្លះ មន្ទីរស-២១មានអ្នកទោសតែពីរ-បីរយនាក់ប៉ុណ្ណោះ ។ ក្នុងឆ្នាំ១៩៧៥ មានមនុស្សតិចជាង២០០នាក់ត្រូវបានឃុំខ្លួនដោយសន្តិបាល ។ ចំនួនអ្នកទោសកើនឡើងដល់១៦២២នាក់ក្នុងឆ្នាំ១៩៧៦ ដែល៣ភាគ៤នៃអ្នកទោសទាំងនោះត្រូវបានចាប់ខ្លួនក្នុងរវាងខែឧសភា ជាពេលដែលមានការធ្វើវិសុទ្ធកម្មខ្លាំងក្លា និងជាពេលដែលអគារនៅទួលស្លែងត្រូវបានចាប់ផ្ដើមប្រើប្រាស់រហូតដល់ចុងឆ្នាំ ។ នាឆ្នាំ១៩៧៧ ពេលដែលមន្ទីរភូមិភាគនានារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យត្រូវទទួលចលនាវិសុទ្ធកម្ម យ៉ាងហោចណាស់មានមនុស្សចំនួន៦៣០០នាក់ត្រូវបានចាប់ខ្លួន ។ មានថ្ងៃខ្លះមានមនុស្សជាង៣០០នាក់ត្រូវបានចាប់ដាក់គុក ។

(នៅមានត)

# ឈ្លើយ

## តើជាបទឧក្រិ



ជិន ង៉ុក តាយ អាយុ ២២ឆ្នាំ តួនាទីៈ ទាហាន
ទីកន្លែងចាប់ខ្លួនៈ កោះរ៉ៃ
ថ្ងៃចាប់ខ្លួនៈ ៣១ មករា ១៩៧៨
ថ្ងៃកម្ទេចៈ ២៧ ឧសភា ១៩៧៨



យោងតាមបញ្ជីសម្លាប់អ្នកទោស រូបថត ប្រវត្តិរូប ព្រមទាំងចម្លើយសារភាព មានទាហានវៀតណាមជាង១០០នាក់ត្រូវស្លាប់នៅទួលស្លែងដែលជាគុកសម្ងាត់របស់ខ្មែរក្រហមមានឈ្មោះថា ស-២១ ។ លោកអ៊ឹំ វ៉ាន់ណាត ជាអ្នកទោសម្នាក់ក្នុងចំណោមអ្នកទោសទាំង៧នាក់ដែលរួចជីវិតពីគុកទួលស្លែង មានប្រសាសន៍ ថា គាត់បានឃើញអ្នកទោសវៀតណាម ។ អតីតនាយទាហានជាន់ខ្ពស់វៀតណាមម្នាក់បាននិយាយថា មានទាហានវៀតណាមតែ «២ឬ៣នាក់» តែប៉ុណ្ណោះដែលត្រូវខ្មែរក្រហមចាប់ខ្លួនបាន ។ នាយទាហានរូបនេះបន្តទៀតថា ឯកសណ្ឋានទាហានវៀតណាមក្នុងរូបថតនៅ ស-២១ នោះគឺសល់មកពីទសវត្សរ៍ឆ្នាំ១៩៥០ ។ តើអ្នកទោសទាំងនេះជាជនជាតិវៀតណាមឬយ៉ាងដូចម្តេច? ហើយប្រសិនបើជាជនជាតិវៀតណាម តើជាទាហានឬជាជនស៊ីវិល? យើងអាចរកឃើញការពិតតាមរយៈឯកសារផ្ទៃក្នុងនៃគុកទួលស្លែង ។ កន្លងមក បុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួបជាមួយគ្រួសារសាច់ញាតិទាំងឡាយរបស់អ្នកទោសខ្មែរចំនួន២០នាក់ដែលស្លាប់នៅទួលស្លែង និងសាច់ញាតិរបស់កម្មាភិបាលគុកចំនួន១៩នាក់ដែលបាត់ខ្លួននៅទួលស្លែង ព្រមទាំងបានជួបអតីតកម្មាភិបាលគុកចំនួន១៩នាក់ដែលនៅរស់ហើយបានផ្តល់បទសម្ភាសន៍ ។ ដូចគ្នានេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជាមានជំនឿថានឹងអាចបានជួបជាមួយ

# សឹកវៀតណាម

# ជ្ជនៃឧក្រិដ្ឋកម្មសង្គ្រាមឬ?

ខែមករា ឆ្នាំ១៩៧៨ នៅកោះវៃ (ប៉ូឡូវៃ) ក្នុងដែនសមុទ្រកម្ពុជា ។ ឈ្មោះ ជិន ត្រូវបានបញ្ជូនមកដល់ទួលស្លែងនៅថ្ងៃទី៣១ ខែមករា ឆ្នាំ ១៩៧៨ ហើយត្រូវបានសម្លាប់នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៨ ។ ជិន កើតនៅភូមិធីជិន ឃុំឌៀងដុង ស្រុកហូគួក (កោះត្រល់) ខេត្តកៀងហ្សាង ប្រទេសវៀតណាម ។ ជិន ត្រូវបាន ចោទថាជាទាហានវៀតណាមឋានៈពលទោក្នុងវរសេនាតូចលេខ២ អនុសេនាធំលេខ១ យោធាស្រុកហូគួក ។ ជិន ចូលធ្វើទាហាន នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ ។ ក្នុងចម្លើយសារភាព ជិន និយាយថា





វិញ ទី ភៀន អាយុ ២៣ឆ្នាំ



លឿង កុង វ៉ាយ អាយុ ២៤ឆ្នាំ

គ្រួសារសាច់ញាតិនៃអ្នកទោសដែលខ្មែរក្រហមហៅថា ទាហានវៀតណាម ដែលបានស្លាប់នៅទួលស្លែង។ ខណៈដែលរដ្ឋាភិបាលវៀតណាមកំពុងរកអដ្ឋិធាតុទាហានរបស់ខ្លួនដែលបានស្លាប់ក្នុងសង្គ្រាមនៅកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជាសូមចូលរួមចំណែកបង្ហាញទាហានវៀតណាមចំនួន១២៦នាក់ដែលត្រូវបានសម្លាប់នៅទួលស្លែងចន្លោះឆ្នាំ១៩៧៥-៧៩ ។ ឈ្មោះ ជិន ង៉ុកតាយ ជាអ្នកទោសម្នាក់ក្នុងចំណោមទាហានវៀតណាមទាំង១២៦នាក់ ហើយក៏ជាអ្នកទោសម្នាក់ក្នុងចំណោមអ្នកទោសវៀតណាមសរុបចំនួន៤៨៨នាក់ដែលត្រូវបានសម្លាប់នៅគុកទួលស្លែង។ យោងតាមចម្លើយសារភាព ឈ្មោះ ជិន ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៨

គាត់ត្រូវបានបញ្ជូនទៅហ៊ុកហ៊ឺននៅសាលានយោបាយនិងយោធា ។ ជិន ត្រូវបានបង្រៀនថា គោលនយោបាយជាយុទ្ធសាស្ត្រនៃបក្សកុម្មុយនិស្តវៀតណាម គឺបង្កើតសហពន្ធ័ឥណ្ឌូចិនបន្ទាប់ពីបានរំដោះឥណ្ឌូចិនទាំងស្រុងពីពួកចក្រពត្តិ ។ នៅឆ្នាំ១៩៧៥ កម្ពុជាបដិសេធគំនិតនេះ ប៉ុន្តែវៀតណាមនៅតែបន្តបេតនាចង់ឲ្យគំនិតនេះក្លាយជាការពិត ។ ជិន ត្រូវបានពន្យល់ថា គោលបំណងវៀតណាមគឺត្រូវធ្វើឲ្យឥណ្ឌូចិនក្លាយជាប្រទេសតែមួយដែលមានវៀតណាមជាមេដឹកនាំតែមួយគ្មាននរណាអាចតវ៉ាបានលុបបំបាត់ឯករាជ្យភាពកម្ពុជា ។ អង្គភាពរបស់ ជិន បានទទួលបញ្ជាទៅយាមការពារស្រុកហូគួក (កោះត្រល់) ។ នៅថ្ងៃទី២៣


ជឿន ដន ហ៊ុន អាយុ ២៨ឆ្នាំ


ងៀម ថាញ់ សុន អាយុ ២៣ឆ្នាំ


ង្វី វ៉ាន់ ឡឺយ អាយុ ២០ឆ្នាំ




ង្វៀន វ៉ាន់ បែ អាយុ ២៨ឆ្នាំ


សំ គីម អាយុ ៣៩ឆ្នាំ




ចាន់ ទេព អាយុ ២៦ឆ្នាំ


ចៀវ ឡុក អាយុ ៣០ឆ្នាំ

ខែមករា ឆ្នាំ១៩៧៨ មេបញ្ជាការកងអនុសេនាធំរបស់ ដិន ឈ្មោះ អែម ចឹមក្វាត និង ង្វៀង វ៉ាន់ ដូវ បញ្ជាឲ្យ ដិន មកស៊ើបការណ៍នៅកោះវ៉ៃ (ប៉ូឡូវ៉ៃ) ជាកន្លែងដែល ដិន ត្រូវខ្មែរក្រហមចាប់ខ្លួនបាន ។

សាច់រឿងរបស់អ្នកទោសឈ្មោះ ដិន បានមកពីចម្លើយសារភាពក្រោមការបង្ខំពិតមែន ប៉ុន្តែបទពិសោធន៍បានបង្ហាញថា សាច់រឿងនេះព្រមទាំងសាច់រឿងទាំងឡាយនៃអ៊ីដែលខ្មែរក្រហមហៅថា ទាហានវៀតណាម ដែលបានស្លាប់នៅទួលស្លែង អាចផ្ទៀងផ្ទាត់រកការពិតបានតាមរយៈការស្រាវជ្រាវ ។ សំណួរចុងក្រោយគឺថា តើយុត្តិធម៌នឹងត្រូវបានផ្តល់ឬយ៉ាងណា ដល់អ្នកទោសសង្គ្រាម និងឃាតករសម្លាប់អ្នកទោសសង្គ្រាម ដែលអាចនឹងជាប់ចោទពីបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មសង្គ្រាមក្រោម

# គំរូមួយនៃភស្តុតាងឯកសារភ្ជាប់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជាដែលនៅរស់ នៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ភាគ២)

**(តពីលេខមុន)** នួន (នួន ជា) និង វ៉ាន់ (អៀង សារី) បានទទួលឯកសារចម្លងចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៧៧ ស្តីអំពីរបាយការណ៍នៅភូមិភាគពាយ័ព្យ ។ របាយការណ៍នេះបានរៀបរាប់អំពីសកម្មភាពខ្មាំងដែលប្រហែលជាកត្តាបណ្តាលឲ្យប្រជាជនរត់ទៅប្រទេសថៃ ។ ទាក់ទងនឹងភាពជាក់ស្តែងនៃការចាប់ខ្លួននិងបាត់ខ្លួនប្រជាជននៅភូមិភាគនោះ មានការប្រកាសមួយដោយខ្មាំងនិយាយថា «ប្រសិនបើគេយកប្រជាជនម្នាក់ទៀតទៅនោះ អ្នកដទៃទៀតនឹងរត់ចេញពីប្រទេសមិនខាន» ។ ទូរលេខនេះនិយាយអំពីការចាប់ខ្លួន«អាឈឿន...ដែលបំផុសប្រជាជនឲ្យរត់» ។ ទូរលេខនៅបានបញ្ជាក់ថា ក្រៅពីការចេញទៅឃោសនានិងកសាងអប់រំប្រជាជនដើម្បីឲ្យយល់ច្បាស់អំពីបដិវត្តន៍ ផ្នែកផ្សេងៗនៅក្នុងភូមិភាគពាយ័ព្យ«កំពុងតែចេញរកអង្គការខ្មាំង» និងត្រូវបានចាត់តាំងឲ្យរួមជាមួយប្រជាជនកម្ទេចខ្មាំងគ្រប់ប្រភេទ ។ មានលិខិតមួយទៀតមកពីភូមិភាគពាយ័ព្យចុះថ្ងៃទី២១ ខែធ្នូ ជូនចំពោះ«អង្គការ៨៧០» ។ លិខិតនេះបានស្នើថា «សន្តិសុខ (ស-២១) សួរចម្លើយមនុស្សម្នាក់ឈ្មោះ «ហម» ដែលទទួលបន្ទុកភស្តុភារយោធា» ។ លេខាភូមិភាគឈ្មោះ រស់ ញឹម បានពន្យល់តាមរយៈសារនេះថា «ភូមិភាគចង់ឲ្យបញ្ចប់កិច្ចការនេះឲ្យបានចប់ឆាប់ៗ ដើម្បីស្រាវជ្រាវរកខ្សែរយៈពួកវាទាំងអស់» ។

១០ថ្ងៃក្រោយមក នួន និង វ៉ាន់ បានទទួលសារពីលេខាកងពលធំជើងទឹកលេខ១៦៤ ឈ្មោះ មាស មុត ។ ក្នុងសារនោះ មុត បានប្តេជ្ញាចិត្តការពារ«មាតុភូមិសង្គមនិយមកម្ពុជាដោយខិតខំបោសសម្អាតដោយមិនរួញរានូវខ្មាំងបង្កប់ ទោះជាយួន ឬខ្មាំងផ្សេងទៀតក៏ដោយ» ។


សាកសពជនរងគ្រោះនៅគុកទួលស្លែង

នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៨ លេខា(ថ្មី) ភូមិភាគឧត្តរ ឈ្មោះ សែ បានផ្ញើពត៌មានស្តីអំពីសភាពការណ៍មួយច្បាប់ទៀតទៅជូន «គណៈ៨៧០» ដោយមានចម្លងជូន នួន និង វ៉ាន់ ។ លិខិតនេះបរិយាយអំពីវិធានការផ្សេងៗ ដែលបានធ្វើឡើងដើម្បីចាត់ការជាមួយសកម្មភាពនានារបស់ពួកប្រឆាំងប្រដាប់អាវុធដែលតាមដឹងមកថាបានលួចជ្រៀតពីប្រទេសថៃចូលខេត្តព្រះវិហារនិងឧត្តរមានជ័យ ព្រមទាំងលើកឡើងពីវិធានការប្រឆាំងនឹង«អាខ្មាំងរត់ចោលជួរនិងប្រជាជនសាមញ្ញ» ។ វិធានការទាំងនោះរួមមានការពង្រឹងសហករណ៍បង្កបង្កើនផលដោយ«ពឹងផ្អែកជាពិសេសទៅលើប្រជាជនមូលដ្ឋានក្នុងការបោសសម្អាតខ្មាំងបង្កប់និងពួកចោរព្រៃឲ្យអស់» ។ ទូរសារនៅថ្ងៃបន្ទាប់មកពីលេខាភូមិភាគឦសានឈ្មោះ វី បានរាយការណ៍អំពីការ

រកឃើញ“ខ្មាំងបង្កប់”ដែលយកចិត្តទុកដាក់ចំពោះពួកក្បត់ដែលលាក់ស្រូវនិងឃោសនាបំផុសឲ្យប្រជាជនរត់ ដូចជាមេក្បត់ឈ្មោះ នូ ដែល“ធ្វើសកម្មភាពយូរមកហើយ” ។ ទូរសារមួយទៀតចុះថ្ងៃទី១៣ ខែមករា មកពីឈ្មោះ វី បានរាយការណ៍ថា វី ខ្លួនឯងបាន“ណែនាំឲ្យបោសសម្អាត”ក្រោយពីខបទូវហេតុមួយបានកើតឡើង (មានវៀតណាមចូលមកមន្ទីរយោធភូមិភាគ) ។ បីខែក្រោយមក សែ បានរាយការណ៍ពីបញ្ហាផ្សេងៗទៀត ព្រមទាំងលើកពីការបោសសម្អាតនៅភូមិភាគឧត្តរ តាមរយៈទូរសារមួយច្បាប់ផ្ញើទៅ“គណៈ៨៧០” ។ ឯកសារនេះត្រូវបានចម្លងជូន នួន និង វ៉ាន់ ដែរ ។ ទាក់ទងនឹង“សភាពការណ៍ខ្មាំងតាមព្រំដែនថៃ” សែ បាននិយាយថា នៅតែមាន“ជនក្បត់លួចជ្រៀតចូលវាយឆ្មក់ពួកយើងនៅតាមព្រំប្រទល់ព្រះវិហារពេលដែលទាហានយើងកំពុងតែដើរក្នុងព្រៃ ។ មូលហេតុនៃការវាយប្រហារនេះគឺប្រហែលដោយសារផ្ទៃក្នុងរបស់យើងមិនទាន់ល្អ ហើយដែលមិនទាន់ល្អនេះហើយដែលនាំឲ្យបែកការណ៍ទៅខ្មាំង” ។ ប៉ុន្តែ សែ បាននិយាយថា “យើងបានចាត់វិធានការចំពោះបញ្ហានេះរួចហើយ” ។ មានចោរព្រៃ១ក្រុមមានគ្នាប្រហែល ៣០ ទៅ ៤០នាក់ បានចូលជ្រៅទៅក្នុងតំបន់ឧត្តរ ប៉ុន្តែ “ទ័ពស្រុកនិងតំបន់បាននិងកំពុង”វែកព្រៃរកកម្ទេចពួកវា ហើយជាលទ្ធផលយើង“បានកម្ទេចនិងចាប់បានជាបន្តបន្ទាប់” ។ លើសពីនេះ “ពួកដែលលួចផ្តល់ស្បៀងឲ្យខ្មាំងយើងបានចាប់អស់ហើយ” ។ ចុងបញ្ចប់ សែ បានលើកអំពី“សភាពការណ៍ខ្មាំងបង្កប់” ។ “ខ្មាំងនៅសល់ទាំងប៉ុន្មានបានបកក្បាលធ្វើសកម្មភាពប្រឆាំងយើង” ។ ពួកវាបាន “ទាក់ទងជាមួយប៉ូលិសទាហាន និងរដ្ឋការរបស់អតីតសាធារណរដ្ឋខ្មែរ ។ ពួកនេះបានក្លែងខ្លួនធ្វើជាប្រជាជនថ្មី” ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ



រនុកដែកនិងខ្នោះសម្រាប់ដាក់ជើងអ្នកទោសនៅគុកទួលស្លែង

ក៏«ក្រោយពីពួកវាបានធ្វើសកម្មភាពប្រឆាំងយើង» ភូមិភាគបាន«ស្គាល់មុខវាយ៉ាងច្បាស់» ហើយក៏«កម្ចាត់ពួកវាជាខ្សែសង្វាក់» ។ ទោះបីជាទាហាន ប៉ូលិស និងរដ្ឋការ ជាច្រើននាក់រត់គេចចេញក្រោយពីយើងបានសម្អាតអស់ប្រហែលជា២០ក្បាលក៏ដោយ តែភូមិភាគ«កំពុងតែចាត់វិធានការថែមទៀតក្នុងការរុករកនិងចាប់ខ្លួនពួកវា» ។ ទាក់ទងជាពិសេសទៅនឹង«ខ្មាំងបង្កប់នៅក្នុងតំបន់ព្រះវិហារ ពួកវាលែងមានទៀតហើយក្រោយពីយើងបាននិងកំពុងចាត់វិធានការបោសសម្អាតថែមទៀត» ។

នៅថ្ងៃទី១០ ខែមេសា សែ បានរាយការណ៍ថា ក្រុមប្រឆាំងប្រដាប់អាវុធកំពុងតែបន្ត«ធ្វើសកម្មភាពរំខានយើងនៅតាមព្រំដែន» ប៉ុន្តែបានសន្យាថានឹង«វាយកម្ទេចពួកវា» ។ សែ បានបញ្ជាក់ថា តាំងពីពេលដែល«អាហង់» (ហៅ ប៊ូ ជាត) លេខាតំបន់១០៣ (ព្រះវិហារ) ត្រូវបានចាប់ខ្លួនជាមួយនឹង«ខ្សែវា»មក ពួកប្រឆាំងលែងអាចប្រើ«ពួកអាក្បត់»ជា«ខ្នងបង្អែក»ធ្វើសកម្មភាពទៀតហើយ ។ ករណីប្រហាក់ប្រហែលនេះដែរ «ខ្មាំងចោរព្រៃ»ដែលរៀបចំសមាសភាពដោយ អា ហង់ ត្រូវបាន«ចាប់និងកម្ទេច...ជាបន្តបន្ទាប់ ហើយឥឡូវនេះយើងកំពុងតែដំណើរការវែកព្រៃរកពួកវាបន្តទៀត» ។ ទូទៅជាងនេះទៅទៀត ភូមិភាគ«កំពុងតែបន្តបោសសម្អាតអាពួកនៅសេសសល់ជាបន្តបន្ទាប់ ទាំងពួកប្រឆាំងនឹងបដិវត្តន៍ជាចំហ និងប្រឆាំងមិនចេញមុខ» ។ សែ បានពន្យល់ថា «បញ្ហានេះយើងកំពុងធ្វើដោយផ្អែកសំខាន់ទៅលើប្រជាជនសាមញ្ញ ជាពិសេសប្រជាជនមូលដ្ឋានដែលកាន់តែយល់ច្បាស់អ្នកណាជាមិត្តអ្នកណាជាសត្រូវ» ។ សភាពការណ៍បង្កបង្កើនផលជាទូទៅមានការរីកចម្រើន ពីព្រោះ«ប្រជាជនទូទៅ...មានជំនឿកាន់តែខ្លាំងទៅលើសហករណ៍និងការដឹកនាំរបស់បក្ស» ជាលទ្ធផលនៃការដែលយើងបានធ្វើការបោសសម្អាតអ្នកប្រឆាំងទាំងអស់ជាបន្តបន្ទាប់មក ។



នៅក្នុងតំបន់១០៣ ជាពិសេសដោយមានការបោសសម្អាតខ្មាំងបង្កប់ យើងក៏បានពឹងផ្អែកទៅលើប្រជាជនដែរ ។ យើងចង់ចាត់ការនេះឲ្យបានជោគជ័យនិងមិនឲ្យខ្មាំងមានលទ្ធភាពនឹងបកក្បាលមកប្រឆាំងនឹងកម្លាំងប្រជាជនទេ ។ កម្លាំងប្រជាជនជាការគាបសង្កត់ពួកវា និងបោសសម្អាតពួកវាជាបន្តបន្ទាប់ឥតឈប់ឈរ ។ យើងបានទទួលជ័យជម្នះលើខ្មាំងសត្រូវតាំងពីដើមរហូតដល់បច្ចុប្បន្ន ។ ប្រជាជនមានការសប្បាយចិត្តមែនទែនចំពោះការសម្អាតខ្មាំងនៅក្នុងតំបន់១០៣ ។

ទាំង នួន និង វ៉ាន់ ក៏បានទទួលឯកសារចម្លងចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៨ ពីគណៈកងពល២៦០ ដែលស្នើថា «បក្ស»មានការយល់ស្របក្នុងការ«ចាត់វិធានការទាំងនេះ» ចំពោះសមាជិកគណៈស្រុកនិងគណៈតំបន់នៅភូមិភាគបូព៌ាដែលចចេសមិនព្រមធ្វើតាមការណែនាំឲ្យប្រមូលសត្វពាហនៈមកសមរភូមិក្រោយ បណ្តាលឲ្យទាហានវៀតណាមរឹបអូសយកអស់ក្នុងអំឡុងពេលវាយប្រហារគ្នានៅតាមព្រំដែន ។ មួយសប្តាហ៍ក្រោយមក លេខាភូមិភាគពាយ័ព្យឈ្មោះ រី បានរាយការណ៍ថា «ទាក់ទងនឹងការកសាងកម្លាំង»នៅទីនោះ «ពួកវាត្រូវបានបោសសម្អាត» ហើយថា ការណែនាំផ្សេងៗនៅក្នុងភូមិភាគបាន«ធ្វើឲ្យពួកវាមួយចំនួនធំស្ងប់ស្ងាត់ ខ្លះត្រូវបានវែកមុខ ត្រូវបានបំបែកពីហ្វូង និងខ្លះទៀតត្រូវបានបោសសម្អាត» ។ ទូរលេខពីរថ្ងៃក្រោយដែលផ្ញើមកពីភូមិភាគបស្ចិម បានរាយការណ៍ទាក់ទងនឹង «បញ្ហាសមាសភាពនៅក្នុងបក្ស» ថា មានមួយចំនួនដូចជា «សមមិត្ត សុទ្ធ ប្រធានរោងចក្រជួសជុល» ត្រូវបានចាប់ខ្លួនក្រោយពីបានខូចសីលធម៌ជាមួយនារីភេទ និងក្រោយពីត្រូវបាន «ចោទប្រកាន់ថាបានឆ្លើយឆ្លងជាមួយអាខ្មាំងក្បត់ឈ្មោះជួន» ទូរលេខបានបញ្ជាក់ថា «សូមស្នើឲ្យជួយយោបល់ទាក់ទងនឹងបញ្ហានេះ ទោះជាត្រូវទុកវានៅកន្លែងណាឬក៏ត្រូវបញ្ជូនវាទៅកន្លែងណាក៏ដោយ» ។

ក្រោយពីមានជម្លោះប្រដាប់អាវុធតាមព្រំដែនដ៏ធ្ងន់ធ្ងរ នៅឆ្នាំ១៩៧៧ រវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាម នួន និង វ៉ាន់ ក៏បានទទួលឯកសារចម្លងមួយច្បាប់ស្តីអំពីការកើនឡើងនៃរបាយការណ៍សមរភូមិមុខដែលផ្តោតសំខាន់ទៅលើការកម្ទេចជនស៊ីវិលវៀតណាម និងយុទ្ធជនវៀតណាមដែលត្រូវបានចាប់ជាឈ្លើយសឹក ។ របាយការណ៍នេះក៏បានពិភាក្សាអំពីការវាយប្រហារទៅលើមុខសញ្ញាជនស៊ីវិលវៀតណាម ។ ទូរលេខចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៧ មួយច្បាប់មកពីភូមិភាគបូព៌ា ផ្ញើជូនមន្ទីរ៨៧០ បានស្នើសុំយោបល់ពី ម-៨៧០ "ទាក់ទងនឹងបញ្ហាយួនដែលយើងបានចាប់ខ្លួនតាមផ្ទះប្រជាជននៅភូមិតាដែវ" ។ ទូរលេខបានសំណូមពរថា "ប្រសិនបើ ម-៨៧០ ត្រូវការ យើងនឹងបញ្ជូនពួកវាមកឲ្យភ្លាម" ហើយបន្ថែមថា "ឥឡូវនេះយើងកំពុងតែទុកវា និងស្រង់ចម្លើយសារភាពរបស់ពួកវា" ។ ទូរលេខមួយទៀតមកពីភូមិភាគបូព៌ាចុះថ្ងៃទី១៨ ខែកញ្ញា បានរាយការណ៍អំពីការវាយប្រហារគ្នាមួយនៅទ្រៀង ដែលជាកន្លែងទ័ពឈរជើងនិងផ្សារទីរួមខេត្តក្នុងទឹកដីវៀតណាម ។ ពេលវាយប្រហារគ្នានោះ កងទ័ពកម្ពុជាប្រជាធិបតេយ្យបាន"ដុតបំផ្លាញផ្ទះនិងជំរំខ្មាំងអស់ចំនួន៤៩ខ្នង" ហើយបាន"បោសសម្អាតខ្មាំងអស់ពីផ្សារនិងភាគខាងជើងនៃផ្សារនោះ" ទោះបីជាទូរលេខនោះបាននិយាយថា "ចំនួនមនុស្សស្លាប់និងជយភណ្ឌមិនទាន់ដឹងនៅឡើយ"ក៏ដោយ ។ ទូរលេខចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ដែលច្បាស់ជាផ្ញើមកពី សុន សេន បានរាយការណ៍ថាបានចាប់ខ្លួនជនជាតិវៀតណាម"បីក្បាល" ក្នុងនោះពីរក្បាលត្រូវបាន"បាញ់សម្លាប់ចោលពេលដែលវាប្រុងរត់ ហើយម្នាក់ទៀតត្រូវបានបញ្ជូនមកដល់ ២១" (ប្រហែលជាស-២១) ។ សេចក្តីរាយការណ៍សង្ខេបមួយរបស់លេខាកងពល១៦៤ឈ្មោះ មុត ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ បានកត់សម្គាល់ថា "ចំនួនយួន"ដែលត្រូវបានអង្គភាពចាប់ខ្លួន និងបាញ់សម្លាប់ចោលចាប់ពីថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៨ គឺមានរហូតដល់១២០ក្បាល ។ លើសពីនេះទៀត ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៧៧មក នួន និង វ៉ាន់ បានទទួលទូរលេខចម្លងពីឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសវៀតណាមឈ្មោះ សុខ ឈាន (ក្រោយមកត្រូវបានបោសសម្អាត) ។ ទូរលេខបានរាយការណ៍ថា ឥឡូវនេះនៅតែមានការតវ៉ាជាលក្ខណៈឯកជនរបស់ជនជាតិវៀតណាមស្តីពីអំពើឃោរឃៅរបស់កម្ពុជាប្រជាធិបតេយ្យនៅតាមព្រំដែនវៀតណាមនិងកម្ពុជា ។ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ ឈាន បានលើកពីដំណើរទស្សនកិច្ចរបស់មន្ត្រីវៀតណាមដែលបានប្តឹងតវ៉ាអំពីការវាយប្រហាររបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី១៤ ខែមិថុនា ដែលមន្ត្រីរូបនោះបាននិយាយថាមានការទាក់ទង"ការកាប់សម្លាប់"ជនជាតិវៀតណាម "ដុត"ផ្ទះសម្បែង និងបង្ក"ការខូចខាតយ៉ាងដំណំ" ។ មន្ត្រីវៀតណាមបានបន្ថែមទៀតថា "ការដែលកងទ័ពកម្ពុជាធ្វើការរំលោភបំពាន ការកាប់សម្លាប់ ដុតផ្ទះសម្បែង និងកម្ទេច" មិនមែនជា"អ្វី"ដែលខាងវៀតណាម"ចេះតែលើកឡើងតាមរបាយការណ៍នោះទេ ប៉ុន្តែវាជាភស្តុតាងជាក់ស្តែងដែលមិនអាចប្រកែកបាន" ហើយមន្ត្រីនោះចង់ឲ្យមានការថតរូបភាពនៅកន្លែងដែលមានការខូចខាតទៀតផង ។ នៅក្នុងសារលិខិតមួយចុះថ្ងៃទី២០ ខែកក្កដា ឈាន និយាយថា មន្ត្រីវៀតណាមដដែលនោះបានធ្វើការត្អូញត្អែរតាមរយៈលិខិតមួយច្បាប់ថាក្នុងរយៈពេល៣ថ្ងៃនៃការផ្លោងកាំភ្លើងធំកាលពីដើមខែនោះ កងទ័ពកម្ពុជាបានទម្លាក់ចំ "ទីប្រជុំជនបណ្តាលឲ្យមានការខូចខាតយ៉ាងដំណំ ក្នុងនោះយ៉ាងហោចណាស់មានមនុស្សប្រហែល៣០នាក់ស្លាប់ ហើយ៥០នាក់ទៀតរងរបួស ចំណែកផ្ទះសម្បែងវិញត្រូវឆេះអស់ជាច្រើនខ្នង" ។ នៅថ្ងៃទី៥ ខែសីហា ឈាន បានរាយការណ៍ថា សេចក្តីរាយការណ៍ចោទប្រកាន់ពុំសុសសាយពេញក្រុងហាណូយដែលថា "កងទ័ពកម្ពុជាបានសម្លាប់ប្រជាជនវៀតណាមអស់១០០០នាក់នៅហាទៀង ខេត្តកៀងហ្សាង" ។ នៅក្នុងខែដដែល ឈាន បាននិយាយអំពីការចោទប្រកាន់ជាផ្លូវការមួយទៀតដែលថាមាន"ប្រជាជនវៀតណាម"ជាង១០នាក់ត្រូវបានសម្លាប់នៅក្នុងការប្រយុទ្ធក្រោយៗបន្តបន្ទាប់ទៀត ។ ទន្ទឹមគ្នានេះដែរ នៅចុងខែមករា ឆ្នាំ១៩៧៨ មានឯកសារផ្សេងៗទៀតមកពីភូមិភាគបូព៌ាត្រូវបានចម្លងជូននួន និង វ៉ាន់ ។ **(នៅមានត)**

**ស្ទីវ ហេដឺរ**

# ការរំលោភលើផ្លូវភេទ

ការរំលោភលើផ្លូវភេទគឺជាការប្រព្រឹត្តសកម្មភាពណាមួយលើផ្លូវភេទដែលទាក់ទិនដល់ការប្រព្រឹត្តខាងផ្លូវកាមតាមរយៈការប្រើកម្លាំងបង្ខំឬដោយមិនដឹងខ្លួន ។ ការរំលោភលើផ្លូវភេទត្រូវបានទទួលស្គាល់ថាគឺជាទ្រង់ទ្រាយមួយនៃការធ្វើទារុណកម្ម ។ ហេតុដូច្នេះ អំពើនេះរំលោភទៅលើសន្ធិសញ្ញានិងការហាមឃាត់ដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូចដែលបានចែងក្នុងអនុសញ្ញាស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ«ត្រង់មាត្រា៧» និងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនិងការដាក់ទណ្ឌកម្ម ឬការប្រព្រឹត្តដែលមានលក្ខណៈឃោរឃៅអមនុស្សធម៌ ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស ។

មិនតែប៉ុណ្ណោះ ការរំលោភលើផ្លូវភេទក៏រំលោភលើ«ខ»ទាំងឡាយនិងច្បាប់អន្តរជាតិដែលបានបង្កើតឡើងនូវសិទ្ធិចំពោះការមិនរើសអើង សន្តិសុខផ្ទាល់ខ្លួន និងភាពជាឯកជន ។ ឧទាហរណ៍ដូចដែលបានចែងក្នុងមាត្រា៥៥ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ។ អង្គការសហប្រជាជាតិ«ដោយមានទស្សនៈ»ចង់ជំរុញការគោរពនិងការអនុវត្តជាសកលចំពោះសិទ្ធិមនុស្សនិងសិទ្ធិសេរីភាពជាចាំបាច់ចំពោះមនុស្សគ្រប់រូបដោយពុំមានការបែងចែកប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ឬសាសនាអ្វីឡើយ ។ ស្រដៀងគ្នានេះដែរ មាត្រា៥នៃសេចក្តីប្រកាសសកលស្តីអំពីសិទ្ធិមនុស្សចែងថា «គ្មាននរណាម្នាក់ត្រូវទទួលរងនូវការធ្វើទារុណកម្មឬការប្រព្រឹត្តដែលមានលក្ខណៈឃោរឃៅអមនុស្សធម៌ ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្សឡើយ» ។ ហើយមាត្រា៣ចែងថា «មនុស្សគ្រប់រូបមានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន» ។ «ខ»ទាំងនេះជាប្រយោលឬដោយបង្កប់ន័យហាមប្រាមការរំលោភលើផ្លូវភេទ ។ ឧទាហរណ៍នៅក្នុងមាត្រា១៧នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ចែងស្រដៀងគ្នាដែរថា «១)មនុស្សគ្រប់រូបមានសិទ្ធិការពារខ្លួនកុំឲ្យមានការវាយប្រហារទៅលើកិត្តិយសកិត្តិនាមខ្លួនតាមតែអំពើចិត្ត ឬដោយប្រាសចាកពីគន្លងច្បាប់ ។ រីឯការរំខានដល់គេហដ្ឋាន ក្រុមញាតិ មិត្តភក្តិ ព្រមទាំងរឿងរ៉ាវផ្ទៃក្នុងរបស់បុគ្គលម្នាក់ៗដោយពុំស្របតាមច្បាប់ក៏ត្រូវហាមឃាត់ដែរ ។ មនុស្សគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវច្បាប់ក្នុងករណីណាដែលមានការវាយប្រហារ ឬការរំខានដូចពោលក្នុងវគ្គខាងលើ» ។

អនុសញ្ញាស្តីអំពីសិទ្ធិកុមារ (១៩៨៩) ហាមប្រាមដោយប្រយោលនិងយ៉ាងច្បាស់អំពីការរំលោភកុមារនិងការរំលោភបំពានលើផ្លូវភេទក្នុងរូបភាពផ្សេងៗទៀត ។ មាត្រាដែលពាក់ព័ន្ធដល់ការរំលោភលើផ្លូវភេទមានដូចខាងក្រោមនេះ÷

**មាត្រា១:** ចំពោះគោលដៅនៃអនុសញ្ញានេះ កុមារមានន័យថាមនុស្សគ្រប់រូបដែលមានអាយុតិចជាង១៨ឆ្នាំ លើកលែងតែក្នុងករណីដែលអាយុពេញវ័យត្រូវបានសន្មតរហ័សជាងនេះដោយមតិភាគច្រើនក្រោមច្បាប់អនុវត្តចំពោះកុមារ ។

**មាត្រា១៦.១:** គ្មានកុមារណាម្នាក់ត្រូវទទួលរងនូវការជ្រៀតជ្រែកស្រេចតែទំនើងចិត្ត ឬដោយខុសច្បាប់ នៅក្នុងភាពជាឯកជនក្នុងគ្រួសារ ទីលំនៅ ការឆ្លើយឆ្លងគ្នា ព្រមទាំងការបំពារបំពានដោយខុសច្បាប់ទៅលើកិត្តិយសឬកិត្តិនាមរបស់ខ្លួនបានឡើយ ។

**មាត្រា១៦.២:** កុមារមានសិទ្ធិទទួលការការពារតាមផ្លូវច្បាប់តទល់នឹងការជ្រៀតជ្រែកនិងបំពារបំពានអស់ទាំងនេះ ។

**មាត្រា១៩:** ភាគីរដ្ឋទាំងឡាយត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ខាងផ្នែកច្បាប់ ផ្នែករដ្ឋបាលសង្គម និងផ្នែកអប់រំ ដើម្បីការពារកុមារប្រឆាំងនឹងគ្រប់ទ្រង់ទ្រាយនៃអំពើហិង្សាដែលប៉ះពាល់ដល់រាងកាយឬសតិបញ្ញា ការមានរបួសឬការបំពាន ការបោះបង់ចោលឬការមិនយកចិត្តទុកដាក់គិតគូរឲ្យបានដិតដល់ ការធ្វើបាប និងការកេងប្រវ័ញ្ច រួមទាំងការរំលោភបំពានខាងផ្លូវភេទ ក្នុងពេលដែលកុមារស្ថិតនៅក្រោមការចិញ្ចឹម

បីបាច់របស់ឪពុកឬម្តាយ "ឬទាំងឪពុកទាំងម្តាយ" អ្នកអាណាព្យាបាលស្របច្បាប់ ឬបុគ្គលផ្សេងណាដែលទទួលខុសត្រូវក្នុងការថែទាំកុមារនោះ ។

**មាត្រា៣៤:** ភាគីរដ្ឋសន្យាថានឹងការពារកុមារទល់នឹងរាល់ទម្រង់នៃការកេងប្រវ័ញ្ចលើផ្លូវភេទ និងការបំពារបំពានផ្លូវភេទ ។ ក្នុងទិសដៅនេះ រដ្ឋជាភាគីប្រកាន់យកជាពិសេសនូវវិធានការសមស្របទាំងអស់ ក្នុងក្របខ័ណ្ឌជាតិ ក្របខ័ណ្ឌទ្វេភាគី និងក្របខ័ណ្ឌពហុភាគី ដើម្បីទប់ស្កាត់"កុំឲ្យកើតមាន"ការញុះញង់ការបង្ខិតបង្ខំកុមារឲ្យប្រព្រឹត្តសកម្មភាពផ្លូវភេទដោយខុសច្បាប់ ។


ហួត បុប្ផាណា អាយុ ២៥ឆ្នាំ
ថ្ងៃចាប់ ១២.១០.១៩៧៦
ថ្ងៃកម្ទេច ១៨.៣.១៩៧៧

**ក) ការរំលោភលើផ្លូវភេទគឺជាឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងជម្លោះក្នុងស្រុក**

មាត្រា៣ដែលជាមាត្រាទូទៅនៃអនុសញ្ញាទីក្រុងហ្សឺណែវហាមប្រាមយ៉ាងច្បាស់ចំពោះទារុណកម្មនិងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ ឬដែលនាំឲ្យបាត់បង់តម្លៃជាមនុស្សលើជនទាំងឡាយដែលពុំមានការរួមចំណែកយ៉ាងសកម្មក្នុងសកម្មភាពប្រយុទ្ធរាយនានាឡើយ ។ ស្រដៀងគ្នានេះដែរ មាត្រា៤.(២) (ង) នៃពិធីសារទី២នៃអនុសញ្ញាក្រុងហ្សឺណែវហាមប្រាមមិនឲ្យមានការរំលោភបំពានលើសេចក្តីថ្លៃថ្នូររបស់ជនណាឡើយ ជាពិសេសការប្រព្រឹត្តធ្វើឲ្យខូចកិត្តិយសនិងបាត់បង់តម្លៃជាមនុស្ស ការរំលោភលើផ្លូវភេទ ការបង្ខំឲ្យធ្វើពេស្យាចារ និងនៅក្នុងទម្រង់ផ្សេងៗទៀតនៃការធ្វើបាបមិនសមហេតុផល ។

**ខ) ការរំលោភលើផ្លូវភេទគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**

ការរំលោភលើផ្លូវភេទពុំត្រូវបានកំណត់ច្បាស់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេក្នុងធម្មនុញ្ញនូរិមប៊ឺកឬតូក្យូ ទោះបីជាអ្នកច្បាប់អាចប្រកែកបានថាវាចូលទៅក្នុងមាត្រា៦(ង) ដែលចែងអំពី"ការប្រព្រឹត្តអមនុស្សធម៌ទាំងឡាយមកលើប្រជាជនស៊ីវិល"ក៏ដោយ ។ ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ មាត្រា២ បានចែងយ៉ាងច្បាស់ថា ការរំលោភលើផ្លូវភេទគឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយ ។ ទោះបីជាច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០គឺជាច្បាប់ប្រឆាំងដោយចំពោះប្រទេសអាល្លឺម៉ង់ក្រោយចាញ់សង្គ្រាមលោកលើកទី២ក៏ដោយ ក៏អ្នកច្បាប់អាចប្រកែកបានថា វាគឺជាផ្នែកមួយនៃ"គោលការណ៍ច្បាប់ទូទៅដែរ» ហើយហេតុដូចនេះវាក៏អាចជាប្រភពច្បាប់អន្តរជាតិមួយបានដែរ ។

ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ មាត្រា៥(ឆ) នៃលក្ខន្តិកៈយូហ្គោស្លាវី ចាត់ទុកការរំលោភលើផ្លូវភេទថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅពេលដែលការរំលោភនេះត្រូវបានប្រព្រឹត្តឡើងក្នុងលក្ខណៈជាចំណែកមួយនៃសកម្មភាពដែលបានរៀបចំជាប្រព័ន្ធ ឬក្នុងទ្រង់ទ្រាយធំមួយប្រឆាំងនឹងជនស៊ីវិល ដោយឈរលើមូលដ្ឋានសញ្ជាតិ នយោបាយ ជនជាតិភាគតិច ពូជសាសន៍ ឬសាសនា ។

**គ) ការរំលោភលើផ្លូវភេទគឺជាអំពើប្រល័យពូជសាសន៍**

ការចោទប្រកាន់ទាំងឡាយពីបទរំលោភបំពានលើផ្លូវភេទពុំត្រូវបានយកមកជំនុំជម្រះក្តីក្នុងតុលាការឧក្រិដ្ឋកម្មសង្គ្រាមនៅនូរិមប៊ឺកឡើយ ។ មានការលើកយកមកនិយាយតែម្តងគត់អំពីការរំលោភលើផ្លូវភេទក្នុងពេលសង្គ្រាម នៅក្នុងការជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមទាំងឡាយបន្ទាប់ពីសង្គ្រាមលោកលើកទី២ នោះគឺនៅតុលាការតូក្យូដែលនៅទីនោះការរំលោភលើផ្លូវភេទត្រូវបានចាត់ទុកថាគ្រាន់តែជាអ្វីដែលបានកើតឡើងកន្លង

ហួសទៅហើយ ទោះបីជាការពិតបង្ហាញថាពួកជប៉ុនបានបង្ខំឲ្យស្ត្រីរាប់ពាន់នាក់ធ្វើជាស្រីពេស្យាបម្រើទ័ពរបស់ខ្លួនក៏ដោយ ។

នៅក្នុងបរិបទនៃតុលាការយូហ្គោស្លាវី បណ្តាអ្នកច្បាប់បានរុករកមូលដ្ឋានច្បាប់ដើម្បីបង្ហាញថា ការរំលោភលើផ្លូវភេទជាអំពើប្រល័យពូជសាសន៍ ដោយមូលហេតុថា ការរំលោភលើផ្លូវភេទនិងការបង្ខំឲ្យមានផ្ទៃពោះ ត្រូវបានប្រើប្រាស់ជាមធ្យោបាយដើម្បីបំផ្លាញអត្តសញ្ញាណកម្មនៃវប្បធម៌របស់ឥស្លាមបូស្នៀ ។ ការបកស្រាយបែបនេះគឺស្របទៅតាមនិយមន័យនៃការប្រល័យពូជសាសន៍ដូចដែលបានចែងនៅក្នុងអនុសញ្ញាស្តីអំពីការប្រល័យពូជសាសន៍ដែលបានកំណត់និយមន័យនៃការប្រល័យពូជសាសន៍ថាជា...ការបង្កការរំលោភលើផ្លូវភេទដោយចេតនា ទៅលើស្ថានភាពសង្គមរស់នៅក្នុងទំហំធំមួយដែលនាំឲ្យមានការបំផ្លិចបំផ្លាញលើរូបរាងកាយជាក្រុមឬដោយផ្នែក "ការដាក់បង្ខំនូវវិធានការនានាក្នុងគោលបំណងសំដៅទប់ស្កាត់កុំឲ្យក្រុមនោះ (ក្រុមប្រជាជាតិ ជនជាតិភាគតិច វប្បធម៌ ឬសាសនា) ផ្តល់កំណើតទារកនៅក្នុងសង្គមបាន" ។

## ការប្រព្រឹត្តមិនគប្បីលើផ្លូវភេទ

ការប្រព្រឹត្តមិនគប្បីលើផ្លូវភេទទាក់ទងទៅនឹងទំហំនៃការបំពានលើផ្លូវភេទដែលទាក់ទងដល់ការប្រើរូបមន្តវិទ្យាសាស្ត្រចិត្តសាស្ត្រ និងវិធីសាស្ត្រនានាដែលប៉ះពាល់ដល់បុគ្គលឬមនុស្សដែលជិតស្និទ្ធនឹងបុគ្គលនោះ រួមមានការគំរាមកំហែងប្រព្រឹត្តអំពើព្រៃផ្សៃលើផ្លូវភេទមកលើមនុស្សដទៃទៀតដែលជិតស្និទ្ធនឹងបុគ្គលនោះ ការបង្ខំឲ្យអាក្រាត និងរូបភាពនៃការបកអាក្រាតផ្សេងៗទៀតសំដៅធ្វើឲ្យជននោះអាម៉ាស់ បាត់បង់កិត្តិយស និងដើម្បីគំរាមកំហែងដល់ជននោះ ។ យោលទៅតាមភាពធ្ងន់ធ្ងរនិងលក្ខណៈនៃការរំលោភបំពានបែបនេះ ការប្រព្រឹត្តមិនគប្បីទៅលើផ្លូវភេទក៏អាចប្រៀបធៀបទៅនឹងការធ្វើទារុណកម្មនិងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ដែលនាំឲ្យបាត់បង់តម្លៃជាមនុស្ស ។

## ការបង្ខំឱ្យរៀបការ

សិទ្ធិរៀបការឬមិនរៀបការ និងសិទ្ធិជ្រើសរើសគូស្វាមីភរិយាដោយខ្លួនឯងផ្ទាល់ គឺសុទ្ធតែមានចែងនៅក្នុងសេចក្តីប្រកាសនិងសន្ធិសញ្ញាអន្តរជាតិទាំងឡាយ ។ "មាត្រាច្បាប់ត្រូវបានផ្តល់ឲ្យនៅខាងក្រោមនេះ" ។ ការបង្ខំឲ្យរៀបការអាចបណ្តាលឲ្យមានការប្រព្រឹត្តមិនគប្បីលើផ្លូវភេទ ឬ/និង ការរំលោភលើផ្លូវភេទ ។ ការបង្ខំឲ្យរៀបការក៏អាចជាទ្រង់ទ្រាយនៃអំពើប្រល័យពូជសាសន៍ដែរប្រសិនបើអំពើនោះត្រូវបានប្រព្រឹត្តឬបង្ខំដោយរដ្ឋមួយក្នុងគោលបំណងបំផ្លាញក្រុមវប្បធម៌ ជនជាតិភាគតិច ឬក្រុមសាសនាមួយ ។

ដោយយោងទៅតាមសេចក្តីប្រកាសសកលស្តីអំពីសិទ្ធិមនុស្សត្រង់មាត្រា១៦ៈ

១) ដោយពុំមានការដាក់កម្រិតឬការរើសអើងចំពោះពូជសាសន៍ ប្រជាជាតិ ឬសាសនា បុរសនិងស្ត្រីពេញអាយុរៀបការ មានសិទ្ធិរៀបការនិងបង្កើតគ្រួសារ ។ បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាចំពោះអាពាហ៍ពិពាហ៍ ក្នុងចំណងអាពាហ៍ពិពាហ៍និងក្នុងពេលលែងលះគ្នា ។

២) អាពាហ៍ពិពាហ៍ត្រូវប្រព្រឹត្តឡើងដោយមានឆន្ទៈសេរីនិងការព្រមព្រៀងដ៏ពេញលេញពីភាគីទាំងសងខាង ។

ស្រដៀងគ្នានេះដែរ កតិកាសញ្ញាស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយចែងក្នុងមាត្រា២៣ ត្រង់ចំណុចទី ២ និងទី ៣ ថាៈ

២) ត្រូវទទួលស្គាល់សិទ្ធិរបស់ស្ត្រីនិងបុរសដែលគ្រប់អាយុរៀបការក្នុងបញ្ហារៀបការនិងបង្កើតគ្រួសារ ។

៣) អាពាហ៍ពិពាហ៍មិនអាចប្រព្រឹត្តឡើងដោយពុំមានការយល់ព្រមដោយពេញលេញនិងសេរីពីភាគីទាំងសងខាង ។

លើសពីនេះទៅទៀត មាត្រា១៦ៈ

ដោយឈរលើមូលដ្ឋានសិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រី ភាគីរដ្ឋទាំងឡាយត្រូវធានាឲ្យប្រាកដនូវៈ

ក) សិទ្ធិស្មើគ្នាចំពោះអាពាហ៍ពិពាហ៍

ខ) សិទ្ធិស្មើគ្នាក្នុងការជ្រើសរើសគូស្រករដោយសេរី និងរៀបការដោយមានការយល់ព្រមពេញលេញនិងសេរីពីភាគីទាំងសងខាង ។

**ច្រើស្តីខ្មែរក្រហម**

**◆មានតែកូនក្មេងទើបនឹងកើតទេទើបស្អាតស្អំ។**

# វិធីបួនយ៉ាងក្នុងការវិនិច្ឆ័យអំពើទារុណកម្មប្រព្រឹត្តឡើង នៅក្នុងសម័យខ្មែរក្រហម

**(តពីលេខមុន)** មាត្រាទី៥ នៃច្បាប់ស្ដីអំពីការបង្កើតតុលាការ បញ្ជាក់ពីគំនិតនេះថា "ការិយាល័យអង្គជំនុំជម្រះវិសាមញ្ញមានអំណាចនាំយកនូវជនសង្ស័យទាំងឡាយណាដែលបានប្រព្រឹត្ត ឬក៏បញ្ជាឲ្យមានការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរក្រោមអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដូចជាអំពើប្រឆាំងនឹងមនុស្សជាតិ ឬទ្រព្យសម្បត្តិដែលការពារដោយ"ខ" ផ្សេងៗនៃអនុសញ្ញា÷

(...) ទារុណកម្ម ឬការប្រព្រឹត្តអំពើអមនុស្សធម៌ (...)" ។

អនុសញ្ញាទាំងនេះនឹងក្ដោបនូវអំពើទារុណកម្មផ្សេងៗដែលត្រូវបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្ដែដែនសមត្ថកិច្ចដែលបានរៀបរាប់ខាងលើ (ជម្លោះប្រដាប់អាវុធអន្តរជាតិ ទ្រព្យសម្បត្តិនិងប្រជាជនដែលត្រូវបានការពារ) នៃ"ខ" ផ្សេងៗក្នុងអនុសញ្ញា មិនក្ដោបនូវអំពើទារុណកម្មទាំងអស់នោះទេ ។

### ២) ទារុណកម្មជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានការឲ្យនិយមន័យផ្សេងៗគ្នា ។ ប៉ុន្ដែទោះជាយ៉ាងណាក៏មានការឲ្យនិយមន័យរួមមួយទៅលើចំណុចសំខាន់ៗភាគច្រើនស្ទើរតែទាំងអស់ ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាអំពើអមនុស្សធម៌មានលក្ខណៈធ្ងន់ធ្ងរដែលប្រព្រឹត្តឡើងក្នុងទ្រង់ទ្រាយធំនិងជាលក្ខណៈប្រព័ន្ធប្រឆាំងនឹងជនស៊ីវិលដោយហេតុផលនយោបាយ ជាតិពន្ធ ឬហេតុផលសាសនា (ហ្គេហ្វ្រី រ៉ូបឺតសុន "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ទំព័រ២៧៤ ទីក្រុងឡុង ឆ្នាំ១៩៩៩) ។ អំពើទាំងនេះត្រូវតែមានការពាក់ព័ន្ធនឹងវិធានការរបស់រដ្ឋាភិបាល ហើយបើយោងតាមនិយមន័យកាលពីក្រោយសង្គ្រាមលោកលើកទី២ អំពើឧក្រិដ្ឋកម្មទាំងនេះគឺជាឧក្រិដ្ឋកម្មប្រព្រឹត្តក្នុងលក្ខខណ្ឌជម្លោះប្រដាប់អាវុធ ។ តម្រូវការក្រោយមួយនេះត្រូវបានចាត់ទុកថាជា"ទំនាក់ទំនង"ជាមួយនឹងជម្លោះប្រដាប់អាវុធក្នុងច្បាប់អន្តរជាតិ ។

### លក្ខណៈទ្រង់ទ្រាយធំឬលក្ខណៈប្រព័ន្ធ

តាមគំនិតដែលផ្អែកលើភ័ស្ដុតាងជាក់ស្ដែង ការដែលថាទារុណកម្មត្រូវបានប្រព្រឹត្ត គឺមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់ក្រោមនិយមន័យខាងលើឡើយ ។ ការទទួលខុសត្រូវចំពោះទារុណកម្មមានលក្ខណៈជា"ទ្រង់ទ្រាយធំនិងជាប្រព័ន្ធ" ត្រូវតែបានលាតត្រដាងឲ្យច្បាស់ ។ លោក ដេវីដ ឆេនដល័រ បង្ហាញអំពីភ័ស្ដុតាងទារុណកម្មនៅមន្ទីរស-២១ថាត្រូវបានប្រព្រឹត្តឡើងដោយមានការបញ្ជា ឬការដឹងឮ និងការយល់ព្រមពីសំណាក់សមាជិកមេដឹកនាំរបស់បក្ស ។ ស្របពេលគ្នានេះដែរ មានមតិខ្លះព្យាយាមដោយហេតុផលថា អំពើឃោរឃៅភាគច្រើនខ្លះការចាត់តាំងពីមជ្ឈិមបក្ស និងត្រូវបានប្រព្រឹត្តឡើងយ៉ាងឃោរឃៅព្រៃផ្សៃដោយមិនរើសមុខ ។ របាយការណ៍របស់ក្រុមជំនាញការអះអាងលើចំណុចនេះថាៈ "ប៉ុន្ដែប្រសិនបើការអសមត្ថភាពរបស់រដ្ឋាភិបាលចំពោះមុខអំពើទាំងនេះ (អំពើឃោរឃៅរបស់ខ្មែរក្រហម) កើតមានឡើងដោយសារភាពជាសត្រូវប្រឆាំងនឹងជំហរនយោបាយនិងជំហរផ្សេងៗទៀតរបស់ជនរងគ្រោះ វាហាក់ដូចជាមានភាពស្មើគ្នាទៅនឹងលក្ខណៈជាប្រព័ន្ធ"(របាយការណ៍ទំព័រទី២០) ។

ប៉ុន្ដែទោះជាយ៉ាងនេះក៏ដោយ ក៏ការរកឃើញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដូចបានរៀបរាប់ជូននៅក្នុងសេចក្ដីផ្ដើមនៃអត្ថបទនេះ ផ្ដល់ជាភ័ស្ដុតាងសម្រាប់ធ្វើការសន្និដ្ឋានថាអំពើឧក្រិដ្ឋកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវនឹងលក្ខណៈវិនិច្ឆ័យដូចក្នុងលក្ខណៈ"ទ្រង់ទ្រាយធំនិងជាលក្ខណៈប្រព័ន្ធ" ។

### ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ

វានៅតែជាការងឿងឆ្ងល់ថាតើតម្រូវការនៃទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធនៅមានសុពលភាពនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ ។ តម្រូវការនេះមានឫសគល់របស់

វានៅក្នុងធម្មនុញ្ញរបស់តុលាការសឹកនៅទីក្រុងនូរិមប៊ឺក ហើយត្រូវបានលុបចោលនៅក្នុងការឲ្យនិយមន័យបណ្ដោះអាសន្នផ្សេងៗនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ របាយការណ៍របស់ក្រុមជំនាញការរបស់អង្គការសហប្រជាជាតិបានសរសេរថា ទំនាក់ទំនងរវាងឧក្រិដ្ឋកម្មទាំងនេះទៅនឹងជម្លោះប្រដាប់អាវុធ «កើតមានឡើងត្រឹមឆ្នាំ១៩៧៥» (របាយការណ៍នៅទំព័រទី២១) ។ គ្មានការងឿងឆ្ងល់ឡើយថា ចុងចោទនៅក្នុងតុលាការមួយដែលធ្វើឡើងសម្រាប់កាត់ក្ដីពីបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ អាចលើកយកចំណុចនេះដោយព្យាយាមបង្ហាញថា តម្រូវការនៃទំនាក់ទំនងគឺនៅតែមានសុពលភាពត្រឹមឆ្នាំ១៩៧៥ ។ ប្រសិនបើប្រការនេះត្រូវបានទទួលយកដោយតុលាការមែននោះ វានឹងមានន័យថាការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗចំពោះឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ក្រោមនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចត្រឹមតែត្រូវបានបង្កើតដោយសារតែវាមានទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធប៉ុណ្ណោះ ។

រ៉ាត់នែរ និង អាប្រាម (ការទទួលខុសត្រូវចំពោះអំពើឃោរឃៅចំពោះសិទ្ធិមនុស្សនៅក្នុងច្បាប់អន្តរជាតិអុកស្វ៊ត ១៩៩៧ ទំព័រទី២៨៧) បានអះអាងថា ប្រវត្តិវិទូមិនបានភ្ជាប់បន្ទុកនៃអំពើឃោរឃៅរបស់ខ្មែរក្រហមទៅនឹងជម្លោះប្រដាប់អាវុធដែលមានការពាក់ព័ន្ធគ្នាឡើយ ។ អ្នកនិពន្ធបានធ្វើសេចក្ដីសន្និដ្ឋានចំពោះប្រធានបទនេះថា ទំនាក់ទំនងដែលបន្ថែមទៅនឹងជម្លោះប្រដាប់អាវុធ នឹងការពារជនដៃដល់មិនឲ្យមានការទទួលខុសត្រូវជាអន្តរជាតិ ។

ទោះជាយ៉ាងណាក៏ដោយ យោងតាមការសិក្សាដ៏ទូលំទូលាយនៃឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារទាំងនេះផ្តល់ជាភ័ស្តុតាងដ៏លើសលប់គាំទ្រឲ្យមានការរកឃើញទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហមចំពោះប្រជាជនខ្លួនឯងនេះម្យ៉ាង និងម្យ៉ាងទៀតជាមួយនឹងអត្ថិភាពនៃជម្លោះប្រដាប់អាវុធដែលរបបនោះមានការពាក់ព័ន្ធក្រោមអំណាចដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ (រ៉ាយម៉ាន់ ហ្សុនសិនៈ «តម្រូវការនៃឯកសារការទាក់ទងរបស់ខ្មែរក្រហម» និង «ទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ» មិនទាន់បោះពុម្ពផ្សាយ ភ្នំពេញ ឆ្នាំ១៩៩៩) ។

ពង្រាងច្បាប់ស្ដីអំពីការបង្កើតការិយាល័យចៅក្រមវិសាមញ្ញនៅក្នុងតុលាការ បានចែងនៅក្នុងមាត្រាទី៥ថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺ «រាល់អំពើទាំងឡាយណាដែលត្រូវបានប្រព្រឹត្តចូលទៅក្នុងលក្ខណៈវាយប្រហារជាទ្រង់ទ្រាយធំនិងជាប្រព័ន្ធប្រឆាំងនឹងជនស៊ីវិលនៃជាតិមួយ ក្រុមនយោបាយ ក្រុមជាតិពន្ធ ក្រុមជនជាតិ ឬក្រុមសាសនា ដូចជា (...) ទារុណកម្ម(...)» ។ ការដែលថាតម្រូវការនៃទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធមិនត្រូវបាននិយាយដល់ មិនមែនមានន័យថាតម្រូវការនេះត្រូវបានលុបចោលនោះទេ ។ ប្រសិនបើតម្រូវការនេះនៅតែមានសុពលភាពនៅឡើយនៅក្នុងឆ្នាំ១៩៧៥ នោះវាមិនអាចត្រូវបានលុបចោលទេ ។

### ៣) ទារុណកម្មជាឧក្រិដ្ឋកម្មសារធាតុមួយក្រោមច្បាប់អន្តរជាតិ

គោលការណ៍មួយក្នុងចំណោមគោលការណ៍សំខាន់ផ្សេងទៀតនៃច្បាប់ព្រហ្មទណ្ឌគឺថា គ្មានអំពើទាំងឡាយណាត្រូវបានផ្ដន្ទាទោសដោយគ្មានច្បាប់ជាធរមាននៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្តនោះទេ ហៅជាភាសាឡាតាំងថា nullum cimen sine lege ។ ដូច្នេះការកាត់ក្ដីថាអំពើទារុណកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាឧក្រិដ្ឋកម្មដាច់ដោយឡែកមួយក្រោមច្បាប់អន្តរជាតិ វាតម្រូវឲ្យមានការអនុវត្តតាមច្បាប់អន្តរជាតិនាសម័យនោះ ។

ការដែលថាតើអំពើទារុណកម្មជាឧក្រិដ្ឋកម្មដាច់ដោយឡែកមួយក្រោមច្បាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥ពិតឬមិនពិតនោះ វាអាស្រ័យទៅលើភ័ស្តុតាងជាក់ស្ដែងដែលបង្ហាញថា ការហាមប្រាមការប្រព្រឹត្តអំពើទារុណកម្មពិតជាបទដ្ឋានដាច់ខាតដ៏សំខាន់នៃច្បាប់អន្តរជាតិ ដែលហៅថាបទដ្ឋាន "jus cogens" ។ បទដ្ឋានមួយមុនពេលក្លាយជា jus cogens គឺត្រូវតែបានទទួលយកនិងទទួលស្គាល់ដោយរដ្ឋសហគមន៍អន្តរជាតិ ថាជាបទដ្ឋានមួយដែលមិនអាចរំលោភបាន ។ ប្រសិនបើមានបទដ្ឋានមួយ (ឧទាហរណ៍ៈ ហាមមិនឲ្យធ្វើទារុណកម្មលើមនុស្ស) ត្រូវបានចាត់ទុក

ដោយភាគច្រើននៃសហគមន៍អន្តរជាតិថាជាផលប្រយោជន៍សំខាន់ចំពោះរដ្ឋទាំងអស់នោះ រដ្ឋនីមួយៗត្រូវតែមានកាតព្វកិច្ចគោរពធ្វើតាមបទដ្ឋាននោះ ទោះរដ្ឋមួយណានោះមិនពេញចិត្តក៏ដោយ ។

មានការបង្អុលបង្ហាញតាមផ្លូវច្បាប់ថា អំពើទារុណកម្មត្រូវបានទទួលស្គាល់ថាជាបទដ្ឋានមួយត្រឹមឆ្នាំ១៩៧៥ ។ មានការទទួលស្គាល់រួចមកហើយថាអំពើទារុណកម្មជាឧក្រិដ្ឋកម្មស្ថិតក្រោមក្របខ័ណ្ឌនៃ“ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ”និង“ឧក្រិដ្ឋកម្មសង្គ្រាម” ។ សេចក្តីទូទៅស្តីពីសិទ្ធិមនុស្ស (ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនាថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨) និងកិច្ចព្រមព្រៀងអន្តរជាតិស្តីអំពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ (ដែលចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៥) ហាមមិនឲ្យធ្វើទារុណកម្មឡើយ ។ ក្នុងសេចក្តីសម្រេចចិត្តលេខ៣៤៥២ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៥ អង្គមហាសន្និបាតរបស់អង្គការសហប្រជាជាតិបានអនុម័តនិងចេញសេចក្តីប្រកាសស្តីអំពីការការពារជនគ្រប់រូបមិនឲ្យមានការធ្វើទារុណកម្មនិងរងនូវអំពើឃោរឃៅអមនុស្សធម៌ ឬការបន្ទាបបន្ថោកផ្សេងៗទៀត ឬការដាក់ទណ្ឌកម្ម ។ សេចក្តីប្រកាសនេះត្រូវបានអនុម័តនិងដាក់ឲ្យចុះហត្ថលេខាលើសច្ចាប័នព្រមទាំងដាក់ឲ្យប្រើប្រាស់រួចហើយ ។

ប្រសិនបើភស្តុតាងដែលយ៉ាងហោចណាស់ជាបទដ្ឋានចេញមកពីឧក្រិដ្ឋកម្មអន្តរជាតិ មានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញថាពិតជាមានបទដ្ឋានដាច់ខាតមែននោះ វានឹងកាត់បន្ថយបន្ទុករបស់តុលាការក្នុងការរកភស្តុតាងប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះការប្រព្រឹត្តអំពើទារុណកម្ម ។ **(នៅមានត)** **យ៉ន ខ៉ាន់ គ្រីនធីន**

## សេចក្តីកែតម្រូវ

ទស្សនាវដ្តីស្វែងរកការពិតលេខ៨ ទំព័រ៤៨ អត្ថបទដែលមានចំណងជើងថា “ស្នាដៃតាម៉ុក” ត្រង់កូឡោនទី១ បន្ទាត់ទី៤ ដែលសរសេរថា “...សម្រាកកាយនៅលើទគ្រែកក្រោយពី...” សូមកែមកជា “...សម្រាកកាយនៅលើគ្រែទឹកក្រោយពី...”វិញ ។

សូមអរគុណ ។



សាកសពជនរងគ្រោះនៅគុកទួលស្លែង

# សៀវភៅខ្មៅ

## យុទ្ធសាស្ត្រ "សហព័ន្ធឥណ្ឌូចិន" របស់បក្សកុម្មុយនិស្តឥណ្ឌូចិន របស់ហូជីមិញ

*បោះពុម្ពផ្សាយដោយមន្ទីរឃោសនាការនិងព័ត៌មាននៃ*
*ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ*
*ខែកញ្ញា ឆ្នាំ១៩៧៨*

**ទី១ បក្សកុម្មុយនិស្តឥណ្ឌូចិន និងកម្មវិធីនយោបាយរបស់បក្សនេះ**

បក្សវៀតណាមត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៣០ ដោយមានឈ្មោះថា "បក្សកុម្មុយនិស្តឥណ្ឌូចិន" ។ ដំបូងឈ្មោះ "បក្សកុម្មុយនិស្តឥណ្ឌូចិន"មានន័យយ៉ាងច្បាស់ ហើយយ៉ាងគ្រប់គ្រាន់ថាបក្សនេះគឺជាបក្សមួយសម្រាប់ប្រទេសទាំងបីនៅ "ឥណ្ឌូចិន" ។ ជម្រើសឈ្មោះនេះមានសារៈសំខាន់ចំពោះផ្នែកនយោបាយ ។ ឡេនីន ប្រធានកុម្មុយនិស្តអន្តរជាតិដ៏ល្បីល្បាញពុំបានដាក់ឈ្មោះបក្សរបស់ខ្លួនថាជា"បក្សកុម្មុយនិស្តអឺរ៉ុប"ទេ ។ ហេតុដូច្នោះឈ្មោះដែលផ្តល់ទៅឲ្យបក្សវៀតណាមមានន័យថា បក្សនេះគឺជាបក្សតែមួយនិងជាបក្សដូចគ្នាសម្រាប់ប្រទេសវៀតណាម ឡាវ និងកម្ពុជា ។ ជម្រើសយកឈ្មោះបែបនេះបង្ហាញថា គោលដៅរបស់បក្សនេះគឺដើម្បីត្រួតត្រាប្រទេសទាំងបី ។

**ទី២** លក្ខន្តិកៈនៃបក្សកុម្មុយនិស្តឥណ្ឌូចិនបានចែងថា បក្សនេះត្រូវកសាង"ឥណ្ឌូចិនឯករាជ្យពេញលេញ"មួយ ។ ពាក្យស្លោករបស់បក្សនេះគឺ ធ្វើការតស៊ូដើម្បីឲ្យមានឥណ្ឌូចិនឯករាជ្យមួយ ដើម្បីបង្កើតបានជា"សហព័ន្ធឥណ្ឌូចិន" ។ ជាផលវិបាក កម្មវិធីនយោបាយជាយុទ្ធសាស្ត្ររបស់បក្សវៀតណាមគឺជា"សហព័ន្ធឥណ្ឌូចិន" ។ បក្សនេះមានបេសកកម្មមួយដើម្បីដឹកនាំកម្ពុជា ឡាវ និងវៀតណាម នៅក្នុងការតស៊ូរបស់ខ្លួនប្រឆាំងនឹងអាណានិគមនិយមបារាំង ដើម្បីរំដោះប្រទេសទាំងបី កសាងបាននូវសហព័ន្ធមួយដែលមានស្ថាប័ន

គ្រប់វិស័យៈ យោធា សេដ្ឋកិច្ច នយោបាយ និងក្នុងវិស័យដទៃទៀត ។ ស្ថាប័នទាំងនេះនៅក្រោមការដឹកនាំរបស់បក្សតែមួយ គឺ«បក្សកុម្មុយនិស្តឥណ្ឌូចិន»ដែលមានន័យថាជាប្រទេសតែមួយ ប្រជាជនតែមួយ និងយោធាតែមួយ ។ ចាប់តាំងពីឆ្នាំ១៩៣០ មក ដើម្បីសម្រេចបាននូវកម្មវិធីនយោបាយជាយុទ្ធសាស្ត្រនេះ វៀតណាមបានរៀបចំកម្លាំងរបស់ខ្លួន ហើយហ្វឹកហ្វឺនកម្មាភិបាលវៀតណាមដើម្បីបញ្ជូនកម្មាភិបាលទាំងនោះជាបន្តបន្ទាប់ទៅធ្វើការនៅប្រទេសឡាវនិងកម្ពុជា ។

**ទី៣ ការអនុវត្តយុទ្ធសាស្ត្រវៀតណាមរបស់«សហព័ន្ធឥណ្ឌូចិន» នៅក្នុងប្រទេសកម្ពុជា និងសភាពការណ៍សំខាន់ៗចន្លោះឆ្នាំ ១៩៣០ និង ១៩៧៦**

ក) រយៈកាលចន្លោះឆ្នាំ១៩៣០ និង ១៩៤៥

នៅក្នុងរយៈពេល១៥ឆ្នាំនេះវៀតណាមបានអនុវត្តសកម្មភាពនៅក្នុងប្រទេសកម្ពុជានិងប្រទេសឡាវ ក៏ប៉ុន្តែវៀតណាមមានចំណុចខ្សោយជាច្រើន ។ ម្យ៉ាងកម្មាភិបាលរបស់វៀតណាមមានចំនួនតិចតួច ម្យ៉ាងទៀតវៀតណាមរវល់ជាប់ដៃនៅក្នុងស្រុក ។ ម្យ៉ាងវិញទៀត ប្រទេសវៀតណាមពុំទាន់មានការបង្រួបបង្រួមគ្នានៅឡើយ ។ វៀតណាមត្រូវបានបែងចែកជាបីផ្នែកៈ តុងកឹង អាណ្ណាម និងកូសាំងស៊ីន ។ បក្សកុម្មុយនិស្តឥណ្ឌូចិនគឺជាអង្គការវៀតណាមតែមួយគត់គ្មានពីរ ហើយមួយផ្នែកនៃបក្សនេះមានតួនាទីផ្សេងៗពីគ្នា ។ កម្មាភិបាលវៀតណាមនៅពេលនោះមានការមមាញឹកជាមួយនឹងភារកិច្ចនៅក្នុងស្រុក ។ ជាងនេះទៅទៀត មូលដ្ឋានសកម្មភាពសំខាន់ៗគឺនៅវៀតណាមភាគខាងជើង និងជាពិសេសនៅយែនតុន (ប្រទេសចិន) ។ នៅក្នុងកាលៈទេសៈទាំងនេះ វៀតណាមពុំមានកម្មាភិបាលគ្រប់គ្រាន់ដើម្បីអនុវត្តសកម្មភាពនានានៅក្នុងប្រទេសឡាវនិងកម្ពុជាទេ ។

ដោយមូលហេតុនេះហើយដែលសកម្មភាពរបស់វៀតណាមនៅក្នុងរយៈពេលនេះពុំសម្រេចបាននូវលទ្ធផលអ្វីឡើយ ។ ម្យ៉ាងវិញទៀតប្រជាជនកម្ពុជាគឺជាប្រជាជនមួយដែលពុំយល់ពីកុម្មុយនិស្ត ហើយប្រជាជនកម្ពុជាស្អប់វៀតណាម ។ ជាផលវិបាក វៀតណាមពុំបានទទួលបានជោគជ័យនៅក្នុងការជ្រៀតចូលទៅក្នុងប្រទេសកម្ពុជាទេ ។ តាមពិតមានប្រជាជនវៀតណាមនៅក្នុងទឹកដីកម្ពុជា ក៏ប៉ុន្តែប្រជាជនវៀតណាមទាំងនោះពុំទទួលឥទ្ធិពលដោយសារកុម្មុយនិស្តទេ ។ ជាសង្ខេប កងកម្លាំងសត្យានុម័តិរបស់វៀតណាមនៅខ្សោយ ហើយប្រជាជនកម្ពុជាពុំទទួលយកការឃោសនារបស់វៀតណាមឡើយ ។

**ខ) រយៈកាលចន្លោះឆ្នាំ១៩៤៥ និង ឆ្នាំ១៩៥៤**

នៅចន្លោះឆ្នាំ១៩៤០-៤១ វៀតណាមបានបើកការតស៊ូប្រដាប់អាវុធរបស់ខ្លួននៅក្បែរព្រំដែនជាមួយចិន ហើយវៀតណាមបានបង្កើតរណសិរ្សវៀតណាម ។ នៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥ ជប៉ុនបានធ្វើរដ្ឋប្រហារមួយផ្តួលរំលំអាណានិគមបារាំង ។ វៀតណាមឆ្លៀតឱកាសនេះបង្កើនឥទ្ធិពលរបស់ខ្លួនក្នុងចំណោមជនរួមជាតិរបស់ខ្លួន ហើយវៀតណាមបានប្រមែប្រមូលកងកម្លាំងនានាដើម្បីចូលរួមកម្លាំងជាមួយវៀតមិញ ។ នៅថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៤៥ វៀតណាមបានទាញយកផលចំណេញពីការបរាជ័យរបស់ជប៉ុនដើម្បីធ្វើ«បដិវត្តន៍ខែសីហា»មុនពេលដែលពួកអាណានិគមនិយមបារាំងមកដល់ ។ ក្រោយមក វៀតណាមបានបញ្ជូនកម្មាភិបាលរបស់ខ្លួនមួយចំនួនចូលមកកូសាំងស៊ីននិងកម្ពុជា ។

ភ្នាក់ងារវៀតមិញបានមកដល់ហើយគេណែទ័ពក្នុងចំណោមជនជាតិខ្មែរដែលមកពីវណ្ណៈអ្នកមាននិងមានទ្រព្យសម្បត្តិធូរធារនៅកម្ពុជាក្រោម ។ វៀតណាមបានទាក់ទងជាមួយ ប៉ាច ជឿន, ប៉ៅសែន កុសល, ឈឹម ទុំ, យូ ឆាន់, ជា អ៊ុំ ដែលបានរត់ភៀសខ្លួនពីកម្ពុជាទៅជ្រកកោននៅកម្ពុជាក្រោមបន្ទាប់ពីការបរាជ័យរបស់វៀតណាម ហើយនៅពេលដែល សឺង ង៉ុកថាញ់ នាយករដ្ឋមន្ត្រីនាពេលនោះ (ហើយជាឧទាហរណ៍របស់ពួកយោធានិយមរបស់ជប៉ុន) ត្រូវបានពួកអាណានិគមនិយមបារាំងចាប់ខ្លួន ។

ដោយប្រឈមមុខនឹងស្ថានការណ៍បែបនេះ វៀតណាមបានព្យាយាមទាក់ទងជាមួយខ្មែរដទៃទៀតព្រមទាំងជនជាតិខ្លួនដែលរស់នៅកម្ពុជាក្រោម ។ ម្យ៉ាងវិញទៀត នៅភាគបូព៌ានិងនិរតីនៃប្រទេសកម្ពុជា វៀតណាមបានចាប់ពង្រត់ជនជាតិខ្មែរជាច្រើនយកទៅបណ្តុះបណ្តាលនិងប្រើប្រាស់ដើម្បីបម្រើយុទ្ធសាស្ត្រ

«សហព័ន្ធឥណ្ឌូចិន» នៅក្នុងប្រទេសកម្ពុជា ។

ក៏ប៉ុន្តែអាណានិគមនិយមបារាំងក៏មានគោលការណ៍របស់ខ្លួនដែរ ។ បារាំងបានជ្រៀតជ្រែកបញ្ចូលភ្នាក់ងារស៊ើបអង្កេត ប៉ូលិស និងទាហានរបស់ខ្លួន ទៅក្នុងជួរវៀតមិញ ។

ជាផលវិបាក កម្មាភិបាលដំបូងដែលហ៊ឹកហ៊ឺនដោយវៀតមិញ គឺជាប្រជាជនដែលពួកវៀតមិញបានចាប់ពង្រត់ និងជាភ្នាក់ងារដែលពួកអាណានិគមនិយមបារាំងបញ្ចូលទៅក្នុងជួរវៀតមិញ ។

នៅក្នុងឆ្នាំ១៩៤៧ វៀតណាមមានប្រជាជនកើនឡើងច្រើនទៅៗនៅខាងខ្លួន ហើយសកម្មភាពរបស់វៀតណាមកាន់តែរីករាលដាលជាបន្តបន្ទាប់មកលើភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជា ដែលនៅទីនោះវៀតណាមបានប្រមែប្រមូលប្រជាជនដែលនៅសេសសល់ពីក្រុម ដាប ឈួន, កែវ តក់, ហូវ វង្សអនុភាព និង ឈឹម ទុំ ។

ក្រោយមកទៀត ដើម្បីអនុវត្តសកម្មភាពនានានៅក្នុងប្រទេសកម្ពុជា វៀតណាមបានរៀបចំកម្ពុជាឲ្យទៅជាទឹកដីភូមិភាគរួមមានភូមិភាគសំខាន់៣ គឺភូមិភាគនិរតី ពាយ័ព្យ និងភូមិភាគបូព៌ា ។

នៅភាគឦសាន វៀតណាមបានមកបង្កើតមូលដ្ឋានយោធា និងមូលដ្ឋាននយោបាយរបស់ខ្លួននៅភូមិភាគបូព៌ានៃខេត្តស្ទឹងត្រែង ក្បែរបរកែវ ពីព្រោះថានៅក្នុងប្រទេសរបស់វៀតណាម វៀតណាមពុំមានទឹកដី ហើយក៏ពុំមានមូលដ្ឋានដែរ ។

ក្រោយមកវៀតណាមបានបែងចែកតំបន់ទាំងនោះទៅជាខេត្ត ស្រុក និងឃុំ ។ វៀតណាមបានគ្រប់គ្រងអ្វីៗគ្រប់បែបយ៉ាង ។ វៀតណាមមានគណៈកម្មាធិការមួយសម្រាប់គ្រប់គ្រងខ្មែរ ហៅថា «មុតគាហា» ។ ចំពោះកងកម្លាំងប្រដាប់អាវុធ សូម្បីតែនៅចន្លោះខែឧសភា និងខែមិថុនា ឆ្នាំ១៩៥៤ មានន័យថា ១ខែមុនកិច្ចព្រមព្រៀងក្រុងហ្សឺណែវ គណៈកម្មាធិការនេះស្ទើរតែចំណុះដោយសមាសភាពវៀតណាមទាំងស្រុង ។ វៀតណាមបានក្តោបក្តាប់រដ្ឋអំណាចនិងយោធានៅក្នុងដៃរបស់ខ្លួន ។ ឈ្មោះរបស់អង្គការទាំងនេះគឺជាខ្មែរ ក៏ប៉ុន្តែសមាសភាពពិតគឺវៀតណាម ។ ហេតុដូច្នេះចាប់តាំងពីឆ្នាំ១៩៤៥ ដល់ឆ្នាំ១៩៥៤ កម្មាភិបាលខ្មែរដំបូងមានសមាសភាពជាប្រជាជនដែលត្រូវបានចាប់ពង្រត់ដោយវៀតណាម ។ វៀតណាមបានអប់រំនិងប្រើប្រាស់កម្មាភិបាលទាំងនេះដើម្បីអភិវឌ្ឍកម្លាំងរបស់ខ្លួន ។

## ក) រយៈកាលចន្លោះឆ្នាំ១៩៥៤និងឆ្នាំ១៩៧០

បន្ទាប់ពីកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ជនបដិវត្តកម្ពុជាបានបង្កើតឡើងនូវចលនាជាតិមួយដើម្បីឯករាជ្យនិងអព្យាក្រឹតភាពប្រឆាំងនឹងកិច្ចព្រមព្រៀងយោធារបស់អង្គការសន្ធិសញ្ញាអាស៊ីភាគអាគ្នេយ៍ ហើយបានប្រមែប្រមូលមហាជនឲ្យគាំទ្រគោលការណ៍៥ចំណុចនៃការរស់នៅស្រុះស្រួលគ្នាដោយសន្តិភាពគោលនយោបាយបញ្ចសីលា ។ នៅវៀតណាម ង៉ោ ឌិញយៀម បានសម្លាប់សមាជិករបស់បក្សជាច្រើន ហើយជនបដិវត្តនានាត្រូវបានបោសសម្អាតអស់៧០ភាគរយនៅចន្លោះឆ្នាំ១៩៥៧ និង១៩៥៨ ។ គណៈកម្មាធិការបក្សវៀតណាមខាងត្បូងត្រូវបានបោសសម្អាតឲ្យហ្មត់ ។ បន្ទាប់មកបក្សនេះត្រូវបានស្តាររៀបចំឡើងវិញ ស្រាប់តែត្រូវបានបោសសម្អាតឲ្យខ្ទេចជាថ្មីម្តងទៀត ។ បដិវត្តន៍វៀតណាមបានបាត់បង់នូវការគ្រប់គ្រងលើសភាពការណ៍នេះ ហើយជានិច្ចកាលស្ថិតនៅក្នុងដំហរការពារខ្លួន ។ ក្រោយមក ជនបដិវត្តវៀតណាមជាច្រើនបានមកជ្រកកោននៅក្នុងប្រទេសកម្ពុជា ។ កម្ពុជាអព្យាក្រឹតបានក្លាយទៅជាសមរភូមិក្រោយរបស់វៀតណាមដែលវៀតណាមបានប្រើប្រាស់ជាជម្រកដើម្បីលាក់ខ្លួន ហើយមិនតែប៉ុណ្ណោះជាកន្លែងរង់ចាំបន្តដំណើរឆ្ពោះទៅក្រុងហុងកុងនិងយៃនតុននៅក្នុងប្រទេសចិន ។

នៅក្នុងឆ្នាំ១៩៥៧ ឡេ យន់ លេខាធិការទីមួយនាពេលបច្ចុប្បន្នរបស់បក្សវៀតណាម ក៏បានមកជ្រកកោននៅក្រុងភ្នំពេញ ហើយយកប្រទេសកម្ពុជាជាកន្លែងឆ្លងកាត់ ។ សមាជិកគណៈកម្មាធិការមជ្ឈិមរបស់បក្សវៀតណាមនៅវៀតណាមខាងត្បូងត្រូវបានចាប់ខ្លួន លើកលែងតែសមាជិកម្នាក់គត់ដែលមកជ្រកកោននៅក្រុងភ្នំពេញនៅក្នុងខណ្ឌទួលទំពូង គឺ ង្វៀន វ៉ាន់ លិញ ហៅ មួកុក ជាជនជាតិវៀតណាមខាងជើង ។ បច្ចុប្បន្ន ង្វៀន វ៉ាន់ លិញ គឺជាសមាជិកនៃការិយាល័យនយោបាយរបស់បក្សវៀតណាម ។ មិនតែប៉ុណ្ណោះ ហាយ សូ បានមកជ្រកកោននៅក្នុងប្រទេសកម្ពុជាដែលអព្យាក្រឹតនិងមានស្ថិរភាព វៀតណាម

អាចរស់នៅដោយមានសុវត្ថិភាព ។

ដោយប្រឈមមុខនឹងស្ថានភាពមហន្តរាយ និងដើម្បីគេចចេញពីការបោសសម្អាតស្ទើរតែទាំងស្រុងនៅក្នុងឆ្នាំ១៩៦០ វៀតណាមបានសម្រេចធ្វើការតស៊ូប្រដាប់អាវុធជាថ្មីម្តងទៀត ។ វៀតណាមបានមកបោះទីតាំងនៅតាមបណ្តោយព្រំដែនកម្ពុជា ចាប់តាំងពីកំពង់ត្រាច (ខេត្តស្វាយរៀង) រហូតដល់ស្រុកស្នួល (ខេត្តក្រចេះ) ។ នៅពេលដែលវៀតណាមបានជួបប្រទះនឹងការលំបាកនានា វៀតណាមបានពង្រីកការជ្រៀតចូលរបស់ខ្លួនកាន់តែខ្លាំងឡើងៗ ដោយប្រើប្រាស់អំពើពុករលួយប្រសិនបើចាំបាច់ ។ ពួកវៀតកុងអាចធ្វើដំណើរដោយសេរីនិងតាមអំពើចិត្តទូទាំងប្រទេសកម្ពុជា ។ ម្យ៉ាងគឺដោយសារវៀតណាមបានធ្វើឲ្យភ្នាក់ងារសន្តិសុខ ប៉ូលិស និងបុគ្គលិករាជការនៃរដ្ឋាភិបាលមុនងប់ងុលនឹងអំពើពុករលួយ ហើយម្យ៉ាងទៀតដោយសារប្រជាជនបានចាត់ទុកវៀតណាមជាជនបដិវត្ត ។ នៅក្នុងឆ្នាំ១៩៦៥ មានទ័ពវៀតកុងប្រមាណ១សែន៥ម៉ឺននាក់បានបោះទីតាំងនៅក្នុងប្រទេសកម្ពុជាប្រហែល២ទៅ៥គីឡូម៉ែត្រពីព្រំដែន ចាប់ពីស្រុករមាសហែក (ខេត្តស្វាយរៀង)ដល់ខេត្តរតនគិរី នៅក្នុងតំបន់"កន្ទុយនាគ" នៅភាគឦសាននៃប្រទេសកម្ពុជា ។ ក្នុងឆ្នាំ១៩៦៦ ចំនួននេះបានកើនឡើងដល់២សែននាក់ ហើយបានបន្តកើនឡើងទៀតនៅក្នុងឆ្នាំ១៩៦៧ ។


រូបថតក្នុងសមរភូមិប្រយុទ្ធ

នៅពេលនោះវៀតណាមបានឃោសនានៅគ្រប់ទីកន្លែងដើម្បីឲ្យពិភពលោកជឿថាវៀតណាមសម្រេចបាននូវ"ជោគជ័យដ៏ត្រចះត្រចង់" ។ តាមពិតវៀតណាមបានជ្រកកោននៅក្នុងទឹកដីកម្ពុជា ។ អ្នកទាំងឡាយណាដែលពុំបានដឹងការពិតនេះបានគិតថាវៀតកុងបានជួយបដិវត្តន៍កម្ពុជា ។ តាមពិតវៀតកុងពុំមានទឹកដីនៅវៀតណាមខាងត្បូងទេ ។ ដោយគោលនយោបាយភូមិសាស្ត្រសម្រាប់បម្រើឲ្យមេទ័ពអាមេរិកនៅវៀតណាម រ៉ូប៊ឺត ថមសុន ផ្អែកលើបទពិសោធន៍ដែលគាត់ទទួលបាននៅក្នុងបណ្តាប្រទេសដទៃ បានបង្កើតឡើងនូវភូមិសាស្ត្រទូទាំងទឹកដីវៀតណាមខាងត្បូងដើម្បីកុំឲ្យវៀតកុងមានទឹកដីនិងប្រជាជន ។

មាគ៌ានយោបាយរបស់វៀតណាមលើបញ្ហានេះគឺខុសស្រឡះ ។ មាគ៌ានយោបាយនោះរួមមាន "ធ្វើការតស៊ូនៅនឹងកន្លែង" "គ្រប់គ្រងប្រជាជននិងរក្សាប្រជាជនទាំងនោះនៅមួយកន្លែង" ។ សម្រាប់គោលដៅនេះវៀតណាមបានរៀបចំធ្វើបាតុកម្មធំៗចាប់តាំងពីឆ្នាំ១៩៦០ដល់ឆ្នាំ១៩៦៥ ។ ក៏ប៉ុន្តែចាប់តាំងពីឆ្នាំ១៩៦៥មក កងកម្លាំងវៀតណាមមានភាពធូររលុងយ៉ាងខ្លាំង ពីព្រោះសត្រូវបានគ្រប់គ្រងលើប្រជាជនធ្វើឲ្យមានអំពើពុករលួយនិងពាលាអាវ៉ាសែនៅក្នុងចំណោមប្រជាជន ។ នៅភាគខាងត្បូងនៃប្រទេសវៀតណាម សមាជិកបក្សវៀតណាមដែលបានរស់នៅក្នុងភូមិយុទ្ធសាស្ត្រទាំងនោះត្រូវបានគេណែនាំយកទៅធ្វើជាទាហានរបស់ក្រុមធីវគី ។ ប្រហែល៧០-៨០ភាគរយនៃបុរសក្មេងៗសមាជិកអង្គការបក្សវៀតណាម ត្រូវបានគេណែនាំបញ្ចូលទៅក្នុងយោធារបស់សត្រូវ ។ យុវជនវ័យក្មេង២០-៣០ភាគរយទៀតចុះចូលជាមួយសត្រូវហើយបានបោះបង់ចោលនូវការតស៊ូរបស់ខ្លួន ។ ពុំមាននរណាម្នាក់ដឹកនាំចលនាតស៊ូរបស់ប្រជាជនដែលស្ថិតនៅក្រោមការ

គ្រប់គ្រងរបស់ពួកចក្រពត្តិអាមេរិកនិងក្រុមរបស់ធីវគីឡើយ ។

ចាប់តាំងពីឆ្នាំ១៩៦១ ដល់ឆ្នាំ១៩៦៣ ខ្សែក្រវាត់ការពាររបស់ក្រុងព្រៃនគរបានដាក់ពង្រាយទ័ពរហូតដល់ហ្កាឌិញ ។ ក្នុងឆ្នាំ១៩៦៤ ខ្សែក្រវាត់ការពារកាន់តែរីកធំឡើងៗ ហើយលាតសន្ធឹងរហូតដល់ព្រំដែនកម្ពុជា-វៀតណាម ។ បន្ទាប់មកពួកវៀតកុងបានចូលមកក្នុងប្រទេសកម្ពុជាដើម្បីជ្រកកោន ហើយបានបង្កើតជាសេវាកម្មផ្សេងៗដែលរួមមានៈ កងកម្លាំងប្រដាប់អាវុធ មន្ទីរពេទ្យ ក្រុមសិល្បៈ គមនាគមន៍ គណៈកម្មាធិការផ្សេងៗ អង្គការដឹកនាំរបស់ខ្លួនចាប់តាំងពីគណៈកម្មាធិការមជ្ឈិមរហូតដល់ទៅគណៈកម្មាធិការខេត្តនិងស្រុក ។ ជាឧទាហរណ៍ គណៈកម្មាធិការខេត្តគងដុកត្រូវបង្កើតឡើងនៅកោះញែក នៅក្នុងខេត្តមណ្ឌលគិរីនៅកម្ពុជា ។ ក្នុងឆ្នាំ១៩៧០ ចំនួនពួកវៀតកុងដែលបោះទីតាំងនៅកម្ពុជាប្រែប្រួលក្នុងចន្លោះពី១លាន ៥សែននាក់ទៅ២លាននាក់ ។ មានយុទ្ធជនដែលរងរបួសចំនួន ៨ម៉ឺននាក់ បានទទួលការយកចិត្តទុកដាក់ព្យាបាលនៅមន្ទីរពេទ្យដែលកសាងឡើងនៅក្នុងទឹកដីកម្ពុជា ។

បដិវត្តន៍កម្ពុជានិងប្រជាជនកម្ពុជាបានក្លាយជាអ្នករងចាំទទួលផលពីការប្រទានរបស់វៀតណាម ។ ប្រជាជនកម្ពុជាជានិច្ចកាលបានផ្តល់ជំនួយនិងការគាំទ្រដល់វៀតកុង ផ្តល់ឲ្យពួកវៀតកុងនូវកន្លែងលាក់ខ្លួននិងទីជម្រក ផ្តល់ឲ្យពួកវៀតកុងនូវអង្ករនិងម្ហូបអាហារ ។ បដិវត្តន៍កម្ពុជានិងប្រជាជនកម្ពុជាបានផ្តល់ឲ្យពួកវៀតកុងនូវជំនួយនិងការគាំទ្រចាប់តាំងពីឆ្នាំ១៩៥៥ នោះគឺជាពេលដែល ង៉ោ ឌិញយៀម កំពុងបើកយុទ្ធនាការគាបសង្កត់យ៉ាងសាហាវឃោរឃៅបំផុតប្រឆាំងនឹងវៀតណាម ។ ប្រជាជនកម្ពុជាបានផ្តល់ឲ្យប្រជាជនវៀតណាមនូវការគាំទ្រនិងជំនួយចាប់តាំងពីឆ្នាំ១៩៦០ គឺនៅពេលដែលវៀតណាមបើកយុទ្ធនាការតស៊ូប្រដាប់អាវុធ ។ បដិវត្តន៍កម្ពុជានិងប្រជាជនកម្ពុជាបានធ្វើដូច្នោះពីព្រោះយល់ថាវៀតណាមជាមិត្តនិងជាជនបដិវត្ត ។ ទោះបីជាយ៉ាងណាក៏ដោយ វៀតណាមនៅពេលនោះពុំបានបំភ្លេចពីយុទ្ធសាស្ត្រលេបទឹកដីកម្ពុជាឡើយ ។



ពាក្យស្លោករបស់វៀតណាមគឺ «សាមគ្គីភាពក្នុងចំណោមប្រទេសទាំងបី» «កម្ពុជា ឡាវ និងវៀតណាម គឺជាមិត្តប្តូរផ្តាច់នឹងគ្នាដែលពុំអាចកាត់ផ្តាច់បាន ប្រយុទ្ធប្រឆាំងនឹងសត្រូវរួម» ។ ប្រជាជនកម្ពុជានិងបដិវត្តន៍កម្ពុជាបានជឿថាខ្លួនជាប្រជាជនស្មោះត្រង់ ។ តាមពិតវៀតណាមបានប្រើប្រាស់ពាក្យស្លោកសាមគ្គីភាពដើម្បីជ្រៀតចូលមកក្នុងចលនាបដិវត្តរបស់កម្ពុជា ។ វៀតណាមបានប្រឹងប្រែងចងមិត្តភាពជាមួយកម្មាភិបាលកម្ពុជា និងប្រជាជនកម្ពុជា ក្រោយមកបញ្ចូលអ្នកទាំងនោះទៅក្នុងអង្គការរបស់ខ្លួន ។ វៀតណាមបានរៀបចំអ្នកដែលធ្លាប់បានធ្វើការតស៊ូប្រឆាំងនឹងពួកអាណានិគមបារាំង ហើយបញ្ចូលអ្នកទាំងនោះទៅក្នុងបក្សកុម្មុយនិស្តឥណ្ឌូចិន ។ នៅទីណាដែលវៀតណាមទៅដល់ វៀតណាមបង្កបញ្ហានិងភាពឥតសណ្តាប់ធ្នាប់ អនុវត្តនូវអំពើវិទ្ធង្សនា ហើយនិងសកម្មភាពចារកម្ម ។ ចាប់តាំពីឆ្នាំ១៩៦៧មកប្រជាជននិងកម្មាភិបាលនានាបានក្រោកឡើងប្រឆាំងយ៉ាងខ្លាំងក្លាចំពោះសកម្មភាពរបស់វៀតណាម ក៏ប៉ុន្តែមេដឹកនាំបដិវត្តន៍កម្ពុជាជានិច្ចកាលជូនអនុសាសន៍ដល់វៀតណាមឲ្យបង្កើតសាមគ្គីភាពនិងការជួយគ្នាទៅវិញទៅមក ដើម្បីអនុវត្តយុទ្ធសាស្ត្រ

“សហព័ន្ធឥណ្ឌូចិន”របស់វៀតណាម ដើម្បីវាតទីនិងលេបយកទឹកដីកម្ពុជា ។ ហេតុដូច្នេះទោះបីជាស្ថិតនៅក្នុងការប្រឈមមុខនឹងសភាពការណ៍ដ៏ពិបាកយ៉ាងនេះក៏ដោយ ក៏វៀតណាមពុំបោះបង់ចោលនូវយុទ្ធសាស្ត្រនេះដែរ ។

តាមរយៈការទាក់ទងទាំងនេះវៀតណាមព្យាយាមមើលថាតើមានឯកភាពពុំមានឯកភាពគ្នាទេ ចំពោះគោលនយោបាយតស៊ូប្រដាប់អាវុធរបស់បក្សកុម្មុយនិស្តកម្ពុជា ។ វៀតណាមបានអូសយកទៅខាងខ្លួននូវរដ្ឋាភិបាលទាំងឡាយណាដែលពុំមានគោលជំហររឹងប៉ឹង ។ វៀតណាមបានរៀបចំនិងបង្កើតឡើងនូវរដ្ឋអំណាចស្របពេលជាមួយគ្នានេះដោយសម្ងាត់ ។ វៀតណាមបានប្រយុទ្ធនិងជាន់ឈ្លីបក្សកុម្មុយនិស្តកម្ពុជា ដោយនិយាយថាគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាខុសឆ្វេងនិយម និងមានលក្ខណៈផ្សងព្រេងជាដើម ។ល ។ ចំពោះជនជាតិកម្ពុជាដែលបានសិក្សានៅវៀតណាមខាងជើង វៀតណាមបានប្រគល់សៀវភៅរបស់ ឡេនីន មានចំណងជើងថា “ភាពឆ្វេងនិយម ជំងឺកុម្មុយនិស្តដ៏ក្មេងខ្ចី” ។ វៀតណាមបានរឹតបន្តឹងការប្រយុទ្ធរបស់ខ្លួនប្រឆាំងនឹងបក្សកុម្មុយនិស្តកម្ពុជានៅពេលដែលការតស៊ូប្រដាប់អាវុធនៅកម្ពុជាបានផ្ទុះចេញមកនៅក្នុងឆ្នាំ១៩៦៨ ។

នៅក្នុងពេលដដែលនេះ វៀតណាមបានបង្កើតទំនាក់ទំនងនៅតាមតំបន់រដ្ឋបាល ដើម្បីពង្រីកភាពមិនចុះសម្រុងគ្នា និងការបែងចែកនៅក្នុងបក្សកុម្មុយនិស្តកម្ពុជា ។ នៅក្នុងពេលទន្ទឹមនឹងគ្នានេះ វៀតណាមធ្វើវិទ្ធង្សនាបំផ្លាញសេដ្ឋកិច្ចកម្ពុជា ។ ម្ខាងវៀតណាមប្រើប្រាស់ការរត់ពន្ធតាមរយៈទីផ្សារងងឹត និងម្ខាងទៀតវៀតណាមលួចយកអាហារពីប្រជាជនដូចជាផលិតផលកសិដ្ឋាន ជ្រូក មាន់ទា ជាដើម ។ល ។

បទពិសោធន៍ទាំងអស់នេះមានភាពល្វីងជូរចត់ចំពោះប្រជាជនកម្ពុជានិងបដិវត្តន៍កម្ពុជា ។ ចាប់តាំងពីឆ្នាំ១៩៦៥មក ចលនាតស៊ូរវាងជនបដិវត្តកម្ពុជានិងវៀតកុងបានប្រែក្លាយជាតានតឹងនិងស្រួចស្រាល់យ៉ាងខ្លាំង ។ វៀតណាមមកកម្ពុជាមិនមែនដើម្បីតែស្វែងរកជម្រកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រឹងប្រែងវាតទីនិងលេបយកប្រទេសកម្ពុជាទាំងមូល ។ ទោះបីជាវៀតណាមស្ថិតនៅក្នុងស្ថានភាពដ៏លំបាកបំផុត ក៏វៀតណាមនៅតែបន្តរៀបចំកងកម្លាំងយុទ្ធសាស្ត្ររបស់ខ្លួនគ្រប់ទីកន្លែងទាំងអស់ ដើម្បីវាយផ្តួលរំលំអំណាចបដិវត្តន៍របស់កម្ពុជាពេលណាឱកាសមកដល់ ។

នៅភាគឦសាននៃប្រទេសកម្ពុជា វៀតណាមមានការលំបាកក្នុងការអនុវត្តយុទ្ធសាស្ត្ររបស់ខ្លួនដោយសារវត្តមានមេដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជា ។ វៀតណាមព្យាយាមទាញយកការគាំទ្រពីប្រជាជន ក៏ប៉ុន្តែវៀតណាមពុំទទួលបានជោគជ័យទេ ។ នៅពេលដែលកម្ពុជារួបរួមគ្នាយ៉ាងស្អិតរមួតក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជា វៀតណាមមានការភ័យខ្លាចចំពោះប្រជាជនកម្ពុជា ។ វៀតណាមព្យាយាមបំពេញចិត្តបដិវត្តន៍កម្ពុជា ។ វៀតណាមបានមកសុំការអនុញ្ញាតជាដំបូងពីបក្សកុម្មុយនិស្តកម្ពុជាមុននឹងបង្កើតជំរំរបស់ខ្លួន ពីព្រោះថាប្រសិនបើវៀតណាមចង់ដណ្តើមសមិទ្ធផលជាមួយប្រជាជនកម្ពុជា ប្រជាជនកម្ពុជានឹងផ្តន្ទាទោសវៀតណាម ។ ប្រសិនបើវៀតណាមហ៊ានប៉ះជាមួយប្រជាជនកម្ពុជា វៀតណាមនឹងបាត់បង់អត្ថប្រយោជន៍សេដ្ឋកិច្ចនិងនយោបាយទាំងអស់ ។ ម្យ៉ាងវិញទៀត តំបន់នេះគ្របដណ្តប់ទៅដោយព្រៃខ្ពាត់ខ្ពែង ដោយផ្លូវលំតូចៗជាច្រើន ដែលមានតែប្រជាជនកម្ពុជាទេទើបស្គាល់ច្បាស់នូវភូមិសាស្ត្រនេះដូចបាតដៃ ។ ហើយដោយតំបន់នេះមានអន្ទាក់និងចម្រូងអាចបណ្តាលឲ្យស្លាប់មនុស្សជាច្រើន ដែលដាក់ដោយប្រជាជននៅតាមផ្លូវទាំងនោះ វៀតណាមពុំអាចរត់បានឆ្ងាយទេ ។ ប្រជាជនភាគឦសានមានចំនួនតិច (ពី៣ម៉ឺនទៅ៤ម៉ឺននាក់) ប៉ុន្តែវៀតណាមខ្លាចប្រជាជនភាគឦសានខ្លាំងណាស់ ពីព្រោះថាប្រជាជនតំបន់នេះមានភក្តីភាពស្មោះត្រង់ចំពោះបដិវត្តន៍កម្ពុជា ។

នៅតាមតំបន់វាលរាប វៀតណាមទទួលបានជោគជ័យក្នុងការបន្ទំភ្នាក់ងាររបស់ខ្លួនចូលទៅក្នុងចំណោមប្រជាជននិងកម្មាភិបាលកម្ពុជា ។ វៀតណាមធ្វើដូច្នេះបានតាមរយៈអំពើពុករលួយប្រើសម្ភារជានុយ ឬតាមរយៈ“បក្សកុម្មុយនិស្តឥណ្ឌូចិន” ។

នៅក្នុងឆ្នាំ១៩៧០ តួលេខពួកវៀតកុងនៅកម្ពុជាបានកើនឡើងដល់១លាន៥សែននាក់ ។ នៅក្នុងតំបន់ឦសាន ទ័ពវៀតណាម

មានចំនួនពី២សែនទៅ៣សែននាក់ ។ សមាជិកគណៈកម្មាធិការបក្សវៀតណាម និងលេខាភូមិភាគកណ្តាលរបស់វៀតណាមខាងត្បូងដែលជាភូមិភាគទី៩របស់វៀតណាម បានរស់នៅក្នុងភូមិភាគត្បូងឡសាននៃប្រទេសកម្ពុជា ។ យោធាវៀតណាមនៃភូមិភាគទី៩កំពុងតែថយចំនួនស្រឹតៗដែរ ។ គណៈកម្មាធិការវៀតណាមសម្រាប់វៀតណាមខាងត្បូងត្រូវបានបង្កើតឡើងនៅស្រុកមេមត់ ក្នុងភូមិភាគបូព៌ានៃប្រទេសកម្ពុជា ។ សមាជិកគណៈកម្មាធិការនេះគឺ ង្វៀន ធី ថាញ់, ផាម ហុង, ង្វៀន វ៉ាន់ លិញ ហៅ មួកុក, ជិន ណាម ជុង, ហាយ សូ, ហាយ វ៉ាន់ និង វ៉ាង វ៉ាន់ថៃ ។ ង្វៀន ជី ថាញ់ ទទួលខុសត្រូវចំពោះយោធា គឺជាបុគ្គលដ៏សំខាន់មួយដែលប្រហែលជាបានជំនួសឡឺ ដួន ប្រសិនបើ ឡឺ ដួន មិនស្លាប់នាពេលក្រោយមកទេនោះ ។ ដោយត្រឡប់មកដល់រស់នៅក្នុងប្រទេសកម្ពុជាដូច្នេះ អ្វីទៅជាតួនាទីនិងសភាពការណ៍របស់វៀតណាម? ហើយតើតួនាទីនិងសភាពការណ៍កម្ពុជាយ៉ាងដូចម្តេចទៅវិញ? ។

ទឹកដីកម្ពុជាជាមួយនឹងឡាវបានក្លាយទៅជាជម្រកសម្រាប់វៀតណាម ។ ហេតុដូច្នោះកម្ពុជាបានផ្តល់ឲ្យបដិវត្តន៍វៀតណាមនូវជំនួយនិងការគាំទ្រច្រើនជាងបណ្តាប្រទេសដទៃទៀតនៅលើពិភពលោក ។ នៅប្រទេសឡាវ វៀតណាមរកបានតែជម្រកប៉ុណ្ណោះ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅកម្ពុជា វៀតណាមទទួលបាននូវ÷

-ជម្រកៈ រួមបញ្ចូលទាំងជម្រកសម្រាប់គណៈកម្មាធិការទទួលបន្ទុកដឹកនាំបដិវត្តន៍នៅវៀតណាមខាងត្បូង ។

-មូលដ្ឋានសេដ្ឋកិច្ចៈ វៀតណាមពឹងផ្អែកលើកម្ពុជាទាំងស្រុង ។ វៀតណាមរស់នៅដោយសារជំនួយដែលប្រជាជនកម្ពុជាបានផ្តល់ឲ្យ និងការទិញដូរតាមរយៈរដ្ឋអំណាចមូលដ្ឋាន ។

-ផ្លូវនៅតំបន់បូព៌ានិងឡសាននៃប្រទេសកម្ពុជាភ្ជាប់ទៅនឹងតំបន់នានាមកពីប្រទេសឡាវ និងកំពង់ផែកំពង់សោម ។ ក្នុងរយៈពេលមួយខែៗ មានការដឹកជញ្ជូនយ៉ាងច្រើនចេញពីកំពង់ផែកំពង់សោម គឺលើសលប់ជាងការដឹកជញ្ជូនតាមផ្លូវលំពីប្រទេសឡាវក្នុងរយៈពេលបីឆ្នាំទៅទៀត ។

បដិវត្តន៍កម្ពុជាបានផ្តល់អ្វីៗច្រើនណាស់ដល់វៀតណាម ។ អ្នកដែលយល់ខ្លះអំពីយុត្តិធម៌បានដឹងច្បាស់ឥតខ្វះអំពីបញ្ហានេះ ។ បក្សកុម្មុយនិស្តកម្ពុជាពុំដែលបានផ្តល់ព័ត៌មានដល់ពិភពលោកអំពីបញ្ហានេះទេ ។ ក៏ប៉ុន្តែផ្ទុយទៅវិញ វៀតណាមបានបោកប្រាស់ទស្សនៈពិភពលោកជាសាធារណៈដោយធ្វើពុតជាបានជួយកម្ពុជានៅក្នុងគ្រប់កិច្ចការអ្វីៗទាំងអស់ ។ ជាសង្ខេបចាប់តាំងពីឆ្នាំ១៩៣០ ដល់ឆ្នាំ១៩៧០ នៅក្នុងអំឡុងពេលនីមួយៗ នៅក្រោមកាលៈទេសៈណាក៏ដោយ វៀតណាមនៅតែបចេសជានិច្ច ហើយអនុវត្តសកម្មភាពនានាសំដៅវាតទីនិងលេបយកកម្ពុជាតាមរយៈយុទ្ធសាស្ត្រ“សហព័ន្ធឥណ្ឌូចិន” ។ ចាប់តាំងពីឆ្នាំ១៩៣០ដល់ឆ្នាំ១៩៥៤ វៀតណាមពុំដែលទទួលបាននូវលទ្ធផលអ្វីឡើយ ។ ចាប់តាំងពីឆ្នាំ១៩៤៥ ដល់ឆ្នាំ១៩៥៤ ហើយរហូតដល់ឆ្នាំ១៩៧០ ។ ដោយសារអ្នកដែលវៀតណាមបានបញ្ចូលទៅក្នុងជួរបដិវត្តន៍កម្ពុជា វៀតណាមបានទទួលជោគជ័យក្នុងការអនុវត្តសកម្មភាពនៅក្នុងវិស័យមួយចំនួន ។ ក៏ប៉ុន្តែជារួមគម្រោងរបស់វៀតណាមបរាជ័យពីព្រោះថាបដិវត្តន៍របស់កម្ពុជាបន្តពង្រឹងគោលជំហរឯករាជ្យនិងអធិបតេយ្យភាពរបស់ខ្លួនឥតឈប់ឈរនៅក្នុងវិស័យអង្គការមនោគមវិជ្ជា និងនយោបាយ ។

ជាបន្ថែម បដិវត្តន៍កម្ពុជាទទួលឋានៈល្អជាងបដិវត្តន៍វៀតណាមដែលពុំមានទឹកដីនិងប្រជាជន និងពុំមានសេដ្ឋកិច្ចរឹងមាំ ។

ចាប់តាំងពីឆ្នាំ១៩៥៥មក បដិវត្តន៍កម្ពុជាបានបន្តពង្រឹងឯករាជ្យភាពរបស់ខ្លួនឥតឈប់ឈរ ដោយឈរលើលក្ខខណ្ឌសត្យានុម័តិនិងអត្តនោម័តិ ។ លក្ខខណ្ឌអត្តនោម័តិគឺថា ដោយសារកិច្ចព្រមព្រៀងក្រុងប៉ារីស វៀតណាមត្រូវបានបង្ខំឲ្យដកខ្លួនចេញ ។ លក្ខខណ្ឌសត្យានុម័តិគឺថា បដិវត្តន៍កម្ពុជាត្រូវបានដឹកនាំដោយជនបដិវត្តកម្ពុជា ដោយមានឯករាជ្យភាពពេញលេញ ។ ដូច្នេះបដិវត្តន៍អាចប្រមូលយកបទពិសោធន៍ដ៏ច្រើនសន្ធឹកសន្ធាប់ ហើយបង្កើនសមត្ថភាពនិងលទ្ធភាពបានយ៉ាងខ្លាំងក្លា ។ នៅក្នុងឆ្នាំ១៩៦៦ បក្សកុម្មុយនិស្តកម្ពុជាបានពង្រឹងនិងពង្រីកគោលជំហរឯករាជ្យអធិបតេយ្យភាពរបស់ខ្លួន ហើយបញ្ជាក់យ៉ាងច្បាស់នូវសារជាតិពិតរបស់វៀតណាម ។

**ចប់**

# តើការលើកលែងទោសគឺជាតម្លៃនៃសន្តិភាពនៅកម្ពុជាឬយ៉ាងណា?

**(តពីលេខមុន)** នៅពេលដែលសម្តេចសីហនុផ្តល់នូវការលើកលែងទោសដែលនិយាយស្រពេចស្រពិលនៅក្នុងឆ្នាំ១៩៩៦ ពុំមានអ្នកណាច្បាស់ថាតើការលើកលែងទោសនេះគ្រាន់តែជាការលើកលែងទោសមួយពីសាលក្រមប្រហារជីវិតដោយតុលាការកំបាំងមុខបង្កើតឡើងដោយវៀតណាមនៅក្នុងឆ្នាំ១៩៧៩ ឬក៏ជាការលើកលែងទោសមួយពីការជំនុំជម្រះក្តីក្នុងពេលអនាគត ។

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានរំឭកដល់អ្នករិះគន់បស្ចិមប្រទេសថា បញ្ហាទាំងនេះគឺជាបញ្ហាផ្សារភ្ជាប់នឹងនយោបាយ ហើយបានរិះគន់យ៉ាងជូរចត់ចំពោះទំនាក់ទំនងមុខពីររបស់អាមេរិកជាមួយនឹងច្បាប់អន្តរជាតិៈ «អាមេរិកពុំទទួលស្គាល់សាលក្រមតុលាការឆ្នាំ១៩៧៩ ។ បន្ទាប់ពី អៀង សារី ត្រូវបានកាត់ទោសនៅក្នុងក្រុងភ្នំពេញ អៀង សារី បានទៅក្រុងញូវយ៉កថ្លែងសុន្ទរកថា ។ តើមានន័យដូចម្តេច? អៀង សារី បានថ្លែងសុន្ទរកថា នៅឯអង្គមហាសន្និបាតអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៧៩ ១៩៨០ ១៩៨១ គឺរយៈពេល ៣ឆ្នាំ ។ ហេតុអ្វីបានជាប៉ូលិសអន្តរជាតិឬប៉ូលិសក្រុងញូវយ៉កមិនចាប់ អៀង សារី ហើយបញ្ជូនមកឲ្យយើង? អ្វីចឹងអ្វីទៅជាការពិត? អ្វីទៅជាភាពពិតនោះ? វាត្រូវតែផ្លាស់ប្តូរទៅតាមស្ថានភាពនយោបាយ ។ នៅពេលដែលអាមេរិកមានតម្រូវការផ្នែកនយោបាយឲ្យមានការគាំទ្រដល់ អៀង សារី អាមេរិកក៏និយាយថា អៀង សារី អត់បានប្រព្រឹត្តខុសក្រិដ្ឋកម្មអ្វីទេ ។ បន្ទាប់មកអាមេរិកខ្លួនឯងនិយាយផ្សេងទៅវិញនៅក្នុងកាលៈទេសៈខុសៗគ្នា» ។

ទោះបីជារដ្ឋមន្ត្រីការបរទេសអាមេរិក ម៉ាដឺលីន អលប្រាយ បានមានប្រសាសន៍ដោយក្តីរំភើបអំពីការចាប់ខ្លួននិងការកាត់ទោស ប៉ុល ពត ក៏ដោយ ក៏ការពិតគឺស្ថិតនៅក្នុងដៃសម្តេច ហ៊ុន សែន ទៅវិញទេ ។ ភាពពិតដ៏ក្រៀមក្រំគឺថា សហរដ្ឋអាមេរិកធ្លាប់បានប្រឆាំងនឹងកិច្ចខិតខំប្រឹងប្រែងសព្វបែបយ៉ាងដើម្បីដាក់ទណ្ឌកម្មមេដឹកនាំខ្មែរក្រហមនៅពេលដែលកម្ពុជាគិតគូរពីបញ្ហានេះក្នុងដើមទសវត្សរ៍ឆ្នាំ៨០ ។ នៅពេលដែលការប្តេជ្ញាចិត្តរបស់អាមេរិកចំពោះរបបខ្មែរក្រហមត្រូវបានសាកល្បងជាសាធារណៈនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៩ បន្ទាប់ពីការលុកលុយរបស់វៀតណាមមកក្នុងប្រទេសកម្ពុជា លោក សាយរ៉ុស វ៉េន តំណាងរដ្ឋាភិបាលលោកប្រធានាធិបតី ជីមី ខាធ័រ បានបោះឆ្នោតគាំទ្ររបបខ្មែរក្រហមដែលត្រូវបានបណ្តេញចេញពីអំណាចនិងអនុញ្ញាតឲ្យខ្មែរក្រហមអង្គុយកៅអីនៅអង្គការសហប្រជាជាតិនៅក្នុងអង្គមហាសន្និបាតអង្គការសហប្រជាជាតិ ។ សូម្បីតែនៅចុងរដូវស្លឹកឈើជ្រុះឆ្នាំ១៩៨០ (ខែតុលា-វិច្ឆិកា) បន្ទាប់ពីវៀតណាមបើកឲ្យអ្នកសារព័ត៌មានបរទេសចូលមកក្នុងប្រទេសកម្ពុជា ហើយផ្សព្វផ្សាយភាពភ័យរន្ធត់នៃរបបប្រជាធិបតេយ្យរបស់ ប៉ុល ពត ទៅខាងក្រៅ តំណាងថ្មីរបស់សហរដ្ឋអាមេរិកឈ្មោះលោក អេដមុន ម៉ាស្គី បានបោះឆ្នោតគាំទ្ររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឲ្យរក្សានូវកៅអីរបស់ខ្លួននៅអង្គការសហប្រជាជាតិ ។

ទោះបីជាយ៉ាងណាក៏ដោយ សព្វថ្ងៃនេះសភាពការណ៍វាខុសប្លែកគ្នាច្រើនពីពេលនោះដោយហេតុថា ជោគវាសនានៃមេដឹកនាំខ្មែរក្រហមដែលនៅរស់រួមមាន អៀង សារី ខៀវ សំផន តាម៉ុក នួន ជា ឌុច ឥឡូវនេះគឺស្ថិតនៅក្នុងដៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ។ បន្ទាប់ពីការចរចាជាមួយនឹងអង្គការសហប្រជាជាតិអស់រយៈពេលជាង១ឆ្នាំ សភាជាតិនឹងធ្វើការបោះឆ្នោតថាតើត្រូវគាំទ្រការបង្កើតឲ្យមានជំនុំជម្រះក្តីខុសក្រិដ្ឋកម្មអន្តរជាតិចម្រុះដោយមានការចូលរួមពីអង្គការសហប្រជាជាតិឬយ៉ាងណា? ក៏ប៉ុន្តែព្រះរាជបន្ទូលថ្មីៗនេះរបស់ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភាជាតិ អំពីតុលាការនិងសាលក្រមឲ្យ ឈូក រិន មេបញ្ជាការយោធាខ្មែរក្រហមរួចទោសនៅក្នុងការកាត់ទោសពីបទសម្លាប់ជនបរទេស៣នាក់នាពេលថ្មីៗនេះ ដោយចៅក្រមកម្ពុជាមួយរូបដែលប្រើប្រាស់ច្បាប់ស្តីពីការលើកលែងទោសខ្មែរក្រហម បានធ្វើឲ្យមានការងឿងឆ្ងល់ដ៏ធំមួយចំពោះជោគវាសនានៃតុលាការដែលចូលរួមដោយអង្គការសហប្រជាជាតិនាពេលអនាគត ។ ការលើកលែងទោសមិនតាមផ្លូវច្បាប់ឲ្យ អៀង សារី និងជោគវាសនាមិនទៀងទាត់នៃតុលាការចម្រុះខ្មែរក្រហមដែលចូលរួមដោយអង្គការសហប្រជាជាតិបង្កើតជាបញ្ហាដ៏លំបាកមួយគឺត្រង់ថាតើការលើកលែងទោសគឺជាតម្លៃនៃសន្តិភាពនៅកម្ពុជាឬយ៉ាងណា? **ភីតធី ម៉ារឃ្យៀ**



អគារបាក់បែកនេះជាអតីតមន្ទីរពេទ្យស្រុកចន្ទ្រា ដែលត្រូវទទួលរងការទម្លាក់គ្រាប់បែក បេ-៥២ កាលពីឆ្នាំ១៩៦៨ ។

# កេរដំណែល

(តពីលេខមុន)

## ហេតុផលរបស់លោក ហិនរី ឃីសស៊ីងជឺរ "ការទម្លាក់គ្រាប់បែក បេ-៥២ មកលើប្រទេសកម្ពុជា"

និចសុន ជាប្រធានាធិបតីដែលទទួលកេរដំណែលនូវភាពទាល់ច្រកនេះ ខ្វះលក្ខណៈសម្បត្តិជាច្រើនដើម្បីយកឈ្នះលើភាពទាល់ច្រកនេះទោះបីជាវាអាចធ្វើដូច្នេះបានក៏ដោយ ។ ទោះបីជាយ៉ាងនេះក្តី និចសុន ក៏រាប់ថាកើតចេញពី"ជំនាន់ដ៏អស្ចារ្យ"ដែរ ។ ហើយប្រធានាធិបតី និចសុន បានរិះរកមធ្យោបាយដើម្បីអនុវត្តអ្វីដែលគាត់យល់ថាជាការទាមទាររបស់ក្រុមអ្នកជំទាស់កណ្តាលដើម្បីដកខ្លួនចេញពីសង្គ្រាមវៀតណាមដ៏មានកិត្តិយស ។ ចាប់ផ្តើមពីការចរចាដំបូងជាមួយសមាជិកការិយាល័យនយោបាយវៀតណាមឈ្មោះ ឡេ ឌឹកថ ប្រធានាធិបតី និចសុន បានផ្តល់នូវតារាងកាលវិភាគមួយសម្រាប់ដកវត្តមានរបស់អាមេរិក ហើយនិងរូបមន្តជាច្រើនទៀត ដើម្បីអនុញ្ញាតឲ្យប្រជាជនវៀតណាមខាងត្បូងទទួលបានជម្រើសមួយដ៏ពិសេសសម្រាប់ខ្លួន ។ អ្វីដែលប្រធានាធិបតី និចសុន ពុំអាចទទួលយកបាន និងជាអ្វីដែលរហូតដល់ទីបញ្ចប់រដ្ឋាភិបាលក្រុងហាណូយពុំដែលឈប់ទាមទារ គឺការដាក់បន្ទុំនូវរបបកុម្មុយនិស្តមួយមកលើប្រជាជនវៀតណាមរាប់លាននាក់ដែលបានពឹងផ្អែកទៅលើពាក្យរបស់ប្រធានាធិបតីអាមេរិកមុនៗ និងជាប្រជាជនដែលបានផ្ញើជីវិតវាសនាជាមួយសហរដ្ឋអាមេរិក ។

នៅពេលដែលការចរចារកដំណោះស្រាយមួយពុំត្រូវបានសម្រេច និចសុន បានបន្តដោយអត្តនោម័តិអនុវត្តពាក្យសន្យាក្នុងការធ្វើយុទ្ធនាការដកវត្តមានអាមេរិកចេញពីប្រទេសវៀតណាម ។ នៅក្នុងដំណើរការនេះ និចសុន បានកាត់បន្ថយការស្លាប់និងរបួសរបស់ជនជាតិអាមេរិកពី ១២០០នាក់ក្នុង១ខែនៅត្រឹមដំណាច់អាណត្តិប្រធានាធិបតី ចនសុន ឲ្យនៅត្រឹម៣០នាក់ក្នុង១ខែនៅដំណាច់អាណត្តិដំបូងរបស់រដ្ឋបាល និចសុន ។ ហើយប្រធានាធិបតី និចសុន បានកាត់បន្ថយទ័ពអាមេរិកពី៥សែន៥ម៉ឺននាក់ឲ្យមកនៅត្រឹម ៣ម៉ឺននាក់ ។

ដំណាក់កាលជាច្រើននៅក្នុងដំណើរការនេះគឺមានភាពចម្រូងចម្រាសយ៉ាងច្រើន ហើយដំណាក់កាលទាំងនោះតម្រូវឲ្យយកមកពិចារណាឲ្យបានពេញលេញជាងអត្ថបទនេះ ។ ក៏ប៉ុន្តែការដែលសៀវភៅ អត្ថបទ ជាច្រើនសន្និកសន្និដ្ឋានផ្តោតទៅលើការចោទប្រកាន់ថា និចសុន ពុំចាំបាច់ពន្យារសង្គ្រាម ហើយបូជា

ជីវិតពលរដ្ឋអាមេរិកអស់ជាច្រើន ដោយចង់និយាយថា ពេលនោះមានច្រកចេញដ៏មានកិត្តិយសដែល និចសុន បានបដិសេធមិនទទួលយក វាគឺជារោគសញ្ញានៃការធ្វើមិនឲ្យមានការចុះសម្រុងគ្នាដែលវៀតណាមបានបង្កើតឡើង ។

ការបែងចែកនយោបាយ នៅពេលនោះមានសភាពស្រួចស្រាល់យ៉ាងខ្លាំងនៅក្នុងសហគមន៍អ្នកបញ្ញវន្ត ។

នៅពេលដែលខ្ញុំសិក្សានៅសកលវិទ្យាល័យថ្នាក់ក្រោយឧត្តមសិក្សានៅឡើយ បញ្ញវន្តកម្រនឹងទទួលបាននូវតំណែងខ្ពស់នៅក្នុងរដ្ឋាភិបាលណាស់ ។ ប្រសិនបើបញ្ញវន្តចង់ធ្វើអ្វីមួយដើម្បីជះឥទ្ធិពលទៅលើគោលនយោបាយ អ្នកទាំងនោះត្រូវសរសេរអត្ថបទយ៉ាងវែងស្តីអំពីបញ្ហាក្នុងពេលអនាគតយ៉ាងឆ្ងាយ ។ រដ្ឋាភិបាល កេណ្ណឌី បានធ្វើឲ្យបញ្ញវន្តមានចំណង់ចំណូលចិត្តចង់បានអំណាចនយោបាយឡើងវិញ ហើយបញ្ញវន្តទាំងនេះបានរិះរកមធ្យោបាយបង្កើតការពិភាក្សាអំពីគោលនយោបាយសម្រាប់ពេលអនាគតដ៏ខ្លីឲ្យមានរូបរាងឡើងដំបូងនៅក្នុងរដ្ឋាភិបាល ហើយបន្ទាប់ពីប្រធានាធិបតី កេណ្ណឌី ត្រូវបានធ្វើឃាតការពិភាក្សាបែបនេះក៏ត្រូវបានធ្វើឡើងនៅក្រៅរង្វង់រដ្ឋាភិបាលដែរ ។ នៅក្នុងដំណើរការនេះ បញ្ញវន្តត្រូវបានបែងចែកទៅជាពីរក្រុមៈ មួយក្រុមជាបេក្ខជនបំពេញមុខតំណែង និងមួយក្រុមទៀតជាក្រុមបដិវត្តន៍ ។ បេក្ខជនបំពេញមុខតំណែងតំណាងឲ្យការពិភាក្សារបស់អ្នកធ្វើគោលនយោបាយ រីឯក្រុមបដិវត្តន៍តំណាងឲ្យក្រុមដែលទាញហេតុផលប្រឆាំងរបស់ក្រុមអ្នកជំទាស់ ។ នៅក្នុងករណីណាមួយក៏ដោយ បញ្ញវន្តទាំងនេះបញ្ជាក់ច្បាស់ការជំទាស់របស់អាមេរិកជាជាងជួយរកវិធីជម្នះលើបញ្ហាទាំងនោះ ។ ការវិនិច្ឆ័យមួយដែលត្រូវបានធ្វើការថ្លឹងថ្លែងចំពោះវៀតណាមនៅតែជាបញ្ហាលំបាកមួយរបស់យើង មិនមែនជាបញ្ហាយុត្តិធម៌ប្រវត្តិសាស្ត្រចំពោះបុគ្គលប្រធានាធិបតីណាមួយនោះទេ ក៏ប៉ុន្តែជាការពិតជាប្រវត្តិសាស្ត្រមួយអំពីសោកនាដកម្មជាតិមួយ ។

## កេរដំណែលរបស់វៀតណាម

វៀតណាមកាត់ផ្តាច់ចំណងមនោគមវិជ្ជានិងយុទ្ធសាស្ត្រដែលជាគ្រឹះទ្រទ្រង់ភាពឆ្នើមនិយមរបស់អាមេរិក ។

ទោះបីជាគោលការណ៍នានាបានបន្តបញ្ជាក់ដោយគ្រប់ភាគីទាំងអស់ ការអនុវត្តភាពឆ្នើមនិយមពេលនេះស្ថិតនៅក្រោមជម្លោះដ៏ជ្រាលជ្រៅ ។ ចាប់តាំងពីសង្គ្រាមវៀតណាមមកមានគំនិតពាសំខាន់ក្នុងចំណោមអ្នកធ្វើគោលនយោបាយការបរទេសអាមេរិក÷

គាំទ្រការយកយុទ្ធសាស្ត្រសង្គ្រាមត្រជាក់ក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ និងឆ្នាំ ១៩៦០ មកអនុវត្តចំពោះកាលៈទេសៈថ្មី ។ សមាជិកនៃចលនាតវ៉ាប្រឆាំងនឹងសង្គ្រាមវៀតណាមដែលបានឡើងកាន់មុខតំណែងខ្ពស់នៅក្នុងរដ្ឋាភិបាលលោកប្រធានាធិបតីគ្លីនតុន ហើយនិងមនុស្សមួយជំនាន់ទៀតដែលមិនចងចាំពីទំនាស់លើបញ្ហាវៀតណាម ឥឡូវកំពុងប្រឈមមុខនឹងពិភពលោកមួយដែលខុសគ្នាស្រឡះទៅនឹងពិភពលោកដែលបានជាអ្នកធ្វើសង្គ្រាមត្រជាក់ ឬអ្នកជំទាស់នឹងសង្គ្រាមវៀតណាម ។ ដោយសារភាពរង្គោះរង្គើដោយបទពិសោធន៍សង្គ្រាមវៀតណាម អ្នកសេរីនិយមនិងបញ្ញវន្តជាច្រើនដកថយពីសមរភូមិប្រយុទ្ធ បែរទៅរកការកំណត់និយមន័យភាពឆ្នើមនិយមរបស់អាមេរិកសាជាថ្មី ទាក់ទិននឹង "បញ្ហាស្រាល" ដែលអាចដោះស្រាយបានដោយពុំចាំបាច់ប្រើអំណាចយោធា ។ ជាលទ្ធផល យុទ្ធសាស្ត្ររបស់អាមេរិកជាប្រពៃណីភាគច្រើនបានក្លាយទៅជាគំនិតដើមរបស់ពួកអភិរក្សនិយម និងពួកអភិរក្សបែបថ្មី ។ ដោយសារជានិច្ចកាលការប្តេជ្ញាចិត្តនានានៅតាមសមរភូមិដ៏សែនឆ្ងាយពីប្រទេសដែលជាការលំបាក អ្នកដឹកនាំជាតិអាមេរិកកាំងបានផ្តោតតែទៅលើការប្រឆាំងកុម្មុយនិស្តដ៏ខ្លាំងក្លា និងការប្រុងប្រយ័ត្ននៅក្នុងការថែរក្សាតុល្យភាពជាយុទ្ធស្រាស្ត ជាពិសេសចំពោះការចរចាលើការគ្រប់គ្រងសព្វាវុធ ។ នៅក្នុងរដ្ឋាភិបាលរបស់ រីហ្គែន អ្នកដឹកនាំអាមេរិកាំងក្រុមនេះបានទទួលជោគជ័យដ៏ធំក្នុងការប្រឆាំងនឹងសត្រូវសូវៀតដែលត្រូវបានចុះខ្សោយដោយខំប្រឹងពង្រីកឥទ្ធិពលខ្លាំងជ្រុលពេក ។

ទោះបីជាយ៉ាងណាក៏ដោយ ដោយសារការដួលរលំនៃសហព័ន្ធសូវៀត សេចក្តីត្រូវការឲ្យមានយុទ្ធសាស្ត្រជាតិមួយស្របទៅនឹងពិភពលោកក្រោយសង្គ្រាមលោកលើកទី២ បានធ្វើឲ្យអ្នកអភិរក្សនិយមមានភាពវង្វេងវង្វាន់ ។ ស្ទួងពី រីហ្គែន មេដឹកនាំមួយចំនួនដែលដើរតាម រីហ្គែន បន្តបញ្ជាក់ជាថ្មីនូវ

អ្វីដែល រីហ្គែន សន្យាធ្វើ ប៉ុន្តែពុំអើពើចំពោះយុទ្ធសាស្ត្រក្បាលរឹងដែល រីហ្គែន បានអនុវត្តនៅក្នុងទសវត្សរ៍ឆ្នាំ៨០ នូវអ្វីដែលស្មើនឹងយុទ្ធសាស្ត្រទប់ទល់ ។ មេដឹកនាំដែលដើរតាមគន្លងរបស់ រីហ្គែន មានការបែកខ្ញែកគ្នារវាងការតាមរកគ្រោះថ្នាក់ថ្មីមួយដើម្បីជំនួសសហភាពសូវៀតដែលងាយស្រួលនឹងរៀបចំគោលនយោបាយការបរទេសដើម្បីប្រឆាំង ហើយនិងការកំណត់និយមន័យនៃភាពឆ្នើមរបស់អាមេរិកឡើងវិញថាជាអ្នកបូជាដើម្បីបុព្វហេតុលទ្ធិប្រជាធិបតេយ្យលើពិភពលោក ។ ប្រទេសចិនគឺជាគោលដៅសម្រាប់កិច្ចខិតខំប្រឹងប្រែងបែបនេះភាគច្រើន ។ ក៏ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងនេះនៅទន់ខ្សោយណាស់ មនោគមវិជ្ជារបស់ក្រុមដឹកនាំអភិរក្សបែបថ្មីនេះនៅកម្រិតជាតិនិយមពេក ហើយគ្រោះថ្នាក់ជាសក្តានុពលក៏នៅសែនឆ្ងាយសន្ធឹម ដែលពិបាកនឹងអនុញ្ញាតឲ្យគោលនយោបាយការបរទេសក្រសោបទៅលើគ្រោះថ្នាក់នេះ ជាពិសេសប្រសិនបើយើងចង់នាំយកបណ្តាប្រទេសសម្ព័ន្ធមិត្តរបស់យើងមកខាងយើង ។ ដើម្បីបញ្ជាក់ការពិតចំពោះខ្លួនឯង ជានិច្ចកាលសហរដ្ឋអាមេរិកត្រូវក្រោកឈរឡើងដើម្បីលទ្ធិប្រជាធិបតេយ្យ ។ ប្រទេសចិនគឺជាគោលដៅសម្រាប់ឲ្យមានកិច្ចខិតខំប្រឹងប្រែងច្រើនបែបនេះ ។ ក៏ប៉ុន្តែដើម្បីកែច្នៃពិភពលោកឲ្យមានរូបរាងតាមខ្លួននោះ អាមេរិកក៏ចាំបាច់ត្រូវយល់ពីផលប្រយោជន៍របស់ខ្លួននិងកម្រិតរបស់ខ្លួន ហើយក៏មិនត្រូវរួញរាពីការកំណត់និយមន័យដែរ ។

សេចក្តីសន្និដ្ឋាននានាដែលមន្ត្រីភាគច្រើននៅក្នុងរដ្ឋាភិបាល គ្លីនតុន និងនៅក្នុងសហគមន៍សេរីនិយម បានទាញចេញមកពីសង្គ្រាមនៅវៀតណាម បង្ហាញពីការទាញហេតុផលដ៏ទាស់ដ៏ជ្រាលជ្រៅចំពោះគោលនយោបាយការបរទេសមួយរបស់អាមេរិកជាប្រពៃណី ។ មន្ត្រីទាំងនោះចាត់ទុកសង្គ្រាមត្រជាក់ថាជាការយល់ខុសមួយប្រសិនបើមិនមែនជាការបង្កើតរបស់អាមេរិកទេ ។ មន្ត្រីទាំងនេះរួញនៅចំពោះមុខទស្សនៈផលប្រយោជន៍ជាតិ ហើយមិនទុកចិត្តចំពោះការប្រើអំណាចលុះត្រាតែការប្រើអំណាចត្រូវបានស្តែងឲ្យឃើញថាបម្រើឲ្យបុព្វហេតុ«មិនអាត្មានិយម» មានន័យថា លុះត្រាតែពុំឆ្លុះបញ្ចាំងផលប្រយោជន៍ជាតិអាមេរិកជាក់លាក់ណាមួយ ។ នៅក្នុងឱកាសជាច្រើននិងនៅទ្វីបជាច្រើន ប្រធានាធិបតី គ្លីនតុន បានធ្វើការសុំទោសចំពោះទង្វើរបស់ប្រធានាធិបតីមុនៗ ដែលកើតចេញមកពីអ្វីដែលគាត់ពិពណ៌នាក្នុងន័យធៀបថាជាឥរិយាបថសង្គ្រាមត្រជាក់ ។ ក៏ប៉ុន្តែសង្គ្រាមត្រជាក់ពុំមែនជាការស្រមើស្រមៃនោះទេ ។ បញ្ហាដ៏ជ្រាលជ្រៅនៃគោលបំណងដើម្បីរស់និងជាតិបានពាក់ព័ន្ធនៅក្នុងនោះ ។ ហើយអ្នកដឹកនាំជំនាន់នេះរួមទាំងរដ្ឋាភិបាលដែលកំពុងដើរសុំទោសគេ ដែលជាទូទៅពុំសូវដឹងត្រឹមត្រូវអំពីសកម្មភាពទាំងឡាយរបស់ប្រធានាធិបតីសហរដ្ឋអាមេរិកចាប់តាំងពីប្រធានាធិបតី អេសិន ហូវ័រ មកដល់ប្រធានាធិបតី ប៊ូស ត្រូវតែលើកឡើងនូវចម្ងល់ថាហេតុអ្វីបានជាមានភាពដូចគ្នានៅអាមេរិកនៅក្នុងរដ្ឋបាលមុនៗ ។ ការសុំទោសចំពោះរយៈកាល៥០ឆ្នាំគឺជាគូនឹងការលំបាកក្នុងការប្រើប្រាស់អំណាចរបស់អាមេរិក ។ ជាឧទាហរណ៍នៅកូសូវ៉ូ គំនិតថា សកម្មភាពរបស់អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង ហៅកាត់ថា ណាតូ លើកកម្ពស់ផលប្រយោជន៍ជាតិជាប្រពៃណីទៅជាគោលការណ៍មនុស្សធម៌ជាសកល ត្រូវបានប្រើប្រាស់ដោយមេដឹកនាំទាំងអស់ជាលក្ខណៈដ៏ច្បាស់របស់អង្គការនេះ ។ ក៏ប៉ុន្តែប្រាំមួយខែក្រោយមក មេដឹកនាំដែលទាំងនេះបានដកថយរួញរាពីការអនុវត្តគោលការណ៍កូសូវ៉ូចំពោះឆេកឈ្នី ដែលនៅទីនោះការស្លាប់និងរបួសគឺឆ្ងាយហួស ដោយខ្លាចអំណាចរបស់សូវៀត ។ គោលនយោបាយការបរទេសរបស់អ្នកដែលអះអាងថាខ្លួនជាអ្នកមានសីលធម៌ដឹងខុសត្រូវ បានបកក្បាលពេញមួយជុំមករកការពិតដែលដឹងគ្រប់គ្នាថា គោលនយោបាយការបរទេសគឺជាសិល្បៈនៃអ្វីៗដែលអាចធ្វើបាន និងជាវិទ្យាសាស្ត្រនៃអ្វីៗដែលសុទ្ធតែពាក់ព័ន្ធគ្នា ។ **ប្រែសម្រួលដោយ ផាត កុសល**

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហម ផ្ញើមក
**ទស្សនាវដ្តី "ស្វែងរកការពិត"**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
ឬ Email: dccam@bigpond.com.kh

# ស្នាដៃតាម៉ុក



ខាលពិឃាតនៅឆន្លបាធីៈ គុកសង់

***(តពីលេខមុន)*** បុគ្គលិកម្នាក់ទៀតធ្វើការនៅគុកសង់ គឺជាបុគ្គលិករដ្ឋបាលឈ្មោះ ទូច រឿង ។ រឿង បានប្រាប់យើងអំពីការហូរចូលនិងហូរចេញនៃអ្នកទោសនៅគុកសង់ ។ រឿង និយាយថា រៀងរាល់១សប្តាហ៍ឬ១០ថ្ងៃម្តង មានអ្នកទោសមួយចំនួនធំត្រូវបាននាំមកគុក ជួនកាលមានដល់៨០នាក់ ជួនកាល ១០០នាក់ ជួនលើសពីនេះទៀតក៏មាន ។ រឿង ជាអ្នកទទួលខុសត្រូវខាងចុះបញ្ជីឈ្មោះនិងតាមដានប្រវត្តិរូបអ្នកទោស ។ ប្រជាជនមូលដ្ឋានត្រូវបែកដាច់មិនឲ្យឡូកឡំជាមួយប្រជាជន ១៧មេសា ហើយបុរសគេដាក់ផ្សេង ស្ត្រីដាក់ផ្សេង ។ មានអ្នកទោសខ្លះជួនកាលត្រូវបានផ្ទេរទៅកាន់កន្លែងសន្តិសុខផ្សេងៗទៀតដូចជា "មន្ទីរ១៥" នៅស្រុកកោះធំជាដើម ។ មានអ្នកខ្លះស្លាប់ដោយការបង្អត់អាហារ ហើយអ្នកខ្លះទៀតត្រូវបានសម្លាប់នៅគុក សង់តែម្តង ។ ហាក់ដូចជាគ្មានអ្នកទោសណាម្នាក់ត្រូវបានដោះលែងឡើយ ។ ដោយសារមានការហូរចូលជាប្រចាំនៃអ្នកទោសធ្វើឲ្យចំនួនអ្នកទោសនៅគុក សង់ កើនឡើងជាលំដាប់ ប៉ុន្តែរាល់ដងមានតែប្រហែលខ្ទង់រយប៉ុណ្ណោះ ។

កាលពីខែកុម្ភៈកន្លងទៅខ្ញុំបានសម្ភាសជាមួយនឹង រឿង អស់ជាច្រើនម៉ោងនៅអគារគុកបាក់បែកនោះ ។ រឿង បានប្រកែកថាគាត់មិនដែលកាប់សម្លាប់មនុស្សទេ គាត់បញ្ជាក់ថាគាត់គ្រាន់តែជាស្មៀនតែប៉ុណ្ណោះ ។ រឿង ប្រាប់ខ្ញុំថា "បញ្ជី...អ្វីដែលខ្ញុំបានធ្វើមានតែបញ្ជីអ្នកទោសនោះឯង" ។ រឿង បានបង្ហាញខ្ញុំនូវគ្រឹះនៃគុកនោះដែលជាកន្លែងដាក់ប្រជាជនថ្មី ហើយនិយាយថា មានអ្នកទោសរាប់រយនាក់ត្រូវបានឃុំឃាំងនៅទីនោះ ។ រាល់ៗយប់ជនដៃដល់សម្លាប់មនុស្សតែងតែមកនាំអ្នកទោសម្តង១៥នាក់ ម្តង២០នាក់ ហើយបណ្តើរទៅវាលពិឃាតដែលស្ថិតនៅចម្ងាយ ១គីឡូម៉ែត្រពីគុកនេះ ។ ខ្ញុំសួរគាត់ថា "បើមានមនុស្សច្រើនបែបហ្នឹង តើធ្វើម្តេចអ្នកសម្លាប់ដឹងថាអ្នកទោសណាខ្លះនឹងត្រូវយកទៅសម្លាប់រាល់យប់?" រឿង ឆ្លើយថា "គ្មានបញ្ហាទេ ពួកវាមានបញ្ជីឈ្មោះ" ។ ដោយសម្លឹងមើលមុខ រឿង ខ្ញុំក៏សួរទៀតថា "ហើយតាមពិតបញ្ជីឈ្មោះធ្វើដោយស្មៀនមែនទេ?" ។ ពេលនោះច្រមុះរបស់ រឿង រីកបិទបើក ហើយភ្នែករបស់គាត់បើកធំៗជាមួយនឹងការភ័យខ្លាចដោយគាត់ដឹងថាគាត់បានជាប់អន្ទាក់ហើយ ។ "ទេ! ទេ!" រឿងប្រកែក ។ "ទេ! មិនមែនបញ្ជីឈ្មោះនោះទេ! ខ្ញុំបានធ្វើបញ្ជីផ្សេងទៀត មិនមែនមួយនោះទេ!" ។ "អ៊ីចឹងតើនរណាធ្វើបញ្ជីនោះ?" ខ្ញុំសង្កត់សំណួរ ។ គាត់ក៏ឆ្លើយថា "អូ! វាជារឿងសម្ងាត់" ។

ក្រោយមកទៀត ខ្ញុំនិយាយលេងជាមួយនឹងអ្នកស្រុកអ្នកភូមិនៅភូមិត្រពាំងស្វា ហើយសាកសួរគាត់តើគាត់មានគំនិតបែបណាចំពោះបុគ្គលិកធ្វើការនៅគុក សង់ ដែលនៅរស់នៅឡើយនៅភូមិនេះ ។ បុរសម្នាក់ឆ្លើយថា "មានខ្លះមិនអាក្រក់ទេ ប៉ុន្តែអ្នកខ្លះយើងស្អប់" ។ ខ្ញុំសួរគាត់ទៀតថា "តើស្អប់មួយណា?" ។ គាត់ឆ្លើយថា "ខ្ញុំស្អប់ឈ្មោះ រឿង" ។ "ហេតុអ្វីស្អប់ រឿង?" ។ "យើងស្អប់ រឿង ពីព្រោះគាត់គឺជាមនុស្សម្នាក់ដែលធ្វើបញ្ជីឈ្មោះ" ។

ផ្អែកតាមអ្វីដែលយើងដឹងអំពីសកម្មភាពនិងដំណើរការរបស់គុកខ្មែរក្រហម ព្រឹត្តិការណ៍នេះអាចជារឿងពិតដែលថា រឿង បានសរសេរបញ្ជីឈ្មោះមនុស្សដែលត្រូវសម្លាប់ ។ ប៉ុន្តែហាក់ដូចជាថាមានអ្នកណាម្នាក់នៅថ្នាក់ខ្ពស់ជាងនេះពិតជាបានសម្រេចថាឈ្មោះណាខ្លះដែលត្រូវយកក្នុងមួយថ្ងៃៗ ដូចជាប្រធានគុកឈ្មោះ ម៉ុង ឬក៏លេខាតំបន់ឈ្មោះ ប្រាក់ ឬជួនកាលប្រហែលជាលេខាភូមិភាគឈ្មោះ ម៉ុក ក៏ថាបាន ។

ម៉ុក បានត្រួតពិនិត្យយ៉ាងជិតដល់នូវរាល់ការងារនៅក្នុងគុកសង់នេះ ។ មានសាក្សីជាច្រើនរួមទាំងអ្នកស្រុកនេះដែលរួចខ្លួនពីការឃុំឃាំង បានឃើញ តាម៉ុក នៅឯគុកសង់ជាប្រចាំ ។

អតីតអ្នកយាមគុកម្នាក់និយាយថា តាម៉ុកគឺជាអ្នកដែលចុះមកមើលញឹកញាប់ណាស់ ហើយពេលដែលគាត់ចុះដើរមើលម្តងៗ ច្បាស់ជាត្រូវយកមនុស្សទៅសម្លាប់ហើយ ។ "ពេលដែលគាត់មកគេយកអ្នកទោសទៅហើយ ប៉ុន្តែយើងមិនដឹងយកទៅណាឡើយ ។ ពួកខ្មែរក្រហមបានដាក់អ្នកទោសក្នុងឡានតែមិនដឹងយកទៅណាទេ ។ យើងមិនដឹងថាតើខ្មែរក្រហមយកទៅសម្លាប់ឬយ៉ាងណានោះទេ" ។ រឿងនេះហាក់ដូចជាកើតឡើងជាប្រចាំទៅហើយ ។ "តាំងពីឆ្នាំ១៩៧៧មក តាម៉ុកមកគុកសង់រាល់អាទិត្យ" ។ មានសាក្សីជាច្រើននិយាយអំពីវិសុទ្ធកម្ម (ការបោសសម្អាត) របស់ ម៉ុក ទៅលើប្រធានគុកឈ្មោះ ម៉ុង និង ម៉េង ។ អតីតអ្នកទោសនៅគុក សង់ ម្នាក់ឈ្មោះ ស៊ុម រីម ដែលបានសួរនាំពត៌មានដោយ ម៉ម កល្យាណី អ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា នៅចាំបានអំពីពេលមួយដែលតាម៉ុកធ្វើការផ្លាស់ប្តូរមេគុកៈ "ក្រោយពីគេផ្លាស់ប្តូរអ្នកដែលមើលការខុសត្រូវពីមុនមក អាម៉ុង អាម៉េង តាសែម ក៏ចូលមកកាន់កាប់ជំនួស" ។ ឆ្មាំគុកសង់ម្នាក់ឈ្មោះ ងិន ហ៊ុម ក៏បញ្ជាក់ដែរអំពីវិធីព្រៃផ្សៃក្នុងការគ្រប់គ្រងបុគ្គលិកក្រោមបញ្ជាតាម៉ុក ។ ហ៊ុម និយាយថា ពេលដែល "តាម៉ុកកាន់កាប់តំបន់នេះ (ក្នុងឆ្នាំ១៩៧៧) ប្រធានគុក សង់ (ឈ្មោះ កាសេស) ត្រូវបានសម្លាប់ដោយក្រុមខ្មែរក្រហម ហើយមានកម្មាភិបាលមួយចំនួនត្រូវជំនួសដោយមនុស្សថ្មីផ្សេងទៀត" ។ ហេតុនេះហើយបានជា ម៉ុង ក្លាយជាប្រធានគុកសង់នេះ ។ តាមសម្តីរបស់ ងិន ហ៊ុម នៅពេលដែល ម៉ុក សម្រេចថាដល់ពេលត្រូវជំនួស ម៉ុង ហើយ "កូនចៅតាម៉ុកក៏សម្លាប់ ម៉ុង ចោលភ្លាម" ។ លក្ខខណ្ឌការងារក្រោមបញ្ជារបស់ ម៉ុក ក្នុងផ្នែកសន្តិសុខមិនមានដែនការធានាសុខភាពឬក៏ចូលនិវត្តន៍ឡើយ ។

ស៊ុម រីម ត្រូវបានចាប់ខ្លួនហើយយកមកដាក់ក្នុងគុកសង់កាលពីខែកក្កដា ឆ្នាំ១៩៧៧ ជាមួយនឹងកូនពៅ២នាក់ ។ ក្នុងអំឡុងពេលដែលត្រូវឃុំខ្លួន រីម មានផ្ទៃពោះជិតគ្រប់ខែទៅហើយ ។ ប្តីរបស់គាត់ត្រូវបានចាប់ខ្លួនកាលពីខែមករា ឆ្នាំ១៩៧៧ ដោយចោទប្រកាន់ថាគាត់ធ្លាប់ធ្វើជាសមាជិកគណៈកម្មាធិការឃុំ ។ ក្រោមទារុណកម្មនៃគុកសង់ ក្រោយមកបញ្ជីបទល្មើសប្តីរបស់ រីម រួមបញ្ចូលបទល្មើសកាន់តែច្រើនថែមទៀតរហូតដល់ថាគាត់ជាភ្នាក់ងារសម្ងាត់សូវៀតកា.ហ្សេ.បេទៀតផង ។ ឆ្មាំគុកស្រីម្នាក់ឈ្មោះ ប៊ុន ដែលមើលការខុសត្រូវផ្នែកអ្នកទោសភេទស្រី បានប្រាប់ រីម ថា ប្តីរបស់គាត់ត្រូវបានវាយធ្វើបាបយ៉ាងដំណំរហូតដល់ទ្រាំលែងបានក៏ធ្វើអត្តឃាតតែម្តងទៅ ។

រីឯ តោ សំអឿន មិនសំណាងដូច ស៊ុម រីម ឡើយ ។ នៅដើមឆ្នាំ១៩៧៨ អឿន ត្រូវបានចាប់ខ្លួន ។ ប្តីរបស់នាងបានបាត់ខ្លួននៅក្នុងគុកក្រោយមួយរយៈពេលដ៏ខ្លីតែប៉ុណ្ណោះ ។ ហើយដូចជាស្ត្រីដទៃៗទៀតដែរ ទោសរបស់ អឿន គឺដោយសារតែខ្លួនបានរៀបការជាមួយបុរសដែលត្រូវបានប្រកាសថា«ខ្មាំង» ។ ព្រមជាមួយនេះដែរ កូនស្រីម្នាក់និងកូនប្រុស២នាក់របស់ អឿន ក៏ត្រូវបានប្រមូលយកទៅគុកសង់នោះដែរ ។ កូនទាំង៣របស់ អឿន ត្រូវបានសម្លាប់នៅឯគុកសង់ ។ ទោះជា អឿន ត្រូវបានខ្មែរក្រហមទុកជីវិតឲ្យក៏ដោយ ប៉ុន្តែ អឿន ត្រូវបានបង្ខំឲ្យធ្វើការងារពលកម្មជាទម្ងន់ដូចជាកាស់គល់ឈើនៅក្នុងភក់ជាដើម ។ ឥឡូវនេះស្ត្រីមេម៉ាយនិងចំណាស់រូបនេះបួសជាដូនជីនៅវត្តកោះប៊ុនលី ។ បាន សុខឃឹន ក៏ត្រូវបានចាប់ខ្លួននិងដាក់គុកសង់២-៣ខែក្រោយពីគេចាប់ប្តីគាត់យកទៅ ។ នៅពេលសួរចម្លើយនៅក្នុងគុក សុខឃឹន និយាយថា គាត់ត្រូវបានគេបង្អត់អាហារជាច្រើនថ្ងៃហើយវាយដំដោយដំបងឬស្សី ។ "ពេលដែលពួកវាសួរចម្លើយហើយអ្នកឯងឆ្លើយវាមិនរើទេ ប៉ុន្តែបើអ្នកឯងមិនឆ្លើយទេពួកវាច្បាស់ជារើអ្នកឯងមិនខាន" ។ អ្នកទោសត្រូវបានបង្ខំឲ្យដេកផ្ងាល់នឹងឥដ្ឋដោយគ្មានអ្វីគ្របដណ្តប់ខ្លួនប្រាណឡើយ ។ គាត់នៅចាំបានថាកាលនោះមាន"កូនក្មេង"ជាច្រើននាក់នៅគុកសង់ ប៉ុន្តែ"ក្នុងចំណោមអ្នកដែលគេយកទៅនោះ មានតិចណាស់ដែលរួចរស់ជីវិត" ។



**(នៅមានត)**

**ក្រេក អេចឆេសាន់**

# ការទាមទារប្រវត្តិសាស្ត្រកម្ពុជាមកវិញ៖ គណៈកម្មការស្វែងរកការពិត

**(តពីលេខមុន) ប្រធានបទទី៦៖ ការបង្កើតច្បាប់សាជាថ្មី**

ប្រធានបទសំខាន់ជាងគេទី៦គឺការបង្កើតឲ្យមានវិធានច្បាប់ក្នុងប្រទេសកម្ពុជា ។ មន្ត្រីរាជរដ្ឋាភិបាលកម្ពុជា២រូបបានផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះប្រធានបទនេះ ប៉ុន្តែវាក៏ត្រូវបានលើកឡើងដោយផ្ទាល់ឬដោយប្រយោលដោយអ្នកដែលបានផ្តល់បទសម្ភាសន៍សឹងតែគ្រប់រូប ។ ចាប់ពីខែមិថុនា ឆ្នាំ១៩៩៧ សភាជាតិពុំត្រូវបានកោះប្រជុំអស់រយៈពេល៣ខែជាប់ៗគ្នា ។ ក្រុមប្រឹក្សាធម្មនុញ្ញនៅពុំទាន់ត្រូវបានបង្កើតនៅឡើយទេ ហើយក្រុមប្រឹក្សានេះអាចបង្កើតឡើងបានលុះត្រាតែមានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ គួរឲ្យឆ្ងល់ទៅទៀតនោះគឺឧត្តមក្រុមប្រឹក្សានេះនៅពុំទាន់ត្រូវបានបង្កើតឡើងនៅឡើយទេ ។ នាខែកក្កដា ឆ្នាំ១៩៩៧ ហ៊ុន សែន បានរក្សាអំណាចតាមរយៈព្រឹត្តិការណ៍ប៉ះទង្គិចយ៉ាងខ្លាំងមួយដែលអ្នកខ្លះហៅថា“រដ្ឋប្រហារ” ដែលនេះជាការរំលោភបំពានដោយត្រង់ៗចំពោះវិធីផ្លាស់ប្តូរ



ក្រុមគ្រួសារកម្មាភិបាលខ្មែរក្រហម

រដ្ឋាភិបាលដែលមានបែងក្នុងរដ្ឋធម្មនុញ្ញ ។ សហនាយករដ្ឋមន្ត្រី អ៊ឹង ហួត ត្រូវបាន ហ៊ុន សែន គាំទ្រឡើងតាមបែបបទមួយដែលពុំមានលក្ខណៈប្រជាធិបតេយ្យ ។ រីឯអ្នកគាំទ្រទ្រង់រណឫទ្ធិចំនួន ៤០ នាក់ត្រូវបានសម្លាប់ ហើយសមាជិកសភា២០រូបទៀតដែលចងសម្ព័ន្ធភាពជាមួយទ្រង់ បានភៀសខ្លួនតាមយន្តហោះទាំងក្នុងនិងក្រោយព្រឹត្តិការណ៍ភ្លាមៗ ។ ខណៈដែលវិលត្រឡប់មកប្រទេសកម្ពុជាវិញ អ្នកទាំងនេះត្រូវប្រឈមមុខនឹងការព្រមានសងសឹកពី ហ៊ុន សែន ប្រសិនបើខ្លួនហ៊ានធ្វើការប្រឆាំងខ្លាំង ។

ការបោះឆ្នោតបានប្រព្រឹត្តទៅនៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៩៨ ក្នុងបំណងបង្ហាញឲ្យឃើញពីរូបភាពប្រជាធិបតេយ្យ ។ ដូចជាការស្មានទុក ហ៊ុន សែន បានឈ្នះឆ្នោតបន្ទាប់ពីយុទ្ធនាការ



ទិវាចងកំហឹង ២០ ឧសភា នៅខេត្តស្ទឹងត្រែង **ឆ្នាំ១៩៨៩**

ឃោសនាដែលមានការបំភិតបំភ័យចំពោះគណបក្សប្រឆាំង ។ អ្នកការទូត អ្នកវិភាគនយោបាយ និងអ្នកឃ្លាំមើលសិទ្ធិមនុស្ស បានអះអាងថាមានការបំភិតបំភ័យគ្រប់ទីកន្លែង ការត្រួតពិនិត្យមើលការបោះឆ្នោតពុំបានល្អត្រឹមត្រូវ និងឱកាសជាច្រើនចំពោះការបន្លំ ។ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និង សម រង្ស៊ី ដែលជាមេគណបក្សប្រឆាំង បានបន្តបដិសេធចំពោះលទ្ធផល ចំណែកឯអ្នកគាំទ្រចំពោះមេគណបក្សប្រឆាំងនេះដែលរស់នៅទីជនបទនិងដែលជាមុខសញ្ញានៃការឃោរឃៅនិងការគំរាមកំហែង បានទទួលរងនូវការអន្តរាយយ៉ាងធ្ងន់ធ្ងរ ។

ខណៈដែលមនុស្សគ្រប់រូបស្ថិតនៅក្រោមស្ថានការណ៍បែបនេះ អ្នកក្រីក្រនិងអ្នកប្រកបការងារដែលពុំមានការការពារតាមផ្លូវនយោបាយ គឺជាអ្នកដែលទទួលរងធ្ងន់ធ្ងរបំផុត ។ ការពុំបានអនុវត្តច្បាប់ឲ្យបានដូចៗគ្នាចំពោះមនុស្សគ្រប់រូប ការលំបាកក្នុងការប្តឹងផ្តល់ កង្វះខាតសិទ្ធិពលរដ្ឋ និងភាពរួចទោសដែលជាស្នាដៃមន្ត្រីពុំមានភាពម៉ឺងម៉ាត់ហ្មត់ចត់ក្នុងការងារ ជាឧបសគ្គពុំអនុញ្ញាតឲ្យពលរដ្ឋសាមញ្ញរស់នៅខ្ពស់ជាងកម្រិតអប្បបរមា ។ ក្នុងប្រទេសដែលសម្បូរធនធានហើយមានដីដែលអាចដាំដំណាំបាននេះគឺជាការចំអកមួយ ។ តុលាការអាចត្រូវបានលើកហេតុផលបង្ហាញថានឹងបង្កើតឲ្យមានគំរូនៃការទទួលខុសត្រូវតាមផ្លូវច្បាប់ ហើយប្រហែលជានាំឲ្យមានការវិវត្តនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ។ សំខាន់ជាងនេះទៅទៀត ដោយផ្អែកទៅលើកាលៈទេសៈបែបនេះ និងដោយផ្អែកទៅលើទស្សនៈនៃអ្នកដែលបានផ្តល់បទសម្ភាសន៍ វាជាការច្បាស់ណាស់ដែលថាប្រទេសកម្ពុជាពុំអាចបង្កើតតុលាការមួយដែលមានលក្ខណៈត្រឹមត្រូវមិនលម្អៀងដោយខ្លួនឯងបាន ។ ដូច្នេះ តុលាការបុគណៈកម្មការស្វែងរកការពិតត្រូវតែជាអន្តរជាតិ ហើយអាចដើរតួនាទីជាអ្នកជួយប្រទេសកម្ពុជាក្នុងការធ្វើឲ្យមាន



ប្រព័ន្ធច្បាប់មួយត្រឹមត្រូវនិងដំណើរការ ។

## ប្រធានបទទី៧ៈ ការអប់រំ

ប្រធានបទចុងក្រោយដែលត្រូវបានលើកឡើងក្នុងបទសម្ភាសន៍ គឺសេចក្តីត្រូវការចាំបាច់នៃការអប់រំ និងសាលារៀនល្អត្រឹមត្រូវ ។ អ្នកដែលបានផ្តល់បទសម្ភាសន៍ខ្លះបានលើកហេតុផលមកបញ្ជាក់ដែលគួរឲ្យជឿជាក់បានថា ភាពមិនចេះអក្សរក្នុងកម្រិតខ្ពស់ និងកង្វះខាតការអប់រំត្រឹមត្រូវ ជាមូលហេតុដែលនាំឲ្យខ្មែរក្រហមអាចដណ្តើមបានអំណាចគ្រប់គ្រងប្រទេសជាតិ ។ ដើម្បីការពារការវិលត្រឡប់មកវិញជាថ្មីនៃរបបគ្រប់គ្រងដែលមានលក្ខណៈបែបនេះ និងដើម្បីជួសជុលការខូចខាតដែលបានបង្កឡើងដោយខ្មែរក្រហម ការអប់រំគួរតែជាអាទិភាពដ៏ធំចម្បងបំផុត ។

ការបង្រៀនប្រវត្តិសាស្ត្រថ្មីៗរបស់កម្ពុជាក្នុងសាលានឹងបន្តជួបការលំបាករហូតដល់ពេលមានការស្រាវជ្រាវយ៉ាងជិតដល់មួយត្រូវបានធ្វើឡើង ហើយពិរុទ្ធភាពត្រូវបានបង្ហាញឲ្យឃើញតាមផ្លូវច្បាប់ ។ តាំងពីការបោះឆ្នោតនាឆ្នាំ១៩៩៣មក របបគ្រប់គ្រងដោយខ្មែរក្រហម (១៩៧៥-៩៩) ត្រូវបានដកចេញពីសៀវភៅប្រវត្តិសាស្ត្រនិងមុខវិជ្ជាសិក្សាទូទៅនៅក្នុងប្រទេសកម្ពុជា ។ បញ្ហានេះបង្កើតឲ្យមានការបារម្ភដ៏ជាក់ច្បាស់យ៉ាងតិចពីរ ។ ទី១ ប្រសិនបើក្មេងៗពុំត្រូវបានបង្រៀនពីអំពើឃោរឃៅនិងឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ក្រុមនេះឬក្រុមមួយទៀតដែលមានលក្ខណៈបែបនេះអាចទទួលបានអំណាចដឹកនាំប្រទេស ហើយចាប់ផ្តើមរបបមួយដែលគ្របដណ្តប់ដោយការភ័យខ្លាចថ្មីមួយទៀត ។ ប្រជារាស្ត្រកម្ពុជាដែលបានដឹងនិងយល់ពីហេតុផលនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឆ្នាំ១៩៧៥-៧៩ នឹងមានលទ្ធភាពច្រើនក្នុងការបង្កការវិលត្រឡប់មកវិញនៃសោកនាដកម្មបែបនេះ ។ បញ្ហាចម្បងទី២គឺប្រជាជនកម្ពុជាមួយជំនាន់ទាំងមូលនឹងពុំបានដឹងអំពីប្រវត្តិសាស្ត្រដ៏សំខាន់នៃប្រទេសរបស់ខ្លួន ។ ជនកម្ពុជាដែលបានផ្តល់បទសម្ភាសន៍ ភាគច្រើនមានបំណងប្រាថ្នាដ៏លើសលប់ចង់ដឹងពី"ការពិត"ថាតើនរណាជាអ្នកទទួលខុសត្រូវចំពោះអំពើឃោរឃៅដែលបានប្រព្រឹត្តចំពោះគ្រួសារនិងមិត្តភក្តិរបស់ខ្លួន ។ វាជាការសំខាន់ក្នុងការបំពេញបំណងដែលចង់ឲ្យ "ការពិត" ត្រូវបានទទួលយកនិងផ្សព្វផ្សាយជាផ្លូវការ ។

ការបំផ្លិចបំផ្លាញសឹងតែសាបសូន្យនូវគ្រូបង្រៀន សាស្ត្រាចារ្យ និងសាលារៀន បានធ្វើឲ្យសង្គមកម្ពុជាស្ទើរតែគ្មានសល់អ្វីទាំងអស់ ។ ជាលទ្ធផលនៃការបំបាត់ចោលថ្នាក់រៀន គ្រូបង្រៀនបានទទួលការបណ្តុះបណ្តាលយ៉ាងតិចបំផុតជាទូទៅត្រឹមតែ៦សប្តាហ៍ប៉ុណ្ណោះដើម្បីបំពេញការងាររបស់ខ្លួន ។ ប្រាក់ខែគ្រូបង្រៀនគឺពី១៥ដុល្លារអាមេរិកទៅ២៥ដុល្លារអាមេរិកក្នុងមួយខែ ។ វាគឺជាចំនួនមួយដ៏តិចតួច ទោះបីជាវាត្រូវបានលើកយកហេតុផលអំពីលទ្ធភាពចំណាយនៃសេដ្ឋកិច្ចប្រទេសកម្ពុជាមកសំអាងក៏ដោយ ។ ស្ថានភាពបែបនេះជំរុញឲ្យគ្រូបង្រៀនស្វែងរកការងារបន្ទាប់បន្សំដើម្បីចិញ្ចឹមជីវិត ដូចជាការបង្រៀនក្រៅម៉ោងបន្ថែម និងការបង្រៀនក្រៅម៉ោងពិសេសជាដើម ។ ដូច្នេះប្រព័ន្ធអប់រំដែលពុំតម្រូវឲ្យបង់ថ្លៃនេះ បានក្លាយជាប្រព័ន្ធមួយពុំសមស្រប ហើយមានតែអ្នកដែលមានថវិកាគ្រប់គ្រាន់ទេ ទើបអាចទទួលបានការអប់រំគ្រប់គ្រាន់ ចំណែកឯគ្រូបង្រៀនត្រូវបានស្វែងរកការបណ្តុះបណ្តាលដើម្បីចាប់យកអាជីពថ្មី ។

ជម្លោះដណ្តើមអំណាចជាប្រចាំក្នុងរដ្ឋាភិបាលចម្រុះអាណត្តិមុនបង្ហាញឲ្យឃើញថា ការផ្តោតទៅលើការសាងសង់សាលារៀនថ្មីៗជាការចង់បង្ហាញឲ្យឃើញពីសំណង់អគារថ្មីៗជាជាងការយកចិត្តទុកដាក់ទៅលើគុណភាពគ្រូបង្រៀននិងកម្មវិធីសិក្សា ។ ការអប់រំពុំមែនជាកាតព្វកិច្ចឡើយសម្រាប់ប្រទេសកម្ពុជា ដូច្នេះក្មេងជាច្រើនបានបោះបង់ចោលការសិក្សាជាពិសេសក្មេងដែលឪពុកម្តាយស្ថិតក្នុងស្ថានភាពមួយដែលតម្រូវឲ្យមានចំណូលបន្ថែម ។ សូម្បីតែអ្នកដែលចូលសាលាក៏ប្រឈមនឹងបញ្ហាមួយចំនួនដែរដូចជា គ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិមិនគ្រប់គ្រាន់ ថ្នាក់រៀនមិនទៀងទាត់និងមានរយៈពេលខ្លី ។ បញ្ហានេះក៏កើតមាននៅថ្នាក់ឧត្តមសិក្សាដែរ ។ មហាវិទ្យាល័យឯកជនព្យាយាមអូសទាញសាស្ត្រាចារ្យល្អៗពីមហាវិទ្យាល័យរដ្ឋ ។ ខណៈដែលនិស្សិតភាគច្រើននៃមហាវិទ្យាល័យរដ្ឋស្ថិតនៅក្នុងគ្រួសារដែលមានជីវភាពធូរធារ ការស្នើឲ្យមានការបង់ថ្លៃត្រូវបានទទួលការបដិសេធយ៉ាងខ្លាំងក្លា ព្រោះឪពុកម្តាយនៃនិស្សិតទាំងអស់នេះជាទូទៅជាសមាជិករដ្ឋាភិបាល ។ ស្ថានភាពមិនល្អនៃការអប់រំនៅក្នុងប្រទេសកម្ពុជា

នឹងគ្រាន់តែជួយធ្វើឲ្យគម្លាតយ៉ាងច្បាស់រវាងអ្នកមាននិងអ្នកក្រ កាន់តែធំឡើងប៉ុណ្ណោះ គឺបណ្តោយទុកឲ្យអ្នកក្រីក្រអវិជ្ជា ហើយផ្តល់ការអប់រំសម្រាប់តែអ្នកមានដែលមានប្រាក់បង់ ។

ស្ថានភាពនេះវាក្លាយទៅជា«ការជីករណ្តៅកប់ខ្លួនឯង» នៅពេលដែលប្រជាជនដែលពុំទទួលបានការអប់រំអំពីលទ្ធិប្រជាធិបតេយ្យបានត្រឹមត្រូវ មានការលំបាកក្នុងការជ្រើសរើសយកតំណាងផ្នែកនយោបាយដែលបម្រើផលប្រយោជន៍របស់ខ្លួន ។ ដោយពិតទៅ តាមដែលមន្ត្រីរដ្ឋាភិបាលកម្ពុជាមួយរូបបានប្រាប់ខ្ញុំក្នុងខេត្តមួយថា ពលរដ្ឋបោះឆ្នោតជ្រើសរើសយកតំណាងដែលពូកែឃោសនា ព្រោះមូលហេតុសាមញ្ញបំផុតគឺប្រជាជនចូលចិត្តការឃោសនានោះ ។ ជាងនេះទៅទៀត ភាពទន់ខ្សោយនៃសេដ្ឋកិច្ចអាចនាំទៅដល់ការគ្មានការជ្រើសរើសតាមផ្លូវនយោបាយមួយដ៏ពិតប្រាកដ ។ តាមដែលយល់បាន ប្រជាជនក្រីក្រទុក៏តបារម្ភអំពីបញ្ហាចំណីអាហារនិងជម្រក ជាជាងការវិភាគស្ថានភាពនយោបាយក្នុងតំបន់របស់គាត់ ហើយអាចត្រូវបានអូសទាញដោយបេក្ខជនដែលផ្តល់ឲ្យនូវផលប្រយោជន៍ជាសម្ភារផ្សេងៗដើម្បីទទួលបាននូវសន្លឹកឆ្នោត ។ អ្នកនយោបាយបែបនេះនឹងប្រហែលជាមិនតំណាងឲ្យអត្ថប្រយោជន៍របស់អ្នកបោះឆ្នោតក្នុងអាណត្តិរបស់ខ្លួនឡើយ ហើយកម្រិតជីវភាពរបស់ប្រជាជនក្រីក្រធ្វើឲ្យមានការលំបាកក្នុងការប្រឈមជាមួយអ្នកនយោបាយដែលធ្វើឲ្យគាត់ខកចិត្ត ។ កង្វះខាតនៃការអប់រំបានបង្ហាញឲ្យឃើញពីឥទ្ធិពលអាក្រក់របស់វាតាមរយៈការបោះឆ្នោត ហើយគួរតែត្រូវបានយកចិត្តទុកដាក់កែលម្អ ។

## គណៈកម្មការស្វែងរកការពិត

## ព្រះពុទ្ធាខានៈ "ពៀររំងាប់ដោយការមិនចងពៀរ"

ពត៌មានដែលទទួលបានពីការសិក្សានេះបានឲ្យដឹងថា ប្រជាជនកម្ពុជាខ្វះរូបភាពរួមនៃប្រវត្តិសាស្ត្ររបស់ខ្លួន ។ ទស្សនៈរួមមួយចាំបាច់ណាស់ចំពោះការព្រមព្រៀងគ្នាក្នុងសង្គមនិងសន្តិភាព (ពោលគឺដើម្បីជួសជុលអំពើអាក្រក់ដែលបានប្រព្រឹត្តដោយខ្មែរក្រហម និងដើម្បីបង្ការការកើតមានឡើងវិញនូវអំពើឃោរឃៅទាំងនេះនាពេលអនាគត តាមរយៈការអប់រំ) ។ បច្ចុប្បន្នតុលាការហាក់ដូចជាហៀបនឹងកើតឡើងសម្រាប់ប្រទេសកម្ពុជា ។ ដោយហេតុថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនអាចមិនផ្តន្ទាទោសការកំហិតដែលកើតចេញពីរចនាសម្ព័ន្ធរបស់តុលាការអាចបដិសេធការចូលរួមរបស់ប្រជាជនកម្ពុជាក្នុងការយល់ដឹងអំពីការពិតដ៏ពេញលេញមួយអំពីរបបខ្មែរក្រហម ។ គណៈកម្មការស្វែងរកការពិតអាចផ្តល់នូវរូបភាពមួយផ្សេងនៃប្រវត្តិសាស្ត្រកម្ពុជាពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ហើយដូច្នេះ គឺជាធាតុមួយចាំបាច់សម្រាប់តុលាការ ។ បើពុំមានការបង្កើតនូវរូបភាពមួយពេញលេញនៃប្រវត្តិសាស្ត្រកម្ពុជាជាបឋមទេនោះ វាអាចលំបាកសម្រាប់ប្រជាជនកម្ពុជាក្នុងការកំណត់ឲ្យបានច្បាស់លាស់ថាសមាជិកខ្មែរក្រហមណាមួយត្រូវកាត់ទោស ។

ចំពោះករណីដោយឡែកនៃប្រទេសកម្ពុជា គណៈកម្មការស្វែងរកការពិតហាក់ដូចជាធាតុមួយដ៏សែនសំខាន់សម្រាប់នយោបាយចំពោះអំពើឃោរឃៅដែលបានប្រព្រឹត្តឡើងដោយខ្មែរក្រហម ។ ទី១ គណៈកម្មការស្វែងរកការពិតឆ្លើយតបទៅនឹងសេចក្តីប្រាថ្នារបស់ប្រជាជនកម្ពុជាក្នុងការចង់ដឹងចង់ឮអំពីពត៌មានពាក់ព័ន្ធទៅនឹងខ្មែរក្រហម និងខ្សែសង្វាក់នៃការបញ្ជាច្រើនជាងតុលាការ ។ ទី២ «ការផ្សះផ្សាជាតិ»គឺជាគោលដៅមួយដ៏ណាស់ជាងគេសម្រាប់ប្រជាជនកម្ពុជាភាគច្រើន ហើយត្រូវបានផ្តល់ហេតុផលថាមានលក្ខណៈសមស្របជាមួយទស្សនវិជ្ជាព្រះពុទ្ធសាសនាជាងតុលាការ ។ ទី៣ កម្ពុជាគឺជាប្រទេសមួយដែលត្រូវការមូលនិធិសម្រាប់ការអភិវឌ្ឍច្រើនបំផុតសម្រាប់រាល់គ្រប់វិស័យ ដូច្នេះប្រាក់ដែលចំណាយទៅលើតុលាការអន្តរជាតិសម្រាប់កាត់ក្តីឧក្រិដ្ឋជនដ៏ច្រើនលើសលប់មានទំហំលើសការចំណាយសម្រាប់តុលាការដែលមានសមត្ថកិច្ចកំណត់ គណៈកម្មការស្វែងរកការពិត និងគម្រោងអភិវឌ្ឍ ។ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនអាចនៅជាបញ្ហារ៉ាំរ៉ៃតទៅទៀតទេ ហើយតុលាការសម្រាប់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមរួមជាមួយគណៈកម្មការស្វែងរកការពិត អាចកាត់បន្ថយបញ្ហានេះនិងបង្កើតឲ្យមានការចងចាំប្រវត្តិសាស្ត្ររួមគ្នាមួយដើម្បីធ្វើឲ្យប្រជាជនកម្ពុជាអាចបិទទំព័រសម័យកាលមួយដែលគ្រប់គ្រងដោយរបបព្រៃផ្សៃខ្មែរក្រហម ។ **(នៅមានត)**

**ចាយ៉ា រ៉ាមជី**



## សំឡេងចេញពីផ្នូរ

# ការសម្លាប់រង្គាលនៅបឹងទន្លេសាប

(តពីលេខមុន)

ការគិតរបស់ខ្ញុំដែលប្រឈមមុខនឹងសេចក្ដីស្លាប់ ឥឡូវបានធ្វើឲ្យខ្ញុំមានការព្រួយបារម្ភជាលើកដំបូង ។ ខ្ញុំបានគិតថានឹងព្យាយាមរត់ចេញ ប៉ុន្តែក្រោយពីការគិតពិចារណាមួយសន្ទុះធំមកខ្ញុំមិនអាចធ្វើទៅរួចឡើយ ។ ខ្ញុំគ្មានចិត្តនឹងចាកចេញពីក្រុមគ្រួសារ ជាពិសេសបងថ្លៃស្រីដែលកំពុងតែពពោះនៅសល់តែមួយសប្ដាហ៍ទៀតដល់ថ្ងៃឆ្លងទន្លេនោះទេ ។ ក្រៅពីនេះតើខ្ញុំអាចរត់ទៅកន្លែងណា? ខ្ញុំអាចត្រូវពួកទាហានទាំងនេះចាប់បាននិងសម្លាប់ដោយថាហេតុដូចជាករណីមិត្តរបស់ខ្ញុំឈ្មោះ ឡៃ ក៏ថាបាន ។ បើខ្ញុំស្លាប់ខ្ញុំចង់ស្លាប់ជាមួយអ្នកដែលខ្ញុំស្រឡាញ់ ។ ខ្ញុំមានឱកាសច្រើនណាស់ក្នុងការលួចរត់ចេញពីទីនោះ ប៉ុន្តែខ្ញុំមិនរត់ ។ ដូច្នេះខ្ញុំក៏បេះតែធ្វើដំណើរជាមួយគេឯងដោយលីបងថ្លៃស្រី (សាអ៊ុម) នៅស្មាស្ដាំ និងស្ពាយបង្វេចឥវ៉ាន់នៅស្មាឆ្វេង ។ ឪពុករបស់ សាអ៊ុម ដែលមានវ័យចំណាស់បានខំត្រដររធ្វើដំណើរយ៉ាងស្វាហាប់ដោយគ្មាននរណាជួយឡើយ ។ គាត់ចង់ស្លាប់ដោយកិត្តិយស ។ បុរសចំណាស់ដែលមានវ័យប្រហែលជីតារបស់ខ្ញុំនេះបានដឹងហើយថាពេលវេលារបស់យើងជិតមកដល់ហើយ ។

យ៉ាងណាក៏ដោយក៏វាហាក់ដូចជាមិនគួរឲ្យជឿសោះ ។ យើងដឹងថាខ្លួនត្រូវបង្ខំឲ្យដើរចូលទៅរកសេចក្ដីស្លាប់ដូចសត្វគោក្របីត្រូវគេនាំបញ្ចូលទ្រុងមរណៈអ៊ីចឹង ។ យើងបានដឹងហើយពីកន្លែងដែលយើងកំពុងតម្រង់ទៅ ហើយសូម្បីតែក្មេងៗក៏ដឹងដែរ ។ ខ្ញុំនៅតែមានចម្ងល់បន្តិចបន្តួច ទោះជាអ្វីដែលខ្ញុំបានឃើញនិងស្ដាប់ឮបានកន្លងទៅយូរហើយក៏ដោយ ។ វាប្រហែលជាក្ដីសង្ឃឹមដ៏តូចប៉ុណ្ណោះ ជាក្ដីសង្ឃឹមដែលថាទាហានខ្មែរក្រហមទាំងនោះនឹងមិនមែនជាឃាតករចិត្តត្រជាក់ដូចដែលយើងបានគិតពីមុនមកនោះ ។

នៅចម្ងាយបួន-ប្រាំគីឡូម៉ែត្រជិតដល់បឹងទន្លេសាប ទាហានខ្មែរក្រហមប្រាប់ឲ្យមនុស្សទាំងអស់បត់មកទិសខាងលិច លែងឲ្យធ្វើដំណើរទៅភាគខាងត្បូងដូចដែលបានគ្រោងទុក ។ ផ្លូវឆ្ពោះទៅទីនោះពោរពេញទៅដោយភក់ជ្រាំហើយរអិលទៀតផង ។

ភក់ស្អិតជាប់ជើងរបស់ខ្ញុំរាល់ពេលខ្ញុំឈានជើងមួយជំហានៗ ធ្វើឲ្យដំណើររបស់ខ្ញុំមិនបានលឿនឡើយ ។ ពេលដែលមានមនុស្សផុងជាប់ជើងដើរទៅមុខមិនរួច ទាហានខ្មែរក្រហមក៏ដើរត្រឡប់មកក្រោយ ទាត់និងវាយអ្នកទាំងនោះឲ្យដើរឲ្យលឿន ។ ខ្ញុំមិនដឹងថាតើពីមុនមកទាហានទាំងនេះបានធ្វើអំពើបែបនេះឬក៏អត់ទេ ។ ពេលនោះខ្ញុំរវល់ជួយ សាអ៊ុម ផងនិងជួយខ្លួនឯងផង មិនខ្វល់រឿងអ្វីឡើយ ។ នៅខណៈពេលនោះខ្ញុំបានព្យាយាមធ្វើខ្លួនឲ្យស្ងប់ស្ងាត់និងតាំងចិត្តឲ្យត្រជាក់ ។

ក្រោយមកគ្មានអ្នកណាអាចជួយ សាអ៊ុម បានទៀតឡើយ ។ ការយំខ្សឹកខ្សួលរបស់នាងពុកាន់តែខ្លាំងទៅៗ ហើយក្រោយមកក៏ពុពេញទំហឹងតែម្តង ។ រាងកាយនិងសតិអារម្មណ៍របស់នាងបានប្រែក្លាយខុសពីមុន ។ ម្តាយខ្ញុំនៅជិតនាង ព្យាយាមលួងលោមដោយប្រើពាក្យជំរុញលើកទឹកចិត្តដើម្បីបន្ថយការឈឺចាប់របស់នាង ។ ខ្ញុំបានវង្វេងដានដូវរបស់ឪពុកនិងប្អូនប្រុសខ្ញុំ ។ ខ្ញុំមិនដឹងប្រាកដថាតើក្រុមគាត់នៅទីណាឡើយ ។ មេឃក៏កាន់តែងងឹតទៅៗ ។

សាអ៊ុម និយាយថានាងមិនប្រាកដថារមួលពោះឬក៏ឈឺពោះឆ្លងទន្លេទេ ។ នេះគឺកូនដំបូងហើយដែលនាងត្រូវបង្កើត ។ នាងមិនដឹងថាការឆ្លងទន្លេនិងការចងស្បូនគេធ្វើយ៉ាងណាឡើយ សូម្បីតែខ្ញុំក៏អត់ដឹងដែរ ។ ម្តាយខ្ញុំបានព្យាយាមប្រាប់នាងកុំឲ្យព្រួយបារម្ភ ហើយថាគាត់មានកូនដល់ទៅ១០ឯណោះមិនពិបាកផង ។ ក្រោយមកអ្វីដែលខ្ញុំត្រូវធ្វើគឺជួយអូស សាអ៊ុម កាត់ភក់ដើម្បីកុំឲ្យទាហានខ្មែរក្រហមត្រឡប់មកវាយគាត់ដល់ស្លាប់ ។ មើលទៅគួរឲ្យអាណិតមែនទែន ។

យើងនៅមិនដល់៣០០ម៉ែត្រផងនឹងទៅដល់ដូវធំ ។ ពេលនោះពួកទាហានទាំងនោះឲ្យយើងអង្គុយនៅសងខាងប្រឡាយរាក់មួយដែលលាតសន្ធឹងពីកើតទៅលិច ។ យើងអង្គុយសណ្តូកជើងទៅមុខដោយមិនហ៊ានលាន់មាត់អ្វីមួយម៉ាត់ឡើយ ។ មួយសន្ទុះក្រោយមក មានលេចចេញនូវមនុស្សយ៉ាងតិច៥០នាក់ពីព្រៃនៅក្បែរនោះ ។ ពេលនោះមេឃងងឹតឈឹង ប៉ុន្តែខ្ញុំអាចមើលឃើញមនុស្សស្ទុងៗដែលមានកាន់អាវុធអាកា-៤៧និងកាំបិតនៅក្នុងដៃ ។ ទាហានម្នាក់ក្នុងចំណោម៥០នាក់នោះស្រែកសម្លុតពួកយើងថា "នៅឲ្យស្ងៀមកុំស្រែក!" ។ រំពេចនោះទាហាននៅសល់ប៉ុន្មានក៏ស្ទុះមកព័ទ្ធយើងជិតដោយភ្ជង់កាំភ្លើងចំយើងរួចបានចេញបញ្ជាថា "ចាប់ផ្តើមជីកប្រឡាយដោយដៃទទេភ្លាមឥឡូវនេះ" ។ ពេលនោះខ្ញុំឮសំឡេងទាត់ធាក់និងសម្រែកឈឺចាប់របស់ជនរងគ្រោះ ។

ខ្ញុំបានយកដៃក្បង់ភក់ពីប្រឡាយទាំងមិនដឹងខ្លួនដូចអ្នកដទៃៗទៀតដែរ ។ មនុស្សទាំងអស់បានព្យាយាមអង្វរករសុំក្តីមេត្តាទុកជីវិតឲ្យខ្លួន ។ ប៉ុន្តែទាហានទាំងនោះបានស្រែកគំរាមម្តងហើយម្តងទៀតថាឲ្យបិទមាត់ ។ ការវាយដំប្រំធាក់ក៏ចេះតែបន្ត ។ គ្រាប់កាំភ្លើងដៃបានរត់ប៉ះនឹងស្បែកនិងឆ្អឹងធ្វើឲ្យមានជាសំឡេងយ៉ាងទ្រហឹងលាយឡំជាមួយនឹងសម្រែកឈឺចាប់របស់ជនរងគ្រោះ ។ បុរសម្នាក់ឈ្មោះ រុំ នៅជិតគ្រួសាររបស់ខ្ញុំដែរ បានស្រែកអង្វរពួកវាថា "មិត្ត! សូមមេត្តាកុំធ្វើបាបពួកយើងខ្ញុំ ។ កុំធ្វើបាបគ្រួសារខ្ញុំ ខ្ញុំសូមអង្វរ" ។ ហើយទាហានខ្មែរក្រហមក៏ស្រែកតបវិញថា "អង្គការថ្នាក់លើមិនធ្វើបាបមិត្តទាំងអស់គ្នាទេ ប៉ុន្តែគ្រាន់តែចង់សួរសំណួរមួយចំនួនប៉ុណ្ណោះ ។ មានតែប៉ុណ្ណោះឯង" ។

រុំ បានបន្តថា "សូមមិត្តមេត្តាទុកពេលនិងជីវិតយើងខ្ញុំផង ។ ទុកគ្រួសារយើងផង ព្រោះយើងបានជួយអង្គការក្នុងពេលសង្គ្រាមដូចជាផ្តល់ថ្នាំសង្កូវនិងផ្តល់ពត៌មានទៀតផង ។ សូមទុកជីវិតឲ្យពួកយើងផង" ។ ពេលនោះមេបញ្ជាការរបស់ក្រុមទាហាននោះបានសួរទៅ រុំ ថា "អ្នកឯងជួយអង្គការតាំងពីអង្កាល់? នៅកន្លែងណា? តើទាក់ទងជាមួយអ្នកណា?" ។

ខ្ញុំមិនបានដឹងថា រុំ ជាអ្នកគាំទ្រខ្មែរក្រហមឡើយក្នុងអំឡុងពេលសង្គ្រាមកន្លងមក ។ ការអង្វរនិងការរ៉ាយរ៉ាប់អំពីសកម្មភាពរបស់ រុំ ព្រមទាំងគ្រួសាររបស់គាត់ ធ្វើឲ្យខ្ញុំមានកំហឹងយ៉ាងខ្លាំង ។ ខ្ញុំសម្លឹងមុខ រុំ ហើយនិយាយស្ងាត់ៗក្នុងចិត្តថា "អាកំសាក! ឯងគួរតែស្លាប់ដូចជាពួកអាកំសាកទៅ ។ ឯងសមតែស្លាប់ដោយដៃពួកដែលឯងបានជួយដូច្នេះទើបសម" ។ ខ្ញុំនឹងស្លាប់ដោយកិត្តិយសមិនមែនកំសាកដូច រុំ ឡើយ ។ វាសមមុខហើយដែលបានបង្កើតនិងធ្វើឲ្យបិសាចខ្មែរក្រហមឡើងកាន់អំណាច ។ រុំ សមតែស្លាប់ដោយសារទង្វើរបស់ខ្លួន ។ កំសាកណាស់ ។ រុំ នឹងស្លាប់មិនខាន ។

មេបញ្ជាការរបស់ខ្មែរក្រហមបានបញ្ជាក់ រុំ ថា "នេះគ្រាន់

តែជាការសួរចម្លើយមួយប៉ុណ្ណោះ» ។ មេបញ្ជាការនោះបន្ថែមយ៉ាងម៉ឺងម៉ាត់ចំពោះ វុំ ព្រមទាំងអ្នកដទៃៗទៀតថា «អង្គការកំពុងសង្ស័យថាមានខ្មាំងនៅក្នុងចំណោមពួកយើងនេះ ។ មានភ្នាក់ងារវៀតណាមនៅក្នុងក្រុមនេះ» ។

ខ្ញុំដឹងថាការអះអាងនេះមិនមែនជាការពិតឡើយ ព្រោះយើងបានស្គាល់គ្នាជាច្រើនឆ្នាំមកហើយ ។ នេះគឺជាល្បិចរបស់ខ្មែរក្រហមតែប៉ុណ្ណោះ ។ ជាល្បិចដ៏កខ្វក់ដែលចង់ឲ្យយើងស្ងប់ស្ងាត់ ខ្សោយ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់វា ។ ប៉ុន្តែល្បិចនេះមានប្រសិទ្ធភាពណាស់ ពីព្រោះអ្នកដើងខ្លាំងទាំងអស់ដែលអាចធ្វើការតវ៉ាប្រឆាំងគឺជាអ្នកដែលត្រូវទៅមុនគេ ។ អ្នកដែលត្រូវទុកចោលនៅក្នុងក្រុមរបស់ខ្ញុំមានតែស្ត្រី កុមារ អ្នកឈឺ និងអ្នកដែលខ្សត់ខ្សោយកម្លាំងតែប៉ុណ្ណោះ ។ អង្គការថ្នាក់លើចង់ឲ្យយើងមានសិទ្ធិធ្វើអ្វីស្រេចតែខ្លួននឹកឃើញ ។ អ្វីៗទាំងអស់សុទ្ធតែជាការគ្រោងទុកមុនទាំងអស់ ។

រំពេចនោះមានទាហានម្នាក់ដើរយ៉ាងអន្ទះសារសំដៅមករកខ្ញុំដោយហូតក្រមាពីខ្ញុំហើយហែកជាចម្រៀកៗ ។ ខ្ញុំគឺជាមនុស្សទីមួយហើយដែលត្រូវបានចាប់ចងដោយពួកទាហានដែលមានក្លិនអសោចបែបនេះ ។ ខ្ញុំមានអារម្មណ៍រន្ធត់ណាស់ ។ ខ្ញុំព្យាយាមរើតិចៗដែរ ។ បន្ទាប់ពីទទួលពីរ-បីស្មាយកាំភ្លើងចំក្បាលរួចមកហើយមានអាម្នាក់ចូលមកទៀតនោះ ខ្ញុំក៏ស្រែកខ្លាំងៗដោយក្តីឈឺចាប់ ។ អ្នកណាក៏ឮសម្រែកនេះដែរទោះបីស្ថិតនៅរាប់គីឡូម៉ែត្រក៏ដោយ ។ ខ្ញុំបណ្តោយខ្លួនឲ្យទាហានទាំងពីរនាក់នោះធ្វើអ្វីស្រេចតែចិត្ត ។ ក្រោយពីខ្ញុំស្រែកយ៉ាងខ្លាំងទាហាននោះក៏យករបស់មកអ្វីម្យ៉ាងមកញ៉ុកមាត់ខ្ញុំ ។ ទាហានខ្មែរក្រហមទាំងពីរនាក់ចាប់ខ្ញុំចងស្លាបសេក ។ ពេលនោះខ្ញុំដឹងថានេះជាគ្រាបញ្ចប់នៃជីវិតរបស់ក្រុមខ្ញុំនេះហើយ ហើយកាន់តែច្បាស់ជាងនេះទៅទៀតនោះគឺជីវិតខ្ញុំតែម្តង ។

ក្បាលរបស់ខ្ញុំចាប់ផ្តើមហូរឈាម ។ ខ្ញុំស្ថិតនៅក្នុងលក្ខណៈពាក់កណ្តាលដឹងខ្លួននិងពាក់កណ្តាលសន្លប់ ។ ខ្ញុំនៅដឹងឈឺនិងដឹងថាឈាមកំពុងហូរធ្លាក់មកលើមុខខ្ញុំ ។ ពួកខ្មែរក្រហមបានយកខ្ញុំធ្វើជាគំរូដល់អ្នកដទៃទៀត ។ ឧទាហរណ៍នេះបានប្រាប់ថាបើអ្នកណាហ៊ានប្រឆាំងនឹងត្រូវទទួលការឈឺចាប់បែបនេះមិនខាន ។ ក្រោយមក ទាហានខ្មែរក្រហមទាំងនោះក៏ចាប់ចងប្រជាជនដែលនៅសេសសល់ទាំងប៉ុន្មានដោយគ្មានបញ្ហាអ្វីឡើយ ។

មកដល់ចំណុចនេះខ្ញុំមានការជ្រួលជ្រើមនៅពេលដែលអ្នកផ្សេងទៀតអង្វរករសុំជីវិត ។ ខ្ញុំចាប់ផ្តើមវិលមុខខ្លាំងទៅៗហើយងងឹតមុខទៀតផងនៅពេលដែលឈាមចេះតែហូរធ្លាក់ឥតឈប់កាត់មុខនិងភ្នែកស្តាំខ្ញុំ ។ នេះជាលើកទីមួយហើយដែលទឹកភ្នែកខ្ញុំហូរធ្លាក់មក ។ ទោះជាមានហូរឈាមឬឈឺចាប់ក៏ដោយក៏ខ្ញុំមិនដែលសម្រក់ទឹកភ្នែកឡើយ ។ ប៉ុន្តែឥឡូវនេះការពិតក៏ចូលមកដល់ហើយបានបង្ខំឲ្យខ្ញុំយំទៀតផង ។ ខ្ញុំវង្វេងវង្វាន់ ។ ពេលនោះខ្ញុំបានបាត់បង់សតិ ។ ខ្ញុំបានព្យាយាមប្រាប់ខ្លួនឯងថានេះមិនមែនជាការពិតទេ វាគ្រាន់តែជាសុបិនដ៏អាក្រក់មួយតែប៉ុណ្ណោះ ។

ខ្ញុំហួសពីរន្ធត់ទៅទៀតពេលដែលឮសំឡេងវាយបង្ក្រាបចាប់ផ្តើម ។ មិនដឹងជាយ៉ាងម៉េចទេខ្ញុំបែរជាដឹងថាវាជារឿងពិត ។ ឪពុករបស់ សាអ៊ុម ដែលនៅជិតខ្ញុំក៏ដួលមកលើខ្ញុំក្រោយពីត្រូវព្រនង់យ៉ាងធ្ងន់ធ្ងរ ។ នៅពេលនោះដែរ ខ្ញុំសង្កេតឃើញក្មេងតូចម្នាក់ឈ្មោះ អាផាត ដែលខ្ញុំស្គាល់ច្បាស់ជាងគេ បានងើបប្រវេប្រវាស្រែករកម្តាយរបស់វា ។ រំពេចនោះក៏មានអ្វីម្យ៉ាងក្តៅខណ្ហៗបានខ្ទាតមកលើមុខខ្ញុំ ។ ខ្ញុំដឹងប្រាកដថាវាមិនមែនជាភក់ឡើយ ។ តាមពិតវាគឺជាឈាមដែលជាស្រទាប់ខួររបស់ក្មេងតូចអម្បាញ់មិញដែលត្រូវទទួលព្រនង់ផ្តាច់ជីវិតពីពួកពេជ្ឈឃាតខ្មែរក្រហម ។ ទោះជាមានសំឡេងស្រែកទ្រហោយំនិងការអង្វរករសុំក្តីមេត្តាក៏ដោយ ក៏ខ្ញុំនៅតែឮស្នូរដង្ហើមក្រគៗរបស់មនុស្សជិតស្លាប់ដែរ ។ អ្វីៗគ្រប់យ៉ាងហាក់ដូចជាស្ថិតក្នុងសភាពយឺតៗដូចជានៅក្នុងភាពយន្តដូច្នេះដែរ ។ មើលទៅហាក់ដូចជាមិនមែនជាការពិតសោះឡើយ ។ វាកើតឡើងតែមួយភ្លែតតែប៉ុណ្ណោះ តែខ្ញុំនៅតែអាចចាំយ៉ាងច្បាស់នូវរឿងរ៉ាវដែលមិនសូវសំខាន់ ។ ខ្ញុំមិនហ៊ានបើកភ្នែកមើលឡើយ ប៉ុន្តែសំឡេងដ៏គួរឲ្យរន្ធត់បានជ្រាបចូលក្នុងប្រព័ន្ធសោតវិញ្ញាណរបស់ខ្ញុំធ្វើឲ្យសង្កៀរត្រចៀក ។ ខ្ញុំនៅតែត្រូវជាប់ចំណងនិងញ៉ុកមាត់ដដែល ប៉ុន្តែភ្នែកនិងត្រចៀករបស់ខ្ញុំមិនអាចបដិសេធនូវអ្វីដែលខ្ញុំបានមើលឃើញនិងស្តាប់ឮនៅពេលនោះបានឡើយ ។ ខ្ញុំពេលនោះគឺស្ថិតនៅក្នុងឋាននរក ។ **(នៅមានត)**

**យិមស៊ុត វ៉ាណាឌិត**

## លិខិតស្វែងរកគ្រួសារ

ខ្ញុំបាទឈ្មោះ យ៉ាត កំសាន្ត អាយុ៤៥ឆ្នាំ ជាបុគ្គលិកអង្គការលីកាដូខេត្តបាត់ដំបង ដែលមានទីលំនៅក្រុមទី១៣ ភូមិកាប់គោថ្មី ឃុំអូរចារ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

សូមគោរពជូន

លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

សំណូមពរៈ សូមលោកនាយកមេត្តាចុះផ្សាយពីដំណឹងស្វែងរកក្មួយស្រីរបស់ខ្ញុំបាទដែលបានបាត់ខ្លួនក្នុងអំឡុងឆ្នាំ១៩៧៧នៃរបបប៉ុលពត ។ ក្នុងក្តីសង្ឃឹមថាខ្ញុំបាទនឹងបានសម្រេចតាមសំណូមពរដោយក្តីអនុគ្រោះ ។ សូមលោកនាយកទទួលនូវក្តីរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

**ភ្ជាប់មកជាមួយនូវប្រវត្តិរឿងៈ**

នាងឈ្មោះ នូ ដាណារិន ហៅ ពីង ឆ្នាំកំណើត១៩៦៧ ក្នុងពេលជម្លៀសចេញនៅក្នុងឆ្នាំ១៩៧៥ នាងបានរស់នៅជាមួយខ្ញុំបាទនៅឃុំអូរតាគី ស្រុកបាត់ដំបង ក្នុងអំឡុងចុងឆ្នាំ១៩៧៥ នាងបានមករស់នៅជាមួយម្តាយធំខ្ញុំបាទនៅខាងមុខរោងចក្រតម្បាញក្នុងខេត្តបាត់ដំបង ។ ក្នុងអំឡុងខែ៣ ឆ្នាំ១៩៧៦ ម្តាយធំខ្ញុំបាទខូច(ស្លាប់) ពេលនោះមានយោធានារីម្នាក់ឈ្មោះ ខឿន (ដែលសព្វថ្ងៃពុំដំណឹងថាមានស្រុកកំណើតនៅភូមិក្រពើ ឃុំភ្នំសំពៅ បាត់ដំបង) សុំយកទៅធ្វើជាប្អូនចិញ្ចឹមដោយបានដាក់ឈ្មោះថ្មីថា ខឿន ។ លុះក្រោយមកក្នុងឆ្នាំ១៩៧៧ ពុំដំណឹងថានារីនោះត្រូវបានអង្គការផ្លាស់ឲ្យទៅនៅឃុំកកោះ ស្រុកមោងឫស្សី តាំងពីពេលនោះមកក៏បាត់ដំណឹងសូន្យឈឹងតែម្តងរហូតមកទល់សព្វថ្ងៃនេះ ។

ម្តាយបង្កើតរបស់នាងឈ្មោះ អ៊ឹម កូឡាប អាយុ៥២ឆ្នាំ ។ ឪពុកឈ្មោះ នូ ភន (ស្លាប់) ។ មានបងប្អូនបង្កើតចំនួន៣នាក់ៈ ១) នូ ដាណារី ហៅ ស្រី ហៅ កៅ សូលីណា ឆ្នាំកំណើត ១៩៦៥ ២) នូ ដាណារិន ហៅ ពីង ឆ្នាំកំណើត១៩៦៧ (សាមីខ្លួនដែលបាត់) ៣) នូ ដាណារ៉ា ហៅ ពុជ ហៅ កៅ សូលីដា (ស្លាប់) ។

បាត់ដំបង ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០០

យ៉ាត កំសាន្ត

## លិខិតថ្លែងអំណរគុណ

ប្រធានបណ្ណាល័យ ហ៊ុន សែន នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

សូមគោរពជូន

លោកប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា

លោកប្រធានជាទីគោរពរាប់អាន

តាងនាមឲ្យលោកសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងនាមសិស្ស និស្សិត និងអ្នកអានស្រាវជ្រាវទូទៅ បណ្ណាល័យ ហ៊ុន សែន សូមសម្តែងនូវសេចក្តីអំណរគុណនិងការដឹងគុណដ៏ជ្រាលជ្រៅចំពោះអំណោយទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា «ស្វែងរកការពិត» ចំនួន១០ក្បាល ដែលមជ្ឈមណ្ឌលលោកបានផ្ញើអំណោយដល់បណ្ណាល័យ ហ៊ុន សែន ។ ទស្សនាវដ្តីទាំងនេះមានប្រយោជន៍ណាស់ក្នុងការផ្តល់ចំណេះដឹងផ្នែកប្រវត្តិសាស្ត្រខ្មែរ និងឯកសារនយោបាយផ្សេងៗដល់អ្នកអានទូទៅ ។

ដូចនេះ បណ្ណាល័យ ហ៊ុន សែន ខិតខំរៀបចំទុកដាក់ទស្សនាវដ្តីទាំងនេះទៅតាមបច្ចេកទេសបណ្ណាល័យ រួចដាក់ជូនសាធារណជនប្រើប្រាស់តាមសេចក្តីត្រូវការ ។ បណ្ណាល័យសង្ឃឹមថា ទស្សនាវដ្តីទាំងនេះនឹងក្លាយទៅជាវត្ថុបំណងចាំបាច់មួយដែលអ្នកអានចាប់អារម្មណ៍ពុំខាន ។

យើងខ្ញុំសន្យានឹងថែរក្សាសៀវភៅទាំងនោះឲ្យបានគង់វង្សជាសម្បត្តិរដ្ឋ ជាឯកសារដ៏មានតម្លៃយូរលង់ ដើម្បីបម្រើវិស័យស្រាវជ្រាវនិងសិក្សាធិការជាតិ ។

ជាថ្មីម្តងទៀត យើងខ្ញុំសូមថ្លែងអំណរគុណចំពោះស្មារតីដ៏ខ្ពង់ខ្ពស់របស់លោកប្រធានក្នុងការជួយអភិវឌ្ឍបណ្ណាល័យ ហ៊ុន សែន ។ យើងខ្ញុំសង្ឃឹមនិងជឿជាក់ថាលោកប្រធាននឹងបន្តការជួយឧបត្ថម្ភបណ្ណាល័យ ហ៊ុន សែន តរៀងទៅជាក់ជាពុំខានឡើយ ។

សូមគោរពជូនពរថ្ងៃថ្នាមហាប្រសើរដល់លោកប្រធាន និងសូមលោកប្រធានមេត្តាទទួលនូវការគោរពពីយើងខ្ញុំ ។

ភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០

អនុប្រធានបណ្ណាល័យ ហ៊ុន សែន

ពៅ វណ្ណនី

ចម្រៀងខ្មែរក្រហម

# យើងខ្ញុំនារីបដិវត្តកម្ពុជាថ្មី

ស្ត្រីបដិវត្តន៍រះភ្លឺចាំងចែង
ភ្លឺដូចសូរ្យសែងសាយសព្វទិស
ពាសពេញមាតុភូមិជាទីស្នេហា
ធំធេងអស្ចារ្យស្តុកស្តម្ភក្រៃ ។
យើងខ្ញុំនារីធ្លាប់អាប់យស
បាត់កេរ្តិ៍បាត់ឈ្មោះរស់នៅគ្មានន័យ
ឥឡូវបានឃើញស្ត្រី
មានសិទ្ធិសេរីហើយឆ្លាស់ឆ្លង ។
មានមុខមានមាត់ស្មើបុរស
មានកេរ្តិ៍មានឈ្មោះសាយពីរោះផង
អង្គការលើកស្ទួយជួយតម្រង់
កិត្តិស័ព្ទផូរផង់ឈ្ងុយឈ្ងប់សាយ ។
យើងខ្ញុំមានភ័ព្វដូចកើតថ្មី
បានស្គាល់អត្ថន័យនៃនយោបាយ
មានសតិអារម្មណ៍រឹងឥតក្លាយ
សីលធម៌មាំក្រៃថ្លៃឧត្តម ។
ត្រចៀកយើងខ្ញុំបានឮសូរ
កែវភ្នែកទាំងគូបានភ្លឺស័ក្តិសម
ចេះស្តាប់ចេះអានគ្មានច្រឡំ
ចេះកត់ចំណាំបែកប្រាជ្ញា ។
យើងខ្ញុំសាមគ្គីយ៉ាងស្ម័គ្រស្មោះ
ជាមួយបុរសក្នុងគ្រប់ការងារ
ធ្វើពេទ្យ ធ្វើកម្មករ ធ្វើយោធា
បង្កើនផលយ៉ាងប្តូរផ្តាច់ ។
អត្តភាពយើងខ្ញុំចាំងភ្លឺថ្លា
ឯករាជ្យម្ចាស់ការគ្រប់គ្រងភារកិច្ច
ហ៊ានទទួលខុសត្រូវជានិច្ច
ប្រយុទ្ធអង់អាចជូនបដិវត្តន៍ ។
យើងខ្ញុំឈឺចាប់ពេញអង្គប្រាណ
ឆ្អួលឆេះគ្មានស្រាន្តនឹងអាចក្រពត្តិ
ជិះជាន់យើងរាប់សតវត្សរ៍
វេទនាពេកក្តាត់បាត់រស្មី ។
បដិវត្តន៍កម្ពុជាមានគុណ
គុណនេះមហាធ្ងន់សែនធ្ងន់ឥតបី
ជាងភ្នំព្រះសុមេរុស្កឹមស្កៃ
រំដោះនារីផុតពីទុក្ខា ។
ដូច្នេះយើងខ្ញុំសូមប្តូរផ្តាច់
បូជាឈាមសាច់បូជាទាំងជីវ៉ា
កសាងសង្គមថ្មីថ្លៃថ្លា
ស្លាប់រស់គ្មានរាការពារជាតិ ។

**កត់ត្រាចងក្រងជាឯកសារ**

**កញ្ញា សើ សាយ្យ៉ាណា**

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុក និងឃុំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។
ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។
The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or (855) 18 812 558. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 9, September 2000
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; and the Canada Funds, Canadian Embassy, Phnom Penh, Cambodia